## សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិង វិទ្យាសាស្ត្រសេដ្ឋកិច្ច

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# ការកសាងមូលធនមនុស្សក្នុងវិស័យនវានុវត្តន៍ឌីជីថល

ករណីសិក្សា៖ ធនធានមនុស្សក្នុងវិស័យនវានុវត្តន៍ឌីជីថលនៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ **កញ្ញា វេង ស៊ូមុី**

**លោក ពុធ តារារ័ត្ន**

ណែនាំដោយ

សាស្ត្រាចារ្យបណ្ឌិត **ខ៉ាន់ ស៊ុនដេត**

ថ្នាក់បរិញ្ញាបត្រ **សេដ្ឋកិច្ចអភិវឌ្ឍន៍**

ជំនាន់ទី ០៨

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិង វិទ្យាសាស្ត្រសេដ្ឋកិច្ច

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**

# សារណាបញ្ចប់ការសិក្សា

## ការកសាងមូលធនមនុស្សក្នុងវិស័យនវានុវត្តន៍ឌីជីថល

ករណីសិក្សា៖ ធនធានមនុស្សក្នុងវិស័យនវានុវត្តន៍ឌីជីថលនៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ **កញ្ញា ខេង ស៊ូមី**

**លោក ពុធ តារារ័ត្ន**

ណែនាំដោយ

សាស្ត្រាចារងបណ្ឌិត **ម៉ាន់ ស៊ុនដេត**

ថ្នាក់បរិញ្ញាបត្រ **សេដ្ឋកិច្ចអភិវឌ្ឍន៍**

ជំនាន់ទី ០៨

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ ពុធ តារារ័ត្ន និង វេង ស៊ូមុី ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែក សេដ្ឋកិច្ចអភិវឌ្ឍន៍ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**សូមលំឱនកាយគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ ៖**

- លោកឪពុក **ពុធ សុខធី** និង អ្នកម្តាយ **គឹម ស្រី**
- លោកឪពុក **នៃ ម៉ុនលាភ** និង អ្នកម្តាយ **ជឹម ណារី**

ដែលលោកបានផ្តល់កំណើតដល់យើងខ្ញុំទាំងទ្វេជាពិសេសលោកបានលះបង់យ៉ាងច្រើន ដែលមិនអាចកាត់ថ្លៃបានក្នុងការចិញ្ចឹមបីបាច់ថែរក្សា និងផ្តល់នូវសេចក្តីស្រឡាញ់ មេត្តាករុណា អប់រំទូន្មានឱ្យមានសេចក្តីព្យាយាមអំណត់ក្លាហាន ព្រមទាំងបានធ្វើពលិកម្មគ្រប់យ៉ាងដល់ កូនរហូតបានបញ្ចប់ការសិក្សាដោយទទួលបាននូវចំណេះដឹងថ្លៃថ្លារហូតដល់ចប់ចុងចប់ដើម។ កូន សូមក្រាបប្រណិបត្តិ ដែលមានចំពោះកូន និងសម្តែងកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតចំពោះអ្នកមានគុណទាំងពីរ។

យើងខ្ញុំទាំងទ្វេក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តមសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការ រង លោក-លោកស្រីប្រធានដេប៉ាតឺម៉ង់ លោក-លោកស្រីប្រធានការិយាល័យ លោក-លោកស្រីអនុ ប្រធានដេប៉ាតឺម៉ង់ លោក-លោកស្រីសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងបុគ្គលិកទាំងអស់រួមទាំងផ្នែកសន្តិសុខ និងអ្នកអនាម័យ ដែលបានខិតខំប្រឹង ប្រែងយកអស់ពីសមត្ថភាពទាំងកំលាំងកាយ កំលាំងចិត្ត និងកំលាំងប្រាថ្នាក្នុងការសរសេររបាយការណ៍បញ្ចប់សិក្សានេះកាន់តែទទួលបានលទ្ធផលល្អថែមទៀត។

ជាពិសេស យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **លោកសាស្ត្រាចារ្យ បណ្ឌិតចាន់ ស៊ុនដេត** ដែលលោកបានខិតខំទាំងកម្លាំងកាយ និងកម្លាំងកាយចិត្តក្នុងការដឹកនាំក្រុមយើងខ្ញុំដោយផ្តល់នូវវិធីសាស្ត្រក្នុងការចុះស្រាវជ្រាវ និងប្រមូលព័ត៌មានយកមកចងក្រងទើបសរសេរបានជារបាយការណ៍កម្មសិក្សាមួយច្បាប់នេះ។

ជាទីបញ្ចប់យើងខ្ញុំសូមគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតហើយក៏សូមគោរពជូនពរដល់លោកឪពុក អ្នកម្តាយ ព្រមទាំងលោកឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោកសាស្ត្រាចារ្យណែនាំ ព្រមទាំងលោក លោកស្រី ជាសាស្ត្រាចារ្យ និងបុគ្គលិកទាំងអស់ សូមជួបប្រទះនូវព្រះពុទ្ធពរទាំងឡាយ បួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។ សូមអរគុណ៕

# អារម្ភកថា

បន្ទាប់ពីបានសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចលើមុខវិជ្ជាជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍រយៈពេល៤ឆ្នាំកន្លងមកនេះ យើងខ្ញុំទាំងពីរនាក់ក៏បានសម្រេចចិត្តចាប់ដៃគូជាមួយគ្នាសរសេរសារណាដើម្បីបញ្ចប់ការសិក្សា ដើម្បីបន្សល់ទុកជាស្នាដៃមួយសម្រាប់គុណប្រយោជន៍ដល់សិស្សនិស្សិតជំនាន់ក្រោយៗ ក្នុងការសិក្សាស្រាវជ្រាវបន្ត។

ដោយក្រុមយើងខ្ញុំសង្កេតឃើញថា ក្នុងយុគសម័យនៃសេដ្ឋកិច្ចឌីជីថលនៅប្រទេសកម្ពុជា កំពុងមានការអភិវឌ្ឍជាលំដាប់ទៅតាមលំហូរនៃគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញក្នុងការអនុវត្តដើម្បីសម្រេចឱ្យបានទៅដល់គោលដៅដែលចង់បាននិងប្រទេសមានការអភិវឌ្ឍ។ នាពេលបច្ចុប្បន្នកម្ពុជាមានការយល់ដឹងពីវិស័យឌីជីថលដែលគួរឱ្យកត់សម្គាល់ ហើយក៏ជាផ្នែកមួយនៃប្រភពចំណូល មានភាពប្រកួតប្រជែង និងផ្តល់ជាការងារច្រើនដល់ប្រជាជន ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទបញ្ចប់ការសិក្សាមួយនេះ យកមកសិក្សាស្រាវជ្រាវដែលទាក់ទងទៅនឹង **ការកសាងមូលធនមនុស្សក្នុងវិស័យនវានុវត្តន៍ឌីជីថល**។ មូលហេតុដែលជំរុញឲ្យយើងខ្ញុំជ្រើសយកប្រធានបទនេះ ដោយសារតែយើងខ្ញុំមានគោលបំណងចង់ពង្រីកចំណេះដឹង និងបញ្ចេញសមត្ថភាពក្នុងការស្រាវជ្រាវប្រធានបទមួយនេះ និងធ្វើការស្វែងយល់បន្ថែមលើវិស័យឌីជីថល ដែលមនុស្សមួយចំនួនមិនទាន់យល់ដឹងច្បាស់។ តាមរយៈស្នាដៃស្រាវជ្រាវមួយនេះ យើងខ្ញុំសង្ឃឹមថាវានឹងអាចជួយបន្ថែមនូវចំណេះដឹងថ្មីៗនិងផ្តល់ជាអត្ថប្រយោជន៍ជាច្រើនទៅដល់អ្នកអានគ្រប់ៗរូបឲ្យបានយល់កាន់តែស៊ីជម្រៅ អំពីសេដ្ឋកិច្ចឌីជីថលក្នុងសារណាមួយក្បាលនេះ។

ជាចុងក្រោយ យើងខ្ញុំទាំងពីរនាក់សូមធ្វើការខន្តីអភ័យទោសនូវរាល់ចំណុចខ្វះខាតដូចជា ពាក្យពេចន៍ អត្ថន័យ ឬកំហុសឆ្គងដោយអចេតនាណាមួយ ដែលមាននៅក្នុងសារណាមួយក្បាលនេះទុកជាមុន ព្រោះយើងខ្ញុំជឿជាក់ថា ពិតជាគ្មានអ្វីដែលល្អឥតខ្ចោះនោះទេ។ ដូចនេះយើងខ្ញុំត្រូវទទួលស្គាល់នូវកំហុស និងទទួលយកនូវការកែតម្រូវតាមរយៈការផ្តល់ជាមតិយោបល់ រិះគន់ដើម្បីស្ថាបនារបស់មិត្ត និស្សិត និងអ្នកអានទាំងអស់ ដើម្បីឲ្យស្នាដៃមួយនេះកាន់តែមានភាពល្អប្រសើរឡើង។

# មាតិកា

ទំព័រ

បញ្ជីពាក្យកាត់.....vi

បញ្ជីក្រាហ្វិក.....vii

**សេចក្តីផ្តើម៖.....១**

១. លំនាំបញ្ហានៃការស្រាវជ្រាវ.....១

២. កម្មវត្ថុនៃការស្រាវជ្រាវ.....១

៣. ចំណោទបញ្ហា.....២

៤. សារៈសំខាន់នៃការស្រាវជ្រាវ.....២

៥. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ.....៣

៦. វិធីសាស្ត្រនៃការស្រាវជ្រាវ.....៣

  ៦.១. វិធីសាស្ត្រនៃការប្រមូលទិន្នន័យ.....៤

  ៦.២. វិធីសាស្ត្រនៃការវិភាគទិន្នន័យ.....៤

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ.....៤

**ជំពូកទី១**

**ទស្សនៈនានាជុំវិញការកសាងមូលធនមនុស្ស**

១.១. និយមន័យ.....៧

  ១.១.១. និយមន័យមូលធនមនុស្ស.....៧

  ១.១.២. និយមន័យនវានុវត្តន៍ឌីជីថល.....៧

១.២. សក្តានុពលនៃបរិវត្តកម្មឌីជីថល.....៨

១.២.១. សក្តានុពលលើមូលធនមនុស្ស..........................................................................................៨

១.២.២. សក្តានុពលលើនវានុវត្តន៍ឌីជីថល...................................................................................១០

១.៣. ទំនាក់ទំនងរវាងធនធានមនុស្ស និង ឌីជីថល......................................................................១១

១.៤. ផលប៉ះពាល់បណ្តាលមកពីបរិវត្តឌីជីថល.............................................................................១១

១.៤.១. ផលប៉ះពាល់ទៅលើសង្គម...........................................................................................១១

១.៤.២. ផលប៉ះពាល់ទៅលើសេដ្ឋកិច្ច.......................................................................................១៣

## ជំពូក២

## ការត្រៀមខ្លួនរបស់ប្រទេសកម្ពុជាក្នុងការកសាងមូលធនមនុស្សឌីជីថល និង នវានុវត្តន៍ឌីជីថល

**២. គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២ - ២០៣៥**

២.១. ចក្ខុវិស័យ.........................................................................................................................១៥

២.២. គោលបំណង......................................................................................................................១៥

២.៣. យុទ្ធសាស្រ្តទី៧៖ ការកសាងធនធានមនុស្សឌីជីថល.................................................................១៥

២.៤. យុទ្ធសាស្រ្តទី៨៖ ការស្រាវជ្រាវ និង នវានុវត្តន៍ឌីជីថល..........................................................១៧

**៣. ពិនិត្យមើលឯកសារស្រាវជ្រាវនានាពាក់ព័ន្ធនឹងការត្រៀមខ្លួនក្នុងវិស័យឌីជីថលរបស់យុវជនកម្ពុជា៖**

៣.១. ឯកសារស្រាវជ្រាវពីក្រសួងពាក់ព័ន្ធនានា..............................................................................១៧

៣.២. ឯកសារស្រាវជ្រាវនានាពាក់ព័ន្ធនឹងសេដ្ឋកិច្ច និង សង្គមឌីជីថល.............................................១៨

៣.៣. ហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់បរិវត្តកម្មឌីជីថល.........................................................................២០

៣.៤. ទំនុកចិត្ត និង ភាពជឿជាក់លើប្រព័ន្ធឌីជីថល........................................................................២១

៣.៥. ពលរដ្ឋឌីជីថល.....................................................................................................................២១

៣.៦. រដ្ឋាភិបាលឌីជីថល..........................................................................................................២២

៣.៧. ធុរកិច្ចឌីជីថល...............................................................................................................២២

## ៤. ការបញ្ចៀស ការបន្ថយ និងដោះស្រាយផលប៉ះពាល់ និងការគ្រប់គ្រងហានិភ័យ

៤.១. ហានិភ័យពាក់ព័ន្ធនឹងមូលធនមនុស្ស និង ហិរញ្ញវត្ថុ............................................................២២

៤.២. ហានិភ័យពាក់ព័ន្ធនឹងការអភិវឌ្ឍន៍ឆាប់រហ័សនៃបច្ចេកវិទ្យា...................................................២៣

## ជំពូកទី៣

## ការវិភាគទិន្នន័យ

៣.១. ការប្រមូលទិន្នន័យ..........................................................................................................២៤

៣.២. ពិពណ៌នាទិន្នន័យ..........................................................................................................២៤

៣.២.១. កម្រងសំណួរចំពោះ ស្ថាប័នរដ្ឋ និង ឯកជន.......................................................................២៤

៣.២.១.១. ភេទ..............................................................................................................២៤

៣.២.១.២. អាស័យដ្ឋាន.....................................................................................................២៥

៣.២.១.៣. ប្រភេទការងារ...................................................................................................២៦

៣.២.១.៤. ជំនាញឌីជីថល..................................................................................................២៦

៣.២.១.៥. ការទទួលការបណ្ដុះបណ្ដាល................................................................................២៧

៣.២.១.៦. ការប្រើប្រាស់ឌីជីថល.........................................................................................២៨

៣.២.១.៧. បញ្ហាជួបប្រទះនៃការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលនៅក្នុងការបំពេញការងារ.................២៩

៣.២.១.៨. អ្នកជំនាញឌីជីថល.............................................................................................៣០

៣.២.១.៩. អត្ថប្រយោជន៍នៃបច្ចេកវិទ្យាឌីជីថល.....................................................................៣០

៣.២.២. កម្រងសំណួរសម្រាប់យុវជន និង សិស្សានុសិស្ស...........................................................៣១

៣.២.២.១. ភេទ..........៣១

៣.២.២.២. អាស័យដ្ឋាន..........៣២

៣.២.២.៣. កម្រិតនៃការសិក្សា..........៣៣

៣.២.២.៤. មុខរបរផ្ទាល់ខ្លួន..........៣៣

៣.២.២.៥. ការយល់ដឹងពីឌីជីថល..........៣៤

៣.២.២.៦. ការទទួលការបណ្តុះបណ្តាល..........៣៥

៣.២.២.៧. ការប្រើប្រាស់ឌីជីថល..........៣៥

៣.២.២.៨. ផលចំណេញពីឌីជីថលចំពោះ ការសិក្សា និង មុខរបរ..........៣៦

៣.២.២.៩. ស្ថានភាពអាជីវកម្ម និង ការសិក្សា ក្រោយពេលប្រើប្រាស់ឌីជីថល..........៣៧

៣.២.២.១០. មតិចំពោះឌីជីថល..........៣៨

៣.៣. វិភាគទិន្នន័យ និង ការបកស្រាយ..........៣៨

៣.៣.១. ទិន្នន័យនៃការប្រៀបធៀបតម្លៃ មធ្យមចំពោះការប្រើប្រាស់បច្ចេកវិទ្យា ឌីជីថលក្នុងវិស័យការងារ..........៣៩

៣.៣.១.១. ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងវិស័យការងារ..........៣៩

៣.៣.១.២. អត្ថប្រយោជន៍នៃការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលរវាងស្ថាប័នរដ្ឋ និង ស្ថាប័នឯកជន..........៣៩

៣.៣.១.៣. ការទទួលបានការបណ្តុះបណ្តាលបច្ចេកវិទ្យាឌីជីថលក្នុងវិស័យការងារ..........៤០

៣.៣.២. ទិន្នន័យនៃការប្រៀបធៀបតម្លៃមធ្យមចំពោះការបណ្តុះបណ្តាលពាក់ព័ន្ធនឹងបច្ចេកវិទ្យាឌីជីថលរបស់យុវជននិង សិស្សានុសិស្ស..........៤១

៣.៣.២.១. អត្ថប្រយោជន៍នៃការបណ្តុះបណ្តាលបច្ចេកវិទ្យាឌីជីថលក្នុងថ្នាក់ និងតាមរយៈអនឡាញ..........៤១

៣.៣.២.២. ការបណ្តុះបណ្តាលបច្ចេកវិទ្យាឌីជីថលតាមទីក្រុង និងតាមបណ្តាខេត្ត..........៤១

៣.៤. លទ្ធផលនៃការស្រាវជ្រាវ..........................................................................................................៤២

៣.៥. ពិភាក្សា..........................................................................................................................................៤២

៣.៥.១. ភាពខ្លាំងនៃការចាប់យកបច្ចេកវិទ្យាឌីជីថលលើមូលធនមនុស្ស............................................៤២

៣.៥.២. ភាពខ្សោយនៃការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងការបណ្តុះបណ្តាល.................................៤៣

៣.៥.៣. ប្រសិទ្ធភាពនៃបច្ចេកវិទ្យាឌីជីថលលើមូលធនមនុស្ស.........................................................៤៤

៣.៥.៤. ផលប៉ះពាល់នៃបច្ចេកវិទ្យាឌីជីថលលើមូលធនមនុស្ស.........................................................៤៤

**សេចក្តីសន្និដ្ឋាន**.......................................................................................................................................៤៥

**អនុសាសន៍**..............................................................................................................................................៤៦

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# បញ្ជីពាក្យកាត់

- ក.ស.ឧ : ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និងសង្គមឌីជីថល
- STEM: Science, Technology, Engineering, and Mathematics
- SME: សហគ្រាសធនតូច និងមធ្យម
- ICT: Information Communication and Technology
- TVET: Technical Vocational Education and Training
- ITC: Institute of Technology of Cambodia

# បញ្ជីក្រាហ្វិក

## ➢ ក្រាហ្វិកដែលបង្ហាញក្នុងវិស័យការងារ


ក្រាហ្វិកទី១៖ ភេទនៃអ្នកចូលរួមស្ទង់មតិ

ក្រាហ្វិកទី២ ៖ ទីតាំងនៃអ្នកចូលរួមស្ទង់មតិ

ក្រាហ្វិកទី៣៖ ប្រភេទស្ថាប័ននៃអ្នកធ្វើការ

ក្រាហ្វិកទី៤៖ ចំនួនមន្ត្រីឬបុគ្គលិកដែលស្គាល់ឬធ្លាប់ឃើញពាក់ព័ន្ធបច្ចេកវិទ្យាឌីជីថល

ក្រាហ្វិកទី៥៖ ការទទួលបានការបណ្តុះបណ្តាលនិងសិក្ខាសាលាអំពីសេដ្ឋកិច្ចឌីជីថល

ក្រាហ្វិកទី៦៖ ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលសម្រាប់បំពេញការងារ

ក្រាហ្វិកទី៧៖ ផលវិបាកនៃអ្នកប្រើប្រាស់បច្ចេកវិទ្យាឌីជីថល

ក្រាហ្វិកទី៨៖ ធនធានមនុស្សដែលមានជំនាញឌីជីថលនៅគ្រប់ស្ថាប័ន

ក្រាហ្វិកទី៩៖ អត្ថប្រយោជន៍នៃបច្ចេកវិទ្យាឌីជីថលនៅគ្រប់ស្ថាប័ន


## ➢ ក្រាហ្វិកដែលបង្ហាញសម្រាប់យុវជន និងសិស្សានុសិស្ស


ក្រាហ្វិកទី១៖ បង្ហាញអំពីភាគរយភេទរបស់អក្នចូលរួមស្ទង់មតិ

ក្រាហ្វិកទី២៖ បង្ហាញអំពីចំនួនភាគរយនៃទីលំនៅស្ថានរបស់អ្នកចូលរួមស្ទង់មតិ

ក្រាហ្វិកទី៣៖ បង្ហាញពីភាគរយនៃកម្រិតសិក្សារបស់អ្នកដែលចូលរួមការស្ទង់មតិ

ក្រាហ្វិកទី៤៖ បង្ហាញពីភាគរយរបស់អ្នកដែលចូលរួមការស្ទង់មតិដែលមានអាជីវកម្ម និង មិនទាន់មានអាជីវកម្ម

ក្រាហ្វិកទី៥៖ ចំនួនភាគរយនៃការយល់ដឹងអំពីបច្ចេកវិទ្យាឌីជីថល

ក្រាហ្វិកទី៦៖ បង្ហាញពីភាគរយរបស់អ្នកដែលចូលរួមការស្ទង់មតិដែលទទួលការបណ្តុះបណ្តាលឌីជីថល

ក្រាហ្វិកទី៧៖ បង្ហាញពីភាគរយរបស់អ្នកដែលចូលរួមការស្ទង់មតិដែលប្រើប្រាស់ឌីជីថល

ក្រាហ្វិកទី៨៖ បង្ហាញពីភាគរយរបស់អ្នកដែលចូលរួមការស្ទង់មតិដែលការសិក្សា និង មុខរបពួកគាត់ទទួលផល ពីឌីជីថល

ក្រាហ្វិកទី៩៖ បង្ហាញពីភាគរយបស់អ្នកដែលចូលរួមការស្ទង់មតិដែលការសិក្សា និង មុខរបរបស់ពួកគាត់ប្រើប្រាស់ឌីជីថល

ក្រាហ្វិកទី១០៖ បង្ហាញពីភាគរយបស់អ្នកដែលចូលរួមការស្ទង់មតិមានមតិចំពោះឌីជីថល

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ក្នុងបរិបទថ្មីនេះ រាជរដ្ឋាភិបាលកំពុងជំរុញ និងពន្លឿនការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដែលជាថ្នាលសម្រាប់ការអភិវឌ្ឍជំនាញឌីជីថល ដល់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញឌីជីថល វិស័យឯកជន សិស្ស និស្សិត និងនិយោជិកឱ្យកាន់តែល្អប្រសើរ។ ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលតម្រូវឱ្យមានការកសាងមូលធនមនុស្សជំនាញឌីជីថលប្រកបដោយសមត្ថភាពឆ្លើយតបទៅនឹងតម្រូវការ គាំទ្រដល់ដំណើរបរិវត្តកម្មឌីជីថលរបស់រដ្ឋាភិបាលធុរកិច្ច និងប្រជាពលរដ្ឋ លើកកម្ពស់វិស័យឌីជីថលនិងភាពប្រកួតប្រជែងរបស់កម្ពុជាក្នុងតំបន់។ ដំណើរការនៃបរិវត្តកម្មឌីជីថលនេះ ត្រូវបានអនុវត្តតាមក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា ២០២១ - ២០៣៥ របស់រាជរដ្ឋាភិបាលកម្ពុជាដែលជាសសរស្តម្ភសម្រាប់ជំរុញធុរជននិងប្រជាពលរដ្ឋឱ្យចាប់យកបច្ចេកវិទ្យាឌីជីថលប្រកបដោយភាពជឿទុកចិត្ត។

ការអភិវឌ្ឍទេពកោសល្យជំនាញឌីជីថសម្រាប់មូលធនមនុស្សនៃប្រធានបទនេះ ផ្តោតសំខាន់ទៅលើការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធឌីជីថលគាំទ្រដល់ការអប់រំឌីជីថល និង ការពង្រឹងសមត្ថភាពរបស់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលក្នុងការរៀបចំកម្មវិធីសិក្សាជំនាញឌីជីថលឱ្យសម្បូរបែប សម្រាប់សិស្ស និស្សិត និងនិយោជិតងាយស្រួលក្នុងការសម្រេចចិត្តជ្រើសរើសជំនាញសិក្សា និង តម្រង់ទិសអាជីពការងារប្រកបដោយភាពច្បាស់លាស់ ដោយកំណត់ពីសមត្ថភាពជំនាញឌីជីថលជាក់លាក់ និងជំនាញទុនតាមមុខរបរនីមួយៗ។ ម្យ៉ាងវិញទៀតមានការលើកកម្ពស់សមត្ថភាពស្រាវជ្រាវ និង នវានុវត្តន៍ដោយការបណ្តុះបណ្តាលធនធានមនុស្សជំនាញឌីជីថល និងជម្រុញការបណ្តុះគំនិតច្នៃប្រឌិត ទេពកោសល្យ ការបង្កើតថ្មី និងមានការបង្កើតធុរកិច្ចថ្មីឌីជីថល និងការស្រាវជ្រាវផ្នែកបច្ចេកវិទ្យាឌីជីថល និងផ្នែកវិទ្យាសាស្ត្រ ស្របតាមតម្រូវការចាំបាច់ក្នុងការធ្វើបរិវត្តកម្មឌីជីថល និងបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤។

ដើម្បីលើកកម្ពស់ការអភិវឌ្ឍជំនាញឌីជីថល ក្នុងក្របខណ្ឌសមត្ថភាពជំនាញឌីជីថល នៅកម្ពុជាប្រកបដោយច្នៃប្រឌិត ក្នុងប្រធានបទនេះនឹងបង្ហាញពីសកម្មភាពនៃដំណើរការការកសាងមូលធនមនុស្សនិងនវានុវត្តន៍ឌីជីថល ដោយយើងធ្វើការស្រាវជ្រាវពីសក្តានុពលនៃបរិវត្តកម្មសេដ្ឋកិច្ច និង សង្គមឌីជីថល និងនវានុវត្តន៍ក្នុងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញឌីជីថល វិស័យឯកជន ស្ថាប័នសាធារណៈ សិស្ស និស្សិត និងនិយោជិត ដែលជាតួអង្គពាក់ព័ន្ធសំខាន់ៗក្នុងបរិវត្តកម្មឌីជីថលនេះ។

## ២. កម្មវត្ថុនៃការសិក្សាស្រាវជ្រាវ

កម្មវត្ថុនៃការសិក្សាស្រាវជ្រាវប្រធានបទនេះ ធ្វើឡើងដើម្បី៖

- ស្វែងយល់អំពីសក្តានុពលនៃបរិវត្តកម្មសេដ្ឋកិច្ច និងសង្គមឌីជីថល និងនវានុវត្តនបច្ចេកវិទ្យាឌីជីថល
- ស្វែងយល់ពីបញ្ហាប្រឈមធនធានមនុស្សកំឡុងពេលកម្ពុជាកំពុងដំណើរការទៅរកសេដ្ឋកិច្ចឌីជីថល

- សិក្សាយុទ្ធសាស្ត្រដាក់ចេញដោយរាជរដ្ឋាភិបាលដើម្បីអភិវឌ្ឍនិងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់ធនធានមនុស្សក្នុងវិស័យនវានុវត្តឌីជីថល
- ស្វែងយល់ពីវឌ្ឍភាព និង កម្រិតនៃស្ថាប័នសាធារណៈ វិស័យឯកជន និងយុវជន ទាក់ទងនឹងចំណេះដឹងនៃជំនាញឌីជីថលនៅក្នុងប្រទេសកម្ពុជា។

## ៣. ចំណោទបញ្ហា

យើងបានសង្កេតឃើញថាការឈានចូលនៃបច្ចេកវិទ្យាឌីជីថលនៅកម្ពុជាយើង គឺមានភាពសុះសាយគួរឱ្យកត់សម្គាល់ ជាមួយគ្នានេះផងដែររាជរដ្ឋាភិបាលក៏បានដាក់ចេញនូវក្របខណ្ឌគោលនយោបាយស្តីពីសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ដែលគាំទ្រនូវបច្ចេកវិទ្យាឌីជីថល ម្យ៉ាងទៀតសម្រាប់ស្ថាប័នរដ្ឋ និង ឯកជនមួយចំនួនគឺបានលើកកម្ពស់ការអនុវត្តវិធីសាស្ត្រឌីជីថល ដើម្បីជួយសម្រួលកិច្ចការងារ និង បង្កើតភាពងាយស្រួលសម្រាប់បុគ្គលិកស្ថាប័នរបស់ពួកគេបានជាច្រើននិងប្រកបដោយសុវត្ថិភាព។ យោងតាមស្ថានភាពបច្ចុប្បន្នរបស់កម្ពុជា គ្រប់បណ្តាស្ថាប័នរដ្ឋ និងវិស័យឯកជន កំពុងធ្វើការអភិវឌ្ឍយុទ្ធសាស្ត្រការងារ និងធ្វើកំណែទម្រង់ថ្មីក្នុងប្រព័ន្ធការងារដោយរួមបញ្ចូលនូវបច្ចេកវិទ្យាឌីជីថល ជាការឆ្លើយតបទៅនឹងក្របខណ្ឌគោលនយោបាយរបស់រដ្ឋាភិបាលដើម្បីទទួលបានភាពរីកចម្រើនក្នុងវិស័យការងារ និងជាស្ពានចម្លងសម្រាប់ឱ្យប្រទេសកម្ពុជាមានកំណើនសេដ្ឋកិច្ចនិងមានភាពប្រកួតប្រជែង។ ស្របពេលជាមួយគ្នានេះដែរ កង្វះធនធានមនុស្សជំនាញឌីជីថល គឺជាឧបសគ្គចម្បងមួយក្នុងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា។ កត្តានេះហើយទើបយើងខ្ញុំបានសម្រេចមូលមតិគ្នាក្នុងការជ្រើសរើសប្រធានបទ ការកសាងមូលធនមនុស្សក្នុងវិស័យនវានុវត្តឌីជីថល មកសិក្សាស្រាវជ្រាវ ដោយលើកឡើងនូវចំណោទបញ្ហាមួយចំនួនដូចជា៖

១. តើការធ្វើបរិវត្តកម្មនៃវិស័យនវានុវត្តឌីជីថលកម្ពុជាផ្តល់អត្ថប្រយោជន៍អ្វីខ្លះ?

២. យោងតាមក្របខណ្ឌគោលនយោបាយស្តីអំពីសេដ្ឋកិច្ច និងសង្គមឌីជីថលរបស់រដ្ឋាភិបាល តើមានយុទ្ធសាស្ត្រអ្វីខ្លះដើម្បីលើកកម្ពស់ធនធានមនុស្សក្នុងវិស័យនវានុវត្តឌីជីថល?

## ៤. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ការកសាងមូលធនមនុស្ស ប្រៀបដូចទៅនឹងការវិនិយោគទៅលើធនធានមនុស្ស ដែលអាចឱ្យមនុស្សចេះប្រើសមត្ថភាពរបស់ខ្លួន ធ្វើអ្វីមួយឱ្យមានផលប្រយោជន៍ និងជួយលើកស្ទួយវិស័យការងារក្នុងប្រទេសកម្ពុជាឱ្យមានកំណើនសេដ្ឋកិច្ច។ ប្រទេសមួយមានធនធានមនុស្សច្រើន មានមូលធនមនុស្សកាន់តែច្រើន មានសុខភាពល្អ និងមានគុណភាព ចំណេះដឹង មានភាពបត់បែន ហើយប្រជាពលរដ្ឋមានសមត្ថភាពខ្ពស់កាន់តែច្រើន នោះវានឹងធ្វើឱ្យមានការប្រកួតប្រជែងរបស់ប្រទេសនោះកាន់តែខ្លាំង។ ប្រាកដណាស់ ការវិវត្តទៅរកសេដ្ឋកិច្ចឌីជីថលរបស់កម្ពុជា ពិតជាសំខាន់ដែលប្រធានបទនេះ ជាប្រធានបទមួយដែលថ្មីសម្រាប់ជាឯកសារស្រាវជ្រាវប្រើប្រាស់ដើម្បីជាការសិក្សាបន្ថែមរបស់យុវជន និងជាចំណេះដឹងសម្រាប់អ្នកចង់ចាប់យកជំនាញថ្មី មកប្រើប្រាស់ក្នុងមុខរបរ អាជីព ការងារ ឬអាជីវកម្មណាមួយជាដើម។ ម៉្យាងវិញទៀតប្រធានបទនេះ រំលេចចេញមកឡើងដោយសារវាមានសារៈប្រយោជន៍ដូចជា៖

- ទុកជាឯកសារស្រាវជ្រាវសម្រាប់យុវជនកម្ពុជាអាចយកមកប្រើប្រាស់ដើម្បីជាការសិក្សាបន្ថែម
- ជាចំណេះដឹងសម្រាប់បុគ្គលណាចង់ចាប់ជំនាញថ្មី មកបណ្តុះបណ្តាលសមត្ថភាពបន្ថែមទុកជាការប្រើប្រាស់ក្នុងមុខរបរអាជីព ការងារ ឬអាជីវកម្មណាមួយជាដើម
- យុវជនកម្ពុជាបានយល់អំពីនវានុវត្តន៍ឌីជីថល ស្របពេលរដ្ឋាភិបាលបានកំពុងតែពង្រឹង និងបង្កើនសមត្ថភាពធនធានមនុស្សនៃជំនាញឌីជីថល
- ជាគន្លឹះសម្រាប់មិត្តអ្នកអាន និងសិស្សានុសិស្សជ្រើសរើសជំនាញត្រឹមត្រូវ យកមកសិក្សាបន្តស្របតាមតម្រូវការទីផ្សារការងារ
- ជួយសម្រួលកិច្ចការឱ្យមានភាពសក្កានុពលជាមួយភាពជឿនលឿនរបស់បច្ចេកវិទ្យាឌីជីថល
- ផ្តល់គំនិតប្រុងប្រយ័ត្នពេលជួបបញ្ហាប្រឈមផ្សេងៗនៃការឈានចូលធ្វើបរិវត្តកម្មឌីជីថល។

លើសពីនេះទៀតអត្ថបទស្រាវជ្រាវនេះបានបង្ហាញពីសក្កានុពលនៃការវិវត្តទៅរកបរិបទថ្មី សេដ្ឋកិច្ចឌីជីថលកម្ពុជា និងស្វែងយល់បានច្រើនពីបញ្ហាប្រឈមផ្សេងៗពាក់ព័ន្ធនឹងជំនាញឌីជីថល។ ក្នុងនាមជាយុវជនកម្ពុជាដែលកំពុងរស់នៅក្នុងបរិបទថ្មី និងធុរកិច្ចថ្មី ហើយបានស្វែងយល់ពីរបកកំហើញនេះមុន គឺពិតជាមានសារៈសំខាន់ណាស់ ដែលបុគ្គលគ្រប់រូបត្រូវមានចំណេះជំនាញពាក់ព័ន្ធនឹងឌីជីថល វាជាការចូលរួមចំណែកដ៏ធំក្នុងការអភិវឌ្ឍប្រទេសជាតិ។

## ៥. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

វិសាលភាពនៃអត្ថបទនេះ សំដៅដល់៖

- វិស័យការងារ មានស្ថាប័នរដ្ឋ និងស្ថាប័នឯកជនមានអាជីវកម្មខ្នាតតូច និងខ្នាតមធ្យម (SMEs)
- យុវជន និស្សិត និងសិស្សានុសិស្ស នៅវិទ្យាល័យ និងសកលវិទ្យាល័យ
- កំណត់ទីតាំងរបស់អ្នកដែលចូលរួមស្ទង់មតិមកពីទីក្រុង ឬទីប្រជុំជន ជនបទ
- ទម្រង់សំណួរនៃការស្ទង់មតិបានធ្វើឡើងក្នុងរាជធានីភ្នំពេញ តាមរយៈអនឡាញ
- ផ្តោតសំខាន់ទៅលើយុទ្ធសាស្ត្រទី៧និងទី៨ របស់រាជរដ្ឋាភិបាលក្នុងដំណើរការនៃការវិវត្តកម្មឌីជីថល ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវប្រធានបទនេះ តម្រូវឱ្យប្រើវិធីសាស្ត្របរិមាណវិស័យ (Quantitative method) ។ ទិន្នន័យទី១(Primary data) ត្រូវបានប្រើក្នុងកិច្ចការស្រាវជ្រាវនេះ។ ទិន្នន័យត្រូវបានប្រមូលតាមរយៈកម្រងសំណួរចំនួន ២១ ដែលក្នុងនោះមានសំណួរបើកមានចំនួន២ និងសំណួរបិទចំនួន១៧។ ចំនួនអ្នកចូលរួមស្ទង់មតិសរុបមានចំនួន ១២៧ នាក់។ ចំនួនសំណាកទាំងអស់នេះប្រមូលតាមរយៈរូបមន្តសមាមាត្រ៖

$n = \frac{Z^2P(1-p)}{e^2}$ , E ជាកម្រិតលំអៀង(Margin Error)

យក Z=1.96 ជាកម្រិតនៃភាពជឿជាក់ 95% និង

យក E=10% , P=0.5 , (1 – P)=0.5 (លទ្ធភាពដែលអាច)

ជំនួសតម្លៃរបស់លក្ខខណ្ឌក្នុងរូបមន្ត យើងបាន n=96 នាំឱ្យចំនួនអង្កេតត្រូវយកចាប់ពី 96 ឡើង ។

នៅក្នុងការស្ទង់មតិយើងប្រមូលទិន្នន័យបានរហូតដល់ ១២៧ ជាចំនួនសមស្របទៅតាមរូបមន្តរបស់ទំហំសមាមាត្រ។

## ៦.១. វិធីសាស្ត្រនៃការប្រមូលទិន្នន័យ

ដោយប្រធានបទស្រាវជ្រាវមានលក្ខណៈទូលំទូលាយ រាល់ទិន្នន័យដែលប្រមូលបាននឹងត្រូវបង្ហាញពីទស្សនៈវិស័យនៃកម្មវត្ថុ និងចំណោទបញ្ហា។ ដូច្នេះក្នុងការស្រាវជ្រាវនេះ ការរៀបចំសំណួរ(Questionnaire) និងការប្រមូលទិន្នន័យគឺបានធ្វើឡើងតាមរយៈការប្រើប្រាស់កម្មវិធី Google Form ដែលជាវិធីសាស្ត្រប្រមូលទិន្នន័យបែបទិន្នន័យបឋម (Primary Data) និងទទួលបានព័ត៌មានអាចទុកចិត្តបាន។ វាជាឧបករណ៍សម្រាប់ប្រមូលទិន្នន័យមានភាពរហ័ស និងងាយស្រួលក្នុងការចែកចាយតាមរយៈលីងផ្ញើទៅកាន់អ្នកចូលរួមស្ទង់មតិតាមរយៈតេឡេក្រាម ហ្វេសបុក ដើម្បីយកទិន្នន័យទាំងនោះមកធ្វើការបកស្រាយ និងវិភាគ។

## ៦.២. វិធីសាស្ត្រនៃការវិភាគទិន្នន័យ

សម្រាប់ទិន្នន័យដែលយើងទទួលបានពីការស្ទង់មតិទាំងអស់យើងបានយកទិន្នន័យទាំងនេះមកធ្វើការចងក្រងជាមួយកម្មវិធី Excel សម្រាប់បង្កើតជាក្រាហ្វផ្សេងៗ ដើម្បីងាយស្រួលនៅ ក្នុងការយកទិន្នន័យមកធ្វើការវិភាគនិងបកស្រាយទិន្នន័យក្នុងនេះមានដូចជា ៖

- វិភាគទិន្នន័យតាមកម្មវិធី IBM SPSS Statistic
- ពិនិត្យមើលភាពញឹកញាប់ (Frequency )
- បង្កើតតារាងវិភាគថ្មី ( Build new model analysis )
- សន្និដ្ឋានលទ្ធផលស្រាវជ្រាវ ( Research result , research finding ,… ) ។

# ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងអត្ថបទស្រាវជ្រាវមួយនេះ យើងបានបែងចែកវាជា ៣ជំពូកធំៗក្នុងនោះជំពូកទី១ បាននិយាយអំពីពាក្យគន្លឹះនៃមូលធនមនុស្ស និង នវានុវត្តន៍ឌីជីថលដែលជាគន្លឹះមួយឈានដល់ការពិពណ៌នា ពីអត្ថប្រយោជន៍ និង បញ្ហាប្រឈមក្នុងដំណើរការឈានទៅរកនវានុវត្តមូលធននៅកម្ពុជា។ ជំពូកទី២ បង្ហាញឱ្យឃើញថាតើដើម្បីឱ្យធនធានមនុស្សមាននូវសម្ថភាពលើជំនាញឌីជីថលតើពួកគេត្រូវត្រៀមលើកត្តាអ្វីខ្លះ ហើយតើធនធានឌីជីថលបានផ្តល់អត្ថប្រយោជន៍ដល់កម្រិតណា ព្រមទាំងបានប្រាប់អំពីមធ្យោបាយទប់ស្កាត់បញ្ហាប្រឈមកំឡុងពេលកម្ពុជាកំពុងអភិវឌ្ឍន៍ធនធានមនុស្សទៅកាន់ជំនាញឌីជីថល ។ ឯជំពូកទី៣ គឺបាននិយាយទាំងស្រុងទៅលើការស្រង់មតិរបស់យើងដែលផ្តោតទៅលើជំនាញឌីជីថល ព្រមទាំងបកស្រាយនូវទិន្នន័យដើម្បីសន្និដ្ឋាន ។

**សេចក្តីផ្តើម ៖**

នៅក្នុងចំណុចសេចក្តីផ្តើមនេះដែរយើងខ្ញុំបានបង្ហាញអំពី លំនាំបញ្ហានៃការស្រាវជ្រាវ, កម្មវត្ថុនៃការស្រាវជ្រាវ , ចំណោទបញ្ហានៃការស្រាវជ្រាវ, សារៈសំខាន់នៃការស្រាវជ្រាវ , ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ , វិធីសាស្ត្រនៃស្រាវជ្រាវ , រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ។

## ជំពូកទី១ ៖ទស្សនៈនានាជុំវិញការកសាងមូលធនមនុស្ស

ក្នុងជំពូកទីមួយនេះដែរយើងបានលើកយកនូវចំណុចសម្ខាន់ៗមួយចំនួនមកសិក្សាគឺមានដូចជា៖ និយមន័យ, និយមន័យមូលធនមនុស្ស, និយមន័យនវានុវត្តន៍ឌីជីថល, សក្តានុពលនៃបរិវត្តកម្មឌីជីថល, សក្តានុពលលើមូលធនមនុស្ស, សក្តានុពលលើនវានុវត្តន៍ឌីជីថល, ទំនាក់ទំនងរវាងធនធានមនុស្ស និង ឌីជីថល, ផលប៉ះពាល់បណ្តាលមកពីបរិវត្តឌីជីថល, ផលប៉ះពាល់ទៅលើសង្គម និង ចំណុចចុងក្រោយគឺ ផលប៉ះពាល់ទៅលើសេដ្ឋកិច្ច ។

## ជំពូកទី ២ ៖ ការត្រៀមខ្លួនរបស់ប្រទេសកម្ពុជាក្នុងការកសាងមូលធនមនុស្សឌីជីថល និង នវានុវត្តន៍ឌីជីថល

### ២. គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២ - ២០៣៥

ចំណុចសំខាន់ៗនៅក្នុងជំពូកទី២នេះមានដូចជាការសិក្សាទៅលើ ចក្ខុវិស័យ, គោលបំណង , យុទ្ធសាស្ត្រទី៧៖ ការកសាងធនធានមនុស្សឌីជីថល, យុទ្ធសាស្ត្រទី៨៖ ការស្រាវជ្រាវ និង នវានុវត្តន៍ឌីជីថល ។

### ៣. ពិនិត្យមើលឯកសារស្រាវជ្រាវនានាពាក់ព័ន្ធនឹងការត្រៀមខ្លួនរបស់យុវជនកម្ពុជាក្នុងវិស័យនវានុវត្តឌីជីថល

ក. ឯកសារស្រាវជ្រាវពីក្រសួងស្ថាប័នពាក់ព័ន្ធនានា

ខ. ឯកសារស្រាវជ្រាវនានាពាក់ព័ន្ធនឹងសេដ្ឋកិច្ច និងសង្គមឌីជីថល

គ. ហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់បរិវត្តកម្មឌីជីថល

ឃ. ទំនុកចិត្ត និង ភាពជឿជាក់លើប្រព័ន្ធឌីជីថល

ង. ពលរដ្ឋឌីជីថល

ច. រដ្ឋាភិបាលឌីជីថល

ឆ. ធុរកិច្ចឌីជីថល

### ៤. ការបញ្ចៀស ការបន្ថយ និង ដំណោះស្រាយផលប៉ះពាល់ និងការគ្រប់គ្រងហានិភ័យ

ចំណុចដែលយើងខ្ញុំបានលើកយកមកបកស្រាយសំខាន់ៗមានដូចជា ៖ ហានិភ័យពាក់ព័ន្ធនឹងមូលធនមនុស្ស និង ហិរញ្ញវត្ថុ , ហានិភ័យពាក់ព័ន្ធនឹងការអភិវឌ្ឍន៍ឆាប់រហ័សនៃបច្ចេកវិទ្យា។

## ជំពូកទី៣ ៖ការវិភាគទិន្នន័យ

ចំពោះការវិភាគទិន្នន័យនេះដែរយើងមានចំណុចសំខាន់ៗដូចជា៖ ការប្រមូលទិន្នន័យ , ពិពណ៌នាទិន្នន័យ , វិភាគទិន្នន័យ , លទ្ធផលស្រាវជ្រាវ , ពិភាក្សា , ចំណុចខ្លាំង ចំណុចខ្សោយ/ចំណុចខ្វះចន្លោះ ,ប្រសិទ្ធផល , ផលប៉ះពាល់ ។

### ចំពោះចំណុចចុងក្រោយនេះបានសិក្សាអំពី

សេចក្ដីសន្និដ្ឋាន, អនុសាសន៍ និង ចុងក្រោយគឺ ឯកសារយោង និង ឧបសម្ព័ន្ធ ។

# ជំពូកទី១

# ទស្សនៈនានាជុំវិញការកសាង
# មូលធនមនុស្ស

# ជំពូកទី១
# ទស្សនៈនានាជុំវិញការកសាងមូលធនមនុស្ស

## ១.១. និយមន័យ

### ១.១.១.និយមន័យមូលធនមនុស្ស

ការកំណត់ន័យនៃពាក្យមួយតែងតែមានការយល់ឃើញមិនដូចគ្នាទេ ព្រោះមនុស្សម្នាក់ៗមានគំនិតផ្សេងគ្នាដែរ។ បើពិនិត្យលើពាក្យ មូលធនមនុស្ស បាន មកពីពាក្យ **មូលធន** និង មនុស្ស ។ ពាក្យ មូលធន មានន័យថា ទ្រព្យដើម ដើមទ្រព្យ ប្រាក់ដើម ដើមទុន។ ពាក្យ មនុស្ស មានន័យ ថា ជនជាអ្នកដឹងការខុសត្រូវ សត្វវិសេសមួយ ប្រភេទដែលមានកាគិតគូ និងមានការវិភាគបានយ៉ាងល្អប្រសើរ ។

ដូច្នេះ មូលធនមនុស្ស សំដៅលើ មនុស្ស ដែលមានតម្លៃជាទ្រព្យសំខាន់របស់ប្រទេសជាតិ ប្រកបដោយសក្តានុពលខាងចំណេះដឹង សមត្ថភាព ជំនាញ បទពិសោធន៍ និងភាពច្នៃប្រឌិតដែលជាធនធានឬជាទុនសម្រាប់អភិវឌ្ឍប្រទេសបាន ។ មូលធនមនុស្ស សំដៅលើបណ្តុំនៃសមត្ថភាព ចំណេះដឹង ជំនាញ បទពិសោធ និងភាព ច្នៃប្រឌិតរបស់មនុស្សដែលអាចផលិតចេញជាតម្លៃសេដ្ឋកិច្ចបាន ។ សរុបរួមជាខ្លឹមកមូលធនមនុស្សត្រូវមានកត្តារួមផ្សំ ៤យ៉ាង សំខាន់ៗរួមមានៈ

១.មានចំណេះដឹង

២.ចំណេះ ធ្វើឬបំណិន

៣.មានឥរិយាបថល្អ

៤.មានសុខ ភាពល្អ ។[1]

### ១.១.២. និយមន័យនវានុវត្តន៍ឌីជីថល

មនុស្សស្ទើរគ្រប់គ្នាសុទ្ធតែបានឮនូវពាក្យថា «នវានុវត្តន៍» ឬជាភាសាអង់គ្លេសថា Innovation ដោយវាត្រូវបានប្រើប្រាស់យ៉ាងទូលាយនៅក្នុងសម័យកាល ដែលពិភពលោកកំពុងដើរឆ្ពោះទៅមុខលើបរិបទឧស្សាហកម្ម ៤.0 ដែលជាបច្ចេកវិទ្យាដ៏វ៉ៃឆ្លាតបំផុតសម្រាប់សម្រួលដល់កិច្ចការងាររីកចម្រើនរបស់ពិភពលោក។ នវានុវត្តន៍ឌីជីថលនៅក្នុងទីផ្សារសកលបច្ចុប្បន្ននេះបានដើរតួយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចទាំងថ្នាក់ជាតិនិងពិភពលោក ប្រសិនបើយើងអាចយកវាមករៀនសូត្រ និង ប្រើប្រាស់បច្ចេកវិទ្យាឲ្យបានច្រើនបំផុតតាមលទ្ធភាពដែលអាចធ្វើទៅបាន ពីព្រោះថាជាក់ស្តែងបណ្តាប្រទេសមហាអំណាចលើពិភពលោកកាន់តែច្រើនឡើងបាននិង កំពុងអនុវត្តកិច្ចការងារនេះយ៉ាងសកម្មរួចទៅហើយព្រមទាំងអាចទាញយកចំណូលសេដ្ឋកិច្ចយ៉ាងធំធេងផងដែរ ។

[1] ការស្វែងយល់ពីមូលធនមនុស្ស , https://panel.racmanagementsystem.academy/royal-academy/research/attachments/original/328.pdf

ជាទូទៅអត្ថន័យរបស់ **នវានុវត្តន៍ឌីជីថល** គឺសំដៅទៅលើការអនុវត្តផលិតផលនៃការច្នៃប្រឌិត ឬការបង្កើតគំនិតថ្មីៗទាំងឡាយ ដែលភាគច្រើនពាក់ព័ន្ធទៅនឹងការប្រើប្រាស់បច្ចេកវិទ្យា ការប្រើប្រាស់វិទ្យាសាស្ត្រ ឬការប្រើប្រាស់ព័ត៌មានវិទ្យាជាដើម។

និយាយជារួម នវានុវត្តឌីជីថល គឺជាផ្នែកមួយដ៏សំខាន់នៅក្នុងសកលភាវូបនីយកម្ម ពីព្រោះនៅពេលដែលប្រទេសណាដែលមានការបង្កើនសកម្មភាពផ្សព្វផ្សាយ និងលើកកំពស់ខ្លាំងចំពោះកិច្ចការងារនេះវានឹងជួយឲ្យបណ្ដាប្រទេសទាំងនោះទទួលបាននូវភាពប្រកួតប្រជែងខ្លាំងជាងមុនផងនិងទទួលបានការវិនិយោគច្រើនជាងមុនផង ក៏ដូចជាការត្រៀមខ្លួនបានកាន់តែល្អប្រសើរជាងមុនផងចំពោះមុខលើបញ្ហាប្រឈម និងវិបត្តិសកលនានាចាប់រាប់តាំងពីវិបត្តិសេដ្ឋកិច្ច, វិបត្តិសង្គម និងវិបត្តិបរិស្ថានផងដែរ។[2]

## ១.២. សក្ដានុពលនៃបរិវត្តកម្មឌីជីថល

ការធ្វើបរិវត្តកម្មឌីជីថល ជាការចាប់យក និងទាញយកផលប្រយោជន៍ជាអតិបរមាពីការរីកចម្រើននៃបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា និងបច្ចេកវិទ្យាឌីជីថល ដើម្បីគាំទ្របដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤ ដែលបង្កើនផលិតភាព ជំរុញកំណើនសេដ្ឋកិច្ចជាតិ និងកសាងសង្គម និងសេដ្ឋកិច្ចឌីជីថល ដែលផ្តល់ផលប្រយោជន៍ដល់ពលរដ្ឋឌីជីថល និងជាកាតាលីករនៃការជំរុញការអភិវឌ្ឍឱ្យមានកំណើនសេដ្ឋកិច្ចខ្ពស់ជាលំដាប់។

### ១.២.១. សក្ដានុពលលើមូលធនមនុស្ស

កម្ពុជារំពឹងថា នឹងជំរុញឱ្យមូលធនមនុស្សមានការចាប់យកវិស័យឌីជីថលជាមូលដ្ឋាន ដើម្បីគាំទ្រដល់ការអភិវឌ្ឍ ការអប់រំឌីជីថល ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងការជំរុញកំណើនសេដ្ឋកិច្ច ដោយទទួលបានការបណ្តុះបណ្តាលជំនាញឌីជីថលសម្បូរបែប និងទូលំទូលាយ ដែលមានការចូលរួមពីមូលធនមនុស្សទាំងអស់។ ជាពិសេសបុគ្គលគ្រប់រូប អាចប្រើប្រាស់នូវបច្ចេកវិទ្យាឌីជីថល ក្នុងការប្រាស្រ័យទាក់ទងគ្នារវាង បុគ្គល ក្រុមគ្រួសារ សហគមន៍, ការចូលរួមចំណែកបម្រើឱ្យសកម្មភាពសង្គម និងការទទួលបានសេវាសាធារណៈ ដោយគ្មានការរើសអើង។

**ការទទួលបានសេវាសង្គមកាន់តែងាយស្រួល និង ទូលំទូលាយ តាមរយៈថ្នាលបច្ចេកវិទ្យាឌីជីថល៖**

មូលធនមនុស្សបាននឹងកំពុងប្រើប្រាស់ថ្នាលបច្ចេកវិទ្យាឌីជីថល ដើម្បីទទួលបានសេវាសាធារណៈ ដោយយុវជន សិស្សានុសិស្សអាចទាញយកព័ត៌មាន និងទិន្នន័យ ឯកសារស្រាវជ្រាវ លើបណ្តាញសង្គម (Social Media) យ៉ាងងាយស្រួល។ បច្ចុប្បន្នគ្រប់គ្រឹះស្ថានអប់រំសាធារណៈ និងគ្រឹះស្ថានអប់រំឯកជន បានបង្កើតនិងកែលម្អកម្មវិធីសិក្សាជំនាញឌីជីថលយ៉ាងសម្បូរបែបសម្រាប់បណ្តុះបណ្តាល ជាមួយបច្ចេកវិទ្យាថ្មីៗ ដើម្បីលើកកម្ពស់អក្ខរកម្មឌីជីថលសម្រាប់សិស្សានុសិស្ស យុវជនអាចជ្រើសរើសជំនាញមកសិក្សាដើម្បីពង្រឹងសមត្ថភាពជំនាញ ក្នុងការបម្រើការងារគ្រប់វិស័យ។ រីឯការសរសេរអត្ថបទ និងការចែករំលែកចំណេះដឹង សព្វថ្ងៃ

[2] AMS ECONOMY (https://economy.ams.com.kh/start-up-innovation/news/understand-what-is-innovation-and-how-important-is-it/)

មានបុគ្គលមួយចំនួនដែលមានសមត្ថភាពជំនាញឌីជីថលបានធ្វើការបង្កើតមាតិកាធ្វើជាវីដេអូនិយាយ ដើម្បីជាការចែករំលែកចំណេះដឹងពាក់ព័ន្ធនឹងអក្ខរកម្មឌីជីថល បច្ចេកវិទ្យាឌីជីថល និងក៏មានការសរសេរជាអត្ថបទសម្រាប់ជាឯកសារងាយស្រួលក្នុងការស្រាវជ្រាវនៅលើបណ្តាញសង្គមសាធារណៈ។ ម្យ៉ាងទៀតបុគ្គលគ្រប់រូបអាចស្វែងរកការងារពីការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដូចជាការធ្វើអាជីវកម្មតាមអនឡាញ ការធ្វើទីផ្សារផ្សព្វផ្សាយនៅលើបណ្តាញសង្គមជាដើម ដើម្បីបង្កើតអតិថិជន វាជាការងារមួយអាចធ្វើសម្រាប់អាជីវកម្មផ្ទាល់ខ្លួន និងសម្រាប់វិស័យឯកជននានាដែលគេត្រូវការធនធានមនុស្សជំនាញឌីជីថលមកធ្វើការ។ នៅមានការងារជាច្រើនទៀតដែលសង្គមកម្ពុជាកំពុងត្រូវការធនធានមនុស្សមានជំនាញឌីជីថលមកធ្វើការ និង ជាឱកាសសម្រាប់យុវជនបង្ហាញពីទេព្យកោសល្យផ្ទាល់ខ្លួន ដែលទទួលបានចំណេះដឹងពីការបណ្តុះបណ្តាលជំនាញឌីជីថលនិងមានភាពងាយស្រួលក្នុងការកសាងបណ្តាញសម្រាប់ទំនាក់ទំនងទាំងនៅក្នុងប្រទេស និង ក្រៅប្រទេស។

**ការពង្រឹងទំនាក់ទំនង និង ការចែករំលែកក្នុងសង្គម កាន់តែស៊ីជម្រៅ**

បុគ្គលម្នាក់ៗចាប់ផ្តើមមានទំនាក់ទំនង, ការផ្សារភ្ជាប់គ្នាទៅវិញទៅមក និងមានអន្តរសកម្មកាន់តែស្និទ្ធស្នាល និង បើកចំហដោយពុំខ្វល់ខ្វាយពីភាពខុសគ្នានៃឋានៈសង្គម ភូមិសាស្ត្រ ភេទ សាសនា និងជាតិសាសន៍ឡើយ។ នៅក្នុងបរិការណ៍នេះ ឧបករណ៍ឆ្លាត ជាពិសេសឧបករណ៍ចល័ត គួបផ្សំនឹងវិសាលភាពនៃការតភ្ជាប់បណ្តាញ និងសេវាទូរគមនាគមន៍ក្នុងតំបន់នីមួយៗ គឺជាកត្តាកំណត់ការតភ្ជាប់បណ្តាញសង្គមឌីជីថលជាពិសេសការកសាងមូលធនមនុស្សជំនាញឌីជីថលផ្ទាល់ ដើម្បីទាញយកអត្ថប្រយោជន៍ពីសកលភាវូបនីយកម្មឌីជីថលទៅតាមធនធានដែលមាន។ សម្រាប់កម្ពុជាចំនួនការតភ្ជាប់អ៊ីនធឺណិតតាមឧបករណ៍ចល័ត ជាពិសេសទូរស័ព្ទចល័ត មានរហូតដល់ ១២៨% នៃប្រជាជនសរុប ដែលភាគច្រើនជាអ្នកប្រើប្រាស់ថ្នាលបច្ចេកវិទ្យាឌីជីថល ឬប្រព័ន្ធសង្គម។ តួលេខនេះបានបង្ហាញពីការចូលរួមរបស់ប្រជាពលរដ្ឋកម្ពុជាកាន់តែសកម្ម និងទូលំទូលាយ ក្នុងសង្គមឌីជីថល ដោយបានប្រែក្លាយជាសកម្មភាពនៃជីវភាពប្រចាំថ្ងៃ។

**ការទទួលបានសេវាសាធារណៈឌីជីថល និងព័ត៌មានទូទៅពីស្ថាប័នរដ្ឋនិងឯកជនស្របតាមតម្រូវការៈ**

សេវាឌីជីថលផ្សេងៗ រួមមានដូចជា ការទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិច(អនឡាញ) ភាពទូលំទូលាយនៃការទទួលបានការណែនាំនិងបណ្តុះបណ្តាលពីអក្ខរកម្មឌីជីថលដល់យុវជនគ្រប់រូប និងការបំពេញតម្រូវការមូលដ្ឋានដទៃទៀតតាមមធ្យោបាយឌីជីថល ត្រូវបានសង្កេតឃើញថាបាននឹងកំពុងចាប់ផ្តើមជ្រៀតចូលក្នុងសង្គមបន្តិចម្តងៗ ជាពិសេស ក្នុងបរិការណ៍នៃការរីករាលដាលនៃជំងឺកូវីដ- ១៩ កន្លងមក។ ក្នុងពេលបច្ចុប្បន្នយុវជនកម្ពុជាមានទំនោរខ្ពស់ទៅរកការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលជាមួយទូរស័ព្ទចល័ត កុំព្យូទ័រ និងទូរទស្សន៍ឌីជីថលសម្រាប់ប្រើប្រាស់ក្នុងការទស្សនាតាមបណ្តាញសង្គមដែលមានកម្មវិធីផ្សព្វផ្សាយជាច្រើន និង ការប្រើប្រាស់សេវាអ៊ីនធឺណិតសម្រាប់ធ្វើការទំនាក់ទំនងក្នុងការសិក្សា និង ការងារមានដូចជា Telegram, Messenger, Facebook, Instagram ជាដើម ដើម្បីសម្រួលដល់ជីវភាពរស់នៅប្រចាំថ្ងៃនិងក្នុងការទទួលបាននូវព័ត៌មានសង្គម និងព័ត៌មានសេដ្ឋកិច្ចពាណិជ្ជកម្មទាំងក្នុងនិងក្រៅប្រទេសបានឆាប់រហ័ស។

### ១.២.២. សក្តានុពលលើនវានុវត្តន៍ឌីជីថល

កម្ពុជានឹងជំរុញវិស័យបច្ចេកវិទ្យាព័ត៌មាន និង ទូរគមនាគមន៍ (ITC) ក្នុងសម្ទុះ និង ល្បឿនថ្មី ដោយចាប់យកវិស័យឌីជីថលជាមូលដ្ឋាន ដើម្បីចាប់យកកាលានុវត្តភាពថ្មីៗផង និង ជំរុញផលិតភាពប្រសិទ្ធភាព និងការប្រកួតប្រជែងសេដ្ឋកិច្ចផង។ សក្តានុពលសំខាន់ៗ រួមមាន៖

**ការតភ្ជាប់នឹងខ្សែច្រវាក់ផលិតកម្ម និង ខ្សែច្រវាក់តម្លៃតំបន់ និងសកល៖** ផលិតកម្មក្នុងស្រុកនឹងស្ថិតក្នុងវិសាលភាពទូលំទូលាយគ្មានព្រំដែននៃបច្ចេកវិទ្យាឌីជីថល និង សម្រេចបាន តាមនិន្នាការសកលភាវូបនីយកម្ម តាមរយៈការតភ្ជាប់ទៅនឹងខ្សែច្រវាក់តម្លៃតំបន់ និង សកល។ ជាពិសេស ការតភ្ជាប់សហគ្រាសធុនតូច និង មធ្យម (SMEs) ទៅក្នុងខ្សែច្រវាក់ផលិតកម្មតំបន់ និង សកល ត្រូវបានរំពឹងថា នឹងក្លាយជាមូលដ្ឋានដ៏រឹងមាំក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ច។

**ការជំរុញសកម្មភាពពាណិជ្ជកម្ម និង ធុរកិច្ច៖** ប្រសិទ្ធភាពនៃប្រតិបត្តិការទិញ-លក់ទំនិញ និង សេវា ជាពិសេស ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច តាមរយៈការទូទាត់កាន់តែងាយស្រួល និង រហ័ស គួបផ្សំនឹងការដឹកជញ្ជូនលឿន និង មានតម្លៃសមរម្យ នឹងត្រូវបានលើកកម្ពស់ ។ បន្ថែមលើនេះ ការគ្រប់គ្រងអាជីវកម្ម និងផលិតកម្ម នឹងកាន់តែមានប្រសិទ្ធភាព ដោយសារការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល បូកផ្សំនឹងកម្លាំងពលកម្មប្រដាប់ដោយជំនាញ ។ ជាមួយគ្នានេះ ការរៀបចំពិព័រណ៍តាមប្រព័ន្ធអេឡិចត្រូនិក និងការរៀបចំថ្នាលសម្រាប់ដាក់លក់ និង ផ្សព្វផ្សាយផលិតផល ដើម្បីជំរុញការនាំចេញ និង ការផ្សារភ្ជាប់ទីផ្សារឱ្យដល់អតិថិជនចុងក្រោយក៏អាចប្រព្រឹត្តទៅបានតាមបច្ចេកវិទ្យាឌីជីថល។

**ការបង្កើតការងារ ជំនាញ និង ការវិនិយោគ៖** ការងារ និង កម្រិតជំនាញ ត្រូវបានរំពឹងថា នឹងកើនឡើងដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃទីផ្សារ តាមរយៈយន្តការរដ្ឋ តួយ៉ាង បច្ចុប្បន្នមានកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈដល់យុវជន សិស្សានុសិស្ស នៅគ្រឹះស្ថានអប់រំទាំងសាធារណៈ និង ឯកជន និងការបណ្តុះបណ្តាលជំនាញបន្ថែមដល់មន្ត្រី និងបុគ្គលិកផងដែរ។ ជាមួយគ្នានេះ ការលើកកម្ពស់សហគ្រិនភាព និង នវានុវត្តន៍ នឹងរួមចំណែកក្នុងការបង្កើតធុរកិច្ចថ្មី និង ការទាក់ទាញការវិនិយោគ នៅក្នុងស្រុក និង ក្រៅស្រុក នៅក្នុងវិស័យ ICT ។

**ការបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ៖** សម្រាប់វិស័យសាធារណៈ ការផ្តល់សេវាសាធារណៈត្រូវបានរំពឹងថា នឹងមានប្រសិទ្ធភាពកាន់តែប្រសើរ និងតម្លាភាពកាន់តែខ្ពស់ តាមរយៈការទទួលយកផ្នត់គំនិតឌីជីថល និង ការលើកកម្ពស់សមត្ថភាពមូលធនមនុស្សក្នុងការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ ។ និន្នាការនេះក៏បានបង្កើនឱកាសសម្រាប់ការដោះស្រាយបញ្ហាជារចនាសម្ព័ន្ធ នៅក្នុងវិស័យប្រពៃណី រួមទាំងវិស័យសេដ្ឋកិច្ចសង្គម និង សន្តិសុខ ។[3]

[3] ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍, ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ , https://mptc.gov.kh/2021/05/%E1%9E%80%E1%9F%92%E1%9E%9A%E1%9E%94%E1%9E%81%E1%9E%8E%E1%9F%92%E1%9E%8C%E1%9E%82%E1%9F%84%E1%9E%9B%E1%9E%93%E1%9E%99%E1%9F%84%E1%9E%94%E1%9E%B6%E1%9E%99%E1%9E%9F%E1%9F%81%E1%9E%8A%E1%9F%92%E1%9E%8B/

## ១.៣. ទំនាក់ទំនងរវាងធនធានមនុស្ស និង ឌីជីថល

យោងតាមនិយមន័យនៃមូលធនមនុស្ស និងឌីជីថលខាងលើ បង្ហាញឱ្យឃើញថា ធនធានមនុស្សឌីជីថល សំដៅទៅលើធនធានមនុស្សដែលមានចំណេះ ជំនាញឌីជីថលទៅលើការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិច រួមជាមួយប្រព័ន្ធអ៊ីនធឺណិតក្នុងជីវភាពប្រចាំថ្ងៃ។

បច្ចុប្បន្នភាពនេះ ធនធានមនុស្សបានបង្កើត និងប្រើប្រាស់ឧបករណ៍អេឡិចត្រូនិចទំនើប ថ្មីៗជាច្រើនទាំងក្នុងវិស័យសុខាភិបាល វិស័យអប់រំ វិស័យអាជីវកម្ម វិស័យការងារ។ល។ ម្យ៉ាងវិញទៀត គេសង្កេតឃើញថា ឧបករណ៍អេឡិចត្រូនិច ឬ ឧបករណ៍ឌីជីថល ដែលពេញនិយមប្រើប្រាស់ជាងគេនោះគឺ ទូរស័ព្ទដៃ និង កុំព្យូទ័រ ទាំងពីរនេះបានផ្តល់តម្រូវការជាច្រើនសម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃ ព្រោះសព្វថ្ងៃនេះមនុស្សបានភ្ជាប់ខ្លួនទៅនឹងឧបករណ៍ទាំងនោះយ៉ាងស្អិតរមួតសម្រាប់តម្រូវការផ្សេងៗរបស់ពួកគេ ដែលហោចណាស់ក្នុងមនុស្សម្នាក់មានឧបករណ៍អេឡិចត្រូនិចទាំងនេះចំនួនមួយ ក្នុងការប្រើប្រាស់ទៅលើ ការសិក្សា ការប្រកបមុខរបរអាជីវកម្ម ការបំពេញការងារ ការប្រាស្រ័យទាក់ទងគ្នាជាដើម ។

សរុបមកទំនាក់ទំនងរវាងមនុស្ស និង បច្ចេកវិទ្យាឌីជីថលមានភាពស្វាហាប់ និង មានភាពស្មុគស្មាញ ដែលវាជះឥទ្ធិពលទាំងវិជ្ជមាន និង អវិជ្ជមានដូចគ្នា ។

## ១.៤. ផលប៉ះពាល់បណ្តាលមកពីបរិវត្តឌីជីថលសេដ្ឋកិច្ច

ផលប៉ះពាល់ដែលបណ្តាលមកពីបរិវត្តឌីជីថល វាបណ្តាលមកពីការកំណែទម្រង់ឬការបង្កើតទម្លាប់ថ្មីៗ ដែលវាបានបំផ្លាញនូវទម្លាប់ចាស់ៗ ដែលវាបណ្តាលពីវត្តមានបច្ចេកវិទ្យាទំនើបទាំងផ្នែកសេដ្ឋកិច្ច និង ផ្នែកសង្គម។[4]

### ១.៤.១. ផលប៉ះពាល់ទៅលើសង្គម

នៅក្នុងវិស័យសង្គម ការកសាងសង្គមឌីជីថលបង្កឱ្យមានផលប៉ះពាល់មួយចំនួន ដែលកើតមានឡើងដូចជា៖

- **ផលប៉ះពាល់ដល់វប្បធម៌ និង ប្រពៃណី និង ការប្រាស្រ័យទាក់ទង៖**

ការជ្រាបចូលនៃវប្បធម៌ និង ប្រពៃណីដទៃ តាមរយៈបច្ចេកវិទ្យាឌីជីថលអាចជះឥទ្ធិពលមកលើវប្បធម៌ និង ប្រពៃណីពីបុរាណរបស់កម្ពុជាដែលអាចបង្កឱ្យមានប្រតិកម្មសង្គម បើមិនមានការគិតគូរលើវិធានការជាក់លាក់ ។

---

[4] ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍, ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ , https://mptc.gov.kh/2021/05/%E1%9E%80%E1%9F%92%E1%9E%9A%E1%9E%94%E1%9E%81%E1%9E%8E%E1%9F%92%E1%9E%8C%E1%9E%82%E1%9F%84%E1%9E%9B%E1%9E%93%E1%9E%99%E1%9F%84%E1%9E%94%E1%9E%B6%E1%9E%99%E1%9E%9F%E1%9F%81%E1%9E%8A%E1%9F%92%E1%9E%8B/

ជាមួយគ្នានេះ ឧបករណ៍ឌីជីថលកំពុងផ្លាស់ប្តូររបៀប ឬ បែបបទនៃការប្រាស្រ័យទាក់ទង រួមមានជាអាទិ៍ការផ្សព្វផ្សាយ ការកម្សាន្ត ការទទួលបាននូវចំណេះដឹង ការប្រកបអាជីវកម្ម ។ ទន្ទឹមនេះ ការចំណាយពេលច្រើនជាមួយនឹងបច្ចេកវិទ្យា ខណៈចំណាយពេលតិចក្នុងការប្រាស្រ័យទាក់ទងផ្ទាល់ជាមួយគ្នា នៅផ្ទះ កន្លែងធ្វើការ សាលារៀន និង ទីសាធារណៈ ជាដើម អាចនាំឱ្យមានការថមថយបំណិនសង្គម ជាពិសេសនាំមកនូវ ផលលំបាកក្នុងការទំនាក់ទំនងជាមួយនឹងអ្នកដទៃ និង ការធ្លាក់ចុះនៃសីលធម៌ក្នុងការប្រាស្រ័យទាក់ទង ។ ជាលទ្ធផល ផលប៉ះពាល់ទាំងនេះក៏អាចបង្កជាហានិភ័យធ្ងន់ធ្ងរដល់អត្តសញ្ញាណជាតិ ។

- **ការបាត់បង់ឯកជនភាពនៃទិន្នន័យផ្ទាល់ខ្លួន** ( **Personal Data Privacy** ) **និង ព័ត៌មានមិនពិត និង ព័ត៌មានក្លែងក្លាយ** ( **Misinformation and Fake News** )៖

ទិន្នន័យផ្ទាល់ខ្លួនកាន់តែច្រើនកំពុងត្រូវបាន ប្រមូល និង ដោះដូរ ជាពិសេសតាមរយៈប្រព័ន្ធអ៊ីនធឺណិតនៃវត្ថុ ខណៈដែល បុគ្គលជាម្ចាស់ទិន្នន័យមិនបានដឹង ឬ មិនអាចគ្រប់គ្រងលំហូរទិន្នន័យនេះបាន ដោយការប្រើប្រាស់កម្មវិធី ឬ ឧបករណ៍ឌីជីថល ដូចជា ការប្រើប្រាស់បច្ចេកវិទ្យាសម្គាល់មុខ ការធ្វើអន្តរកម្ម លើប្រព័ន្ធសង្គម, ការប្រើប្រាស់ម៉ាស៊ីនស្វែងរក និង ការប្រើប្រាស់ឧបករណ៍ឆ្លាត ផ្សេងៗ ។ ជាមួយគ្នានេះ ក្រុមហ៊ុនគ្រប់គ្រងប្រព័ន្ធ និង បច្ចេកវិទ្យាទាំងនោះ អាចតាមដានរាល់ប្រតិបត្តិការ និង ទំនាក់ទំនងដែលកើតមានឡើង នៅលើប្រព័ន្ធ និង បច្ចេកវិទ្យារបស់ខ្លួន ដែលនេះជាការរំលោភបំពាន លើឯកជនភាព របស់អ្នកប្រើប្រាស់ ។ បន្ថែមពីលើនេះ ការចែកចាយព័ត៌មាន មិនពិត និង ព័ត៌មានក្លែងក្លាយតាមប្រព័ន្ធ គឺជាបញ្ហាដ៏ធំមួយ ដែលធ្វើឱ្យអ្នកប្រើប្រាស់ទទួលបាន ព័ត៌មានមិនច្បាស់លាស់ និង បង្កឱ្យមានការភាន់ច្រឡំ ដែលបណ្តាលឱ្យមានការខាតបង់ទាំងពេលវេលា និង ថវិកា ព្រមទាំងប៉ះពាល់ដល់សតិអារម្មណ៍របស់ប្រជាពលរដ្ឋទូទៅ ឬ អាចបង្កជាការបែកបាក់ ចលាចល ឬ បាតុភាពក្នុងសង្គម ។

- **ឧក្រិដ្ឋកម្ម និង ការគំរាមកំហែងតាមប្រព័ន្ធ ៖**

ឧបករណ៍ដែល បានភ្ជាប់ជាមួយនឹងប្រព័ន្ធអ៊ីនធឺណិតអាចជាគោលដៅសម្រាប់ការប្រព្រឹត្តឧក្រិដ្ឋកម្មតាមរយៈការហេកទិន្នន័យរបស់ឯកជនភាពជាដើម ។ ឧក្រិដ្ឋជនអាចចូលទៅមើល លួច ឬ ក្លែងបន្លំព័ត៌មានសំខាន់ៗ របស់បុគ្គល ឬ អង្គភាព ក្នុងរូបភាព ជាអាទិ៍ ការរំលោភបំពានលើឯកជនភាព, ការលួចអត្តសញ្ញាណ ការក្លែងបន្លំ អត្តសញ្ញាណ ។ ឧក្រិដ្ឋកម្មទាំងអស់នេះអាចមានផលប៉ះពាល់ដល់សុវត្ថិភាពរបស់អ្នក ប្រើប្រាស់ប្រព័ន្ធឌីជីថល ទាំងផ្នែកហិរញ្ញវត្ថុ និង ផ្ទាល់ខ្លួន ព្រមទាំងអាចបណ្តាលឱ្យបាត់បង់ភាពជឿជាក់ពី សំណាក់អ្នកប្រើប្រាស់ ។ បន្ថែមពីលើនេះ ការវាយប្រហារមកលើបុគ្គលឯកជន តាមរយៈការផ្ញើសារគំរាម ដោយផ្ទាល់ ឬ ដោយប្រយោល ដែលអាចប៉ះពាល់ដល់សតិអារម្មណ៍ និង អាចបង្កជាហានិភ័យដល់សុខភាព ផ្លូវចិត្ត និង ផ្លូវកាយ គឺជាផលវិបាកនៃការគំរាមកំហែងតាមប្រព័ន្ធ ។

### ១.៤.២. ផលប៉ះពាល់នៅលើសេដ្ឋកិច្ច ៖

នៅក្នុងវិស័យសេដ្ឋកិច្ច ការទទួលយកបច្ចេកវិទ្យាឌីជីថល បង្កឱ្យមានផលប៉ះពាល់មួយចំនួន ដូចខាងក្រោម៖

- **ការផ្លាស់ប្តូររចនាសម្ព័ន្ធកម្លាំងពលកម្ម និង ការងារ៖**

ការងារបែបប្រពៃណីមួយចំនួនអាចប្រឈម ខ្ពស់នឹងការបាត់បង់ ខណៈសេដ្ឋកិច្ចឌីជីថលនឹងបង្កើតប្រភេទការងារថ្មីដែលទាមទារឱ្យមានចំណេះដឹង និង ជំនាញខ្ពស់ជាងមុន ជាពិសេសជំនាញឌីជីថល ។ ជាមួយគ្នានេះ ចរន្តឌីជីថលអាចនាំមកនូវការផ្លាស់ប្តូរ របៀបធ្វើការងារ, ការជំនួសការងារដោយម៉ាស៊ីនស្វ័យប្រវត្តិ និងគ្រឿងយន្ត, ការបង្រួញខ្សែច្រវាក់ផលិតកម្ម និង ការរីកកាន់តែធំនៃគម្លាតឌីជីថល ក្នុងចំណោមតួអង្គពាក់ព័ន្ធ ។ ក្នុងន័យនេះ កម្លាំង ពលកម្មដែលមានសមត្ថភាពសម្របនឹងចរន្តឌីជីថល នឹងទទួលបានអត្ថប្រយោជន៍ ចំណែកឯអ្នកដែលមិន អាចសម្របខ្លួនបានប្រឈមនឹងការបាត់បង់ការងារ ដែលនាំទៅរកស្ថានភាពគ្មានការងារធ្វើនៅក្នុងវិស័យ មួយចំនួន ឬ និកម្មភាពរចនាសម្ព័ន្ធ។ ជាក់ស្តែង សេដ្ឋកិច្ចឌីជីថលហាក់ចាប់បង្ខំប្រភេទពលកម្មដែលគ្មានជំនាញឬជំនាញទាបឱ្យចាប់យកជំនាញឌីជីថលកម្រិតមូលដ្ឋានដើម្បី រក្សាការងារ ឬ មុខរបរទាំងនោះ ។

**ឧទាហរណ៍៖** អ្នករត់ម៉ូតូឌុប ឬ អ្នកបើកឡាន៉កកង់បីត្រូវចេះប្រើប្រាស់កម្មវិធី (Application) ដូចជា កម្មវិធីផែនទី, ការទូទាត់តាមប្រព័ន្ធធនាគារ រីឯពាណិជ្ជករ ឬ អាជីវករខ្នាតតូច ត្រូវចេះប្រើប្រាស់កុំព្យូទ័រ និង ទូរស័ព្ទឆ្លាតក្នុងការលក់ទំនិញ ឬ សេវាតាមប្រព័ន្ធអេឡិចត្រូនិក និង ទទួលយក ការទូទាត់សងប្រាក់តាមប្រព័ន្ធធនាគារ ។ ជាងនេះទៅទៀត ការវិវឌ្ឍ និង ភាពប្រកួតប្រជែងគ្នានៃបច្ចេកវិទ្យា ឌីជីថល នឹងបង្កើតឱ្យមានការផ្ទេរនូវចំណេះដឹង និង ជំនាញជាច្រើន ប៉ុន្តែក៏នឹងធ្វើឱ្យមានគម្លាតឌីជីថល រីកកាន់តែធំ ដោយអ្នកដែលមានលទ្ធភាពទាប និងឱកាសតិចតួចមិនអាចប្រកួតប្រជែងក្នុងទីផ្សារការងារបាន ។

- **ការប្រែប្រួលមូលដ្ឋាននៃការប្រមូលចំណូលពន្ធ៖**

ការធ្វើបរិវត្តកម្មឌីជីថលក្នុងសេដ្ឋកិច្ច រំពឹងថានឹងបង្កើន កាលានុវត្តភាពនៃចំណូលពន្ធរបស់រាជរដ្ឋាភិបាល តាមរយៈការជំរុញ និង ការបង្កើតនូវសកម្មភាពសេដ្ឋកិច្ច ។ ទោះជាយ៉ាងនេះក្តី ការណ៍នេះក៏អាចបង្កើតជាបច្ច័យអវិជ្ជមានមួយចំនួនដល់ការប្រមូលចំណូលសារពើពន្ធ ក្នុងរូបភាពជា៖

១. ការបាត់បង់ចំណូលពន្ធ និង មូលដ្ឋានពន្ធ ដោយសារអវត្តមានរូបវន្តបុគ្គល/អាជីវកម្ម ក្នុងស្រុក ព្រោះថាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកពុំមានដែនកំណត់ឡើយ
២. ការ កំណត់និយមន័យចំណូលមិនទាន់មានភាពច្បាស់លាស់ ខណៈពុំទាន់មាន យន្តការល្អប្រសើរក្នុងការដោះស្រាយបញ្ហាប្រឈមដែលកើតមាន

៣. យន្តការប្រមូលអាករលើតម្លៃ បន្ថែមមិនទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយ និង មិនទាន់មានប្រសិទ្ធភាពខ្ពស់ ក្នុងបរិការណ៍នៃពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិក ។[5]

[5] ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍, ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ , https://mptc.gov.kh/2021/05/%E1%9E%80%E1%9F%92%E1%9E%9A%E1%9E%94%E1%9E%81%E1%9E%8E%E1%9F%92%E1%9E%8C%E1%9E%82%E1%9F%84%E1%9E%9B%E1%9E%93%E1%9E%99%E1%9F%84%E1%9E%94%E1%9E%B6%E1%9E%99%E1%9E%9F%E1%9F%81%E1%9E%8A%E1%9F%92%E1%9E%8B/

# ជំពូកទី២

# ការត្រៀមខ្លួនរបស់កម្ពុជាក្នុងការ កសាងមូលធនមនុស្សឌីជីថល និង នវានុវត្តន៍

# ជំពូកទី២

# ការត្រៀមខ្លួនរបស់កម្ពុជាក្នុងការកសាងមូលធនមនុស្សឌីជីថល និង នវានុវត្តន៍

តាមការវាយតម្លៃជាអន្តរជាតិ ការត្រៀមខ្លួនរបស់កម្ពុជាក្នុងការចាប់យកវិស័យឌីជីថល នៅមានកម្រិត។ ជាក់ស្តែងសម្រាប់កត្តាជំរុញការត្រៀមខ្លួនលើផ្នែកការអភិវឌ្ឍធនធានមនុស្ស ការចាប់យកបច្ចេកវិទ្យា ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា និង ការកែសម្រួលបរិយាកាសធុរកិច្ច នៅមិនទាន់មានភាពល្អប្រសើរ និង ភាពប្រកួតប្រជែងនៅឡើយ។ តែទោះជាយ៉ាងណា កម្ពុជាបានកំពុងស្វះស្វែងត្រៀមខ្លួនក្នុងដំណើរការជំរុញបរិវត្តកម្មឌីជីថលដោយការបញ្ជ្រាបចូលទៅក្នុងសង្គមបានយ៉ាងឆាប់រហ័សតាមរយៈភាពងាយទទួលយក និងការចាប់យកបច្ចេកវិទ្យាសម្រាប់អភិវឌ្ឍសេដ្ឋកិច្ច និង សង្គមផង និង អភិវឌ្ឍខ្លួនឯងផងឱ្យស្របតាមនិន្នាការសកល។

## ២. គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២ - ២០៣៥

### ២.១. ចក្ខុវិស័យ

ចក្ខុវិស័យនៃគោលនយោបាយនេះគឺ ការកសាងមូលធនមនុស្សឌីជីថល ដើម្បីលើកកម្ពស់សមត្ថភាពជំនាញឌីជីថល និង ការស្រាវជ្រាវនវានុវត្តន៍ឌីជីថលដើម្បីបង្កើនប្រសិទ្ធភាព និងប្រសិទ្ធផលនៃបរិវត្តកម្មឌីជីថល និងមានការប្រកួតប្រជែងឌីជីថលក្នុងតំបន់។[6]

### ២.២. គោលបំណង

ដើម្បីសម្រេចបាននូវចក្ខុវិស័យនិងគោលបំណងនៃគោលនយោបាយខាងលើ រាជរដ្ឋាភិបាលបានដាក់ចេញគោលដៅជាយុទ្ធសាស្ត្រចំនួន៤ ក្នុងចំណោមទាំង៤នេះ យើងបានលើកយកគោលដៅជាយុទ្ធសាស្ត្រទី៣ គឺ **ការកសាងសមត្ថភាពនិងនវានុវត្តន៍ឌីជីថល** ដែលមានយុទ្ធសាស្ត្រចំនួន២ដូចខាងក្រោម៖

- យុទ្ធសាស្ត្រទី៧ ៖ ការកសាងមូលធនមនុស្សឌីជីថល
- យុទ្ធសាស្ត្រទី៨ ៖ ការលើកកម្ពស់ការស្រាវជ្រាវនិងនវានុវត្តន៍ឌីជីថល។[7]

### ២.៣. យុទ្ធសាស្ត្រទី៧៖ ការកសាងមូលធនមនុស្សឌីជីថល

ការកសាងមូលធនមនុស្សឌីជីថល ចាប់ផ្តើមពីការកសាងសមត្ថភាពដល់ថ្នាក់ដឹកនាំនិងមន្ត្រីរាជការគ្រប់ក្រសួងស្ថាប័ន ក្នុងការចាប់យកបច្ចេកវិទ្យាឌីជីថលសម្រាប់បម្រើឱ្យការប្រើប្រាស់ ការគ្រប់គ្រង និងការអភិវឌ្ឍប្រព័ន្ធរដ្ឋាភិបាលឌីជីថល ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។ បន្ថែមលើនេះ ធនធានមនុស្សជំនាញបច្ចេកវិទ្យាឌីជីថលត្រូវទទួលបានបណ្តុះបណ្តាល ដើម្បីជំរុញការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលប្រកបដោយប្រសិទ្ធ

---

[6] និយ័តករទូរគមនាគមន៍កម្ពុជា, គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ https://trc.gov.kh/wp-content/uploads/policy/Digital-Government-Policy-2022-2035-1.pdf

[7] និយ័តករទូរគមនាគមន៍កម្ពុជា, គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ https://trc.gov.kh/wp-content/uploads/policy/Digital-Government-Policy-2022-2035-1.pdf

ភាព គុណភាព និងបរិយាបន្ន។ ទន្ទឹមនឹងនេះ ការលើកកម្ពស់អក្ខរកម្មឌីជីថលដល់សិស្ស និស្សិត និងប្រជាពលរដ្ឋ ជាអាទិភាពភាពចាំបាច់សំដៅជំរុញការទទួលយកនិងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ការកាត់បន្ថយគម្លាតឌីជីថល ការបង្កើនភាពប្រកួតប្រជែង និងការប្រើប្រាស់សេវារដ្ឋាភិបាលឌីជីថល។ ខាងក្រោមនេះជាសកម្មភាពអាទិភាពនៃយុទ្ធសាស្ត្រនេះមានដូចជាៈ[8]

- រៀបចំក្របខណ្ឌវាស់វែងកម្រិតសមត្ថភាពនិងទទួលស្គាល់ជំនាញបច្ចេកទេស និង គោលនយោបាយគ្រប់គ្រងកៀរគរ និងលើកទឹកចិត្តមូលធនមនុស្សជំនាញឌីជីថលក្នុងវិស័យសាធារណៈ ដើម្បីគាំទ្របរិវត្តកម្មឌីជីថល និងអភិវឌ្ឍរដ្ឋាភិបាលឌីជីថល។
- ជំរុញការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំឌីជីថល ជាពិសេសដល់ស្ត្រីនៅតាមក្រសួងស្ថាប័ន ដើម្បីលើកកម្ពស់សមត្ថភាពអភិបាលកិច្ចឌីជីថល។
- ជំរុញការបណ្តុះបណ្តាលអក្ខរកម្មឌីជីថលនិងជំនាញឌីជីថលចាំបាច់នានាដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេស មន្ត្រីបង្គោលបច្ចេកវិទ្យា សម្រាប់បម្រើដល់ការអភិវឌ្ឍ ការគ្រប់គ្រង ការប្រើប្រាស់ និងការបម្រើសេវាសាធារណៈ។
- ជំរុញការរៀបចំនិងកែលម្អកម្មវិធីសិក្សា ដើម្បីលើកកម្ពស់អក្ខរកម្មឌីជីថលសម្រាប់សិស្ស និស្សិត ចាប់ពីកម្រិតចំណេះដឹងទូទៅរហូតដល់ឧត្តមសិក្សា និងវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទូទៅ។
- លើកកម្ពស់អក្ខរកម្មនិងវិធីសាស្ត្របង្រៀនឌីជីថលសម្រាប់គ្រូបង្រៀនគ្រប់កម្រិតសិក្សានិងបណ្តុះបណ្តាល។
- ជំរុញការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធនិងប្រព័ន្ធឌីជីថលសម្រាប់អប់រំនិងបណ្តុះបណ្តាល ដូចជា ការតភ្ជាប់អ៊ីនធឺណិត បន្ទប់ដែលបំពាក់សម្ភារបរិក្ខាឌីជីថល ថ្នាលអប់រំនិងបណ្តុះបណ្តាល ការអភិវឌ្ឍមាតិកាអប់រំឌីជីថលថលជាដើម ដើម្បីគាំទ្រដល់ការអប់រំនិងបណ្តុះបណ្តាលអក្ខរកម្មឌីជីថលដល់គ្រឹះស្ថានអប់រំគ្រប់កម្រិតនិងបណ្តុះបណ្តាល។
- រៀបចំកម្មវិធីបណ្តុះបណ្តាល កម្មវិធីបញ្ជ្រាបការយល់ដឹង និងការអប់រំ អំពីចំណេះដឹងមូលដ្ឋានបច្ចេកវិទ្យាឌីជីថល និងការប្រើប្រាស់សេវាសាធារណៈឌីជីថល ដើម្បីលើកកម្ពស់អក្ខរកម្មឌីជីថលក្នុងចំណោមប្រជាពលរដ្ឋដោយសហការជាមួយតួអង្គពាក់ព័ន្ធ ពិសេស ស្ថាប័នផ្សព្វផ្សាយនិងអាជ្ញាធរមូលដ្ឋាន។
- ជំរុញរៀបចំថ្នាលអប់រំនិងបណ្តុះបណ្តាលជាតិ ដើម្បីផ្តល់មាតិកាអប់រំសម្រាប់កាត់បន្ថយគម្លាតឌីជីថលក្នុងចំណោមប្រជាពលរដ្ឋ ជាពិសេស តាមតំបន់ជនបទដាច់ស្រយាល តាមរយៈប្រព័ន្ធអនឡាញ និងជំរុញការសិក្សាពេញមួយជីវិត។
- រៀបចំក្របខណ្ឌសមត្ថភាពឌីជីថលជាតិ ដែលកំណត់ស្តង់ដាគុណវុឌ្ឍិ សមត្ថភាពនិងជំនាញបច្ចេកវិទ្យាឌីជីថលសំខាន់ៗ ដើម្បីឆ្លើយតបនឹងតម្រូវការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល សេដ្ឋកិច្ចនិងសង្គមឌីជីថល និងឧស្សាហកម្មជំនាន់ទី៤។
- ពង្រឹងនិងពង្រីកគ្រឹះស្ថានបណ្តុះបណ្តាលជំនាញបច្ចេកវិទ្យាឌីជីថល តាមរយៈការរៀបចំកម្មវិធីសិក្សា ការរៀបចំមន្ទីរពិសោធ និងការបណ្តុះបណ្តាលគ្រូបង្គោល ដែលរួមមាន ការពង្រឹងសមត្ថភាពជំនាញនិងវិធី

[8] និយ័តករទូរគមនាគមន៍កម្ពុជា, គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ https://trc.gov.kh/wp-content/uploads/policy/Digital-Government-Policy-2022-2035-1.pdf

សាស្ត្របង្រៀនបែបឌីជីថល ដើម្បីគាំទ្រដល់ការកសាងធនធានជំនាញឌីជីថលដែលមានសមត្ថភាព និងមានភាពប្រកួតប្រជែងខ្ពស់។

- រៀបចំកម្មវិធីតម្រង់ទិស ផ្សព្វផ្សាយ ជំរុញ និងលើកទឹកចិត្ត ដល់យុវជន ជាពិសេសយុវនារី ឱ្យចាប់យកនិងជ្រើសរើសការសិក្សាជំនាញបច្ចេកវិទ្យាឌីជីថលកាន់តែច្រើន ដើម្បីបង្កើនអ្នកជំនាញឌីជីថលក្នុងទីផ្សារការងារឱ្យបានគ្រប់គ្រាន់និងកាត់បន្ថយគម្លាតយេនឌ័រជំនាញឌីជីថល។
- ជំរុញការបណ្តុះបណ្តាលជំនាញឌីជីថលសំខាន់ៗ ជាអាទិ៍ ការអភិវឌ្ឍសុសវែរ ទូរគមនាគមន៍និងបណ្តាញ បញ្ញាសិប្បនិម្មិត វិទ្យាសាស្ត្រទិន្នន័យ និម្មាបនកម្មប្រព័ន្ធព័ត៌មាន និងសន្តិសុខឌីជីថល តាមរយៈដូចជា កម្មវិធីអាហារូបករណ៍ កម្មវិធីលើកទឹកចិត្តគ្រឹះស្ថានអប់រំនិងបណ្តុះបណ្តាលជាដើម ដើម្បីឆ្លើយតបទៅនឹងតម្រូវការជំនាញនៃការអភិវឌ្ឍឧស្សាហកម្មជំនាន់ទី៤។

### ២.៤. យុទ្ធសាស្ត្រទី៤៖ ការលើកកម្ពស់ការស្រាវជ្រាវនិងនវានុវត្តន៍ឌីជីថល

ការស្រាវជ្រាវនិងនវានុវត្តន៍ឌីជីថលជាយុទ្ធសាស្ត្រដ៏សំខាន់ ដើម្បីបង្កើនសមត្ថភាព ប្រសិទ្ធភាព និងប្រសិទ្ធផលនៃបរិវត្តកម្មឌីជីថល និងធានាការប្រកួតប្រជែងឌីជីថលក្នុងតំបន់។ សកម្មភាពអាទិភាពនៃយុទ្ធសាស្ត្រនេះមានដូចខាងក្រោម៖[9]

- ជំរុញការកសាងប្រព័ន្ធជាតិស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល តាមរយៈការរៀបចំផែនការមេ យន្តការនៃការលើកទឹកចិត្ត និងការជំរុញភាពជាដៃគូរវាងគ្រឹះស្ថានស្រាវជ្រាវ សាកលវិទ្យាល័យ និងក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល ដើម្បីលើកកម្ពស់សកម្មភាពស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល។
- ជំរុញការផ្ទេរបច្ចេកវិទ្យាឌីជីថលដែលជាលទ្ធផលពីការស្រាវជ្រាវដល់វិស័យសាធារណៈនិងឯកជន តាមរយៈការរៀបចំកិច្ចសហការ ការវិនិយោគ និងការអនុវត្តគម្រោងរួមគ្នារវាងគ្រឹះស្ថានស្រាវជ្រាវនិងអប់រំជាមួយវិស័យឯកជន ដើម្បីផ្តល់ដំណោះស្រាយបច្ចេកវិទ្យាឌីជីថលឱ្យបានទូលំទូលាយនិងសម្បូរបែប។
- ជំរុញសហគ្រិនភាពនៃនវានុវត្តន៍ឌីជីថល តាមរយៈកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជាតិនិងអន្តរជាតិ និងវិស័យឯកជន ការរៀបចំយន្តការទទួលស្គាល់នវានុវត្តន៍ថ្មីៗ កម្មវិធីប្រកួតប្រជែង ការការពារកម្មសិទ្ធិបញ្ញា ជាដើម ដើម្បីយកលទ្ធផលចេញពីនវានុវត្តន៍ទៅប្រើប្រាស់ក្នុងវិស័យសាធារណៈនិងឯកជន និងធានាឧត្តមភាពប្រកួតប្រជែងឌីជីថល។

## ៣. ពិនិត្យមើលឯកសារស្រាវជ្រាវនានាពាក់ព័ន្ធនឹងការត្រៀមខ្លួនក្នុងវិស័យឌីជីថលរបស់យុវជនកម្ពុជា៖

### ៣.១. ឯកសារស្រាវជ្រាវពីក្រសួងស្ថាប័នពាក់ព័ន្ធនានា

➢ ក្រសួងសេដ្ឋកិច្ចសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបង្កើតអង្គភាពរចនាសម្ព័ន្ធមួយ គឺ**អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល** ដែលបំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើបេសកម្ម ដឹកនាំ គ្រប់គ្រង និង

[9] និយ័តករទូរគមនាគមន៍កម្ពុជា, គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ https://trc.gov.kh/wp-content/uploads/policy/Digital-Government-Policy-2022-2035-1.pdf

អភិវឌ្ឍសេដ្ឋកិច្ចឌីជីថលនៃព្រះរាជាណាចក្រកម្ពុជា ដោយឈរលើគោលការណ៍សេដ្ឋកិច្ចទីផ្សារ និងសមធម៌សង្គម អនុលោមតាមគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀតពាក់ព័ន្ធនឹងសេដ្ឋកិច្ចឌីជីថល។[10]

- នៅក្នុងដំណើរការបរិវត្តកម្មឌីជីថល រាជរដ្ឋាភិបាលបានបង្កើត " **ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និងសង្គមឌីជីថល**" ដែលហៅកាត់ថា ក.ស.ឌ ដែលមានតួនាទី ក្នុងការដឹកនាំ សម្របសម្រួល និង ជំរុញការកសាងនិងការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថលរស់រវើក តាមរយៈការរៀបចំមូលដ្ឋានគ្រឹះជំរុញ ការទទួលយក និង បរិវត្តកម្មឌីជីថលនៅគ្រប់តួអង្គសង្គម ទាំងរដ្ឋ ពលរដ្ឋ និងធុរជន។ ដើម្បីធានាបាននូវការជំរុញសន្ទុះកំណើនសេដ្ឋកិច្ចថ្មី និង ការលើកកម្ពស់សុខុមាលភាពសង្គមក្នុងប្រទេសកម្ពុជា។[11]
- **មជ្ឈមណ្ឌលកម្ពុជា ៤.០** គឺជាអង្គការមិនមែនរដ្ឋាភិបាលដែលបង្កើតឡើងក្នុងគោលបំណង ចូលរួមជាមួយរាជរដ្ឋាភិបាល វិស័យឯកជន ប្រជាពលរដ្ឋ និងភាគីពាក់ព័ន្ធ ក្នុងការជំរុញឌីជីថលូបនីយកម្ម និងការកសាងសេដ្ឋកិច្ច សង្គមឌីជីថលនៅកម្ពុជា។ មជ្ឈមណ្ឌលកម្ពុជា ៤.០ បានខិតខំអនុវត្តសកម្មភាពរបស់ខ្លួនដោយផ្តោតសំខាន់លើការងារចំនួន ៤.០ រួមមានៈ[12]

  ទី១. ការបញ្ជ្រាបការយល់ដឹងពីបច្ចេកវិទ្យាដល់ស្រទាប់មហាជន

  ទី២. ការបណ្តុះបណ្តាល និងតម្រង់ទិសតាមរយៈកម្មវិធីអក្ខរកម្មឌីជីថល

  ទី៣. ការសិក្សាស្រាវជ្រាវ

  ទី៤. ការអនុវត្តគម្រោងគំរូ។

### ៣.២. ឯកសារស្រាវជ្រាវនានាពាក់ព័ន្ធនឹងសេដ្ឋកិច្ច និងសង្គមឌីជីថល

- ចំពោះបច្ចេកវិទ្យាព័ត៌មានវិទ្យា ជាឯកទេសមួយបានចូលរួម លើគ្រប់វិស័យ ដែលមិនអាចខ្វះបានសម្រាប់ប្រទេសកម្ពុជាដែលកំពុងអភិវឌ្ឍ ស្របតាមរបត់នៃបរិវត្តកម្ម ៤.០ ជំនាញនេះផ្អែកលើថ្នាលនៃបច្ចេកវិទ្យាឌីជីថលដើម្បីលើកកម្ពស់អក្ខរកម្មឌីជីថល ការស្រាវជាវ បង្កើតគំនិតថ្មី សម្រាប់សិស្ស និស្សិត មកទទួលការបណ្តុះបណ្តាលវគ្គខ្លីៗជាមួយតម្លៃសិក្សាសមរម្យមិនចាំបាច់សិក្សារយៈពេល៤ឆ្នាំ ក្នុងនោះក៏មានកម្មវិធីអាហារូបករណ៍ផងដែរ ។ សព្វថ្ងៃយើងសង្កេតឃើញមានគ្រឹះស្ថានអប់រំជាច្រើនបានរៀបចំកម្មវិធីវគ្គសិក្សាខ្លីៗដែលអ្នកអាចសិក្សាហើយ រកការងារធ្វើបាន មានដូចជាៈ
- សាលាគ្រប់វិស័យមានបង្រៀនកុំព្យូទ័រក្នុងរយៈពេលខ្លីរៀនឆាប់ចប់ និងមានតម្លៃសមរម្យសម្រាប់យុវជនមានលទ្ធភាពសិក្សា

---

[10] អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល https://www.facebook.com/kh.mef.gdde?mibextid=LQQJ4d

[11] គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល https://digitaleconomy.gov.kh/index

[12] មជ្ឈមណ្ឌលកម្ពុជា៤.០ https://www.facebook.com/cambodia4point0?mibextid=LQQJ4d

- គ្រឹះស្ថានអប់រំគ្រប់វិស័យជាច្រើនដែលមានការរៀបចំកម្មវិធីសិក្សាជាវគ្គខ្លីៗ ឆាប់ចេះអាចរកការងារបានស្របតាមទីផ្សារការងារនាពេលបច្ចុប្បន្ននិងអនាគត ក្នុងនោះមានកម្មវិធីសិក្សាដូចជា៖ កម្មវិធីកាត់តវីដេអូតាមទូរស័ព្ទដៃនិងកុំព្យូទ័រ (Video Editing App), វគ្គសិក្សាការធ្វើទីផ្សារតាមអនឡាញ (Digital Marketing), Software Developers, Software Engineer, ជាដើម និងមានកម្មវិធីផ្សេងៗទៀត ដែលយុវជនអាចជ្រើសរើសមកសិក្សា។

ខាងក្រោមនេះជាការលើកបង្ហាញខ្លះៗពីគ្រឹះស្ថានអប់រំមួយចំនួនដែលមានកម្មវិធីសិក្សាពាក់ព័ន្ធនឹងបច្ចេកវិទ្យាជំនាញឌីជីថល និងកម្មវិធីសក្សាកុំព្យូទ័រ៖

- ➢ ក្នុងវិស័យសេដ្ឋកិច្ច៖ បច្ចុប្បន្នគ្រប់គ្រឹះស្ថានអប់រំនៅប្រទេសកម្ពុជា កំពុងមានការពង្រឹងនិងពង្រីកការបណ្តុះបណ្តាលជំនាញបច្ចេកវិទ្យាឌីជីថលសំខាន់ៗ តាមរយៈការរៀបចំកម្មវិធីសិក្សាតម្រង់ទិស រួមមាន IT, PROGRAMMING AND DATABASE, WED DEVELOPMENT, GRAPHIC DESIGN, ARCHITECTURE DESIGN, STUDIO PHOTOGRAPHY AND MULTIMEDIA, NETWORKING ជាដើម។
- ➢ បច្ចុប្បន្ននេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជជីវៈ បានបង្កើតកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជជីវៈ និងបច្ចេកទេសដល់យុវជនគ្រប់រូបមកសិក្សាដោយមិនគិតថ្លៃ ដែលកម្មវិធីនេះហៅកាត់ថា TVET 1.5m ដោយសម្តេចធិបតីបានផ្តល់ឱកាសថ្មីលើគោលដៅនៃការបណ្តុះបណ្តាល កម្មវិធីនេះបានដាក់នៅគ្រប់វិទ្យាស្ថាន ដែលមានផ្សព្វផ្សាយសម្រាប់ឱ្យយុវជនមកទទួលការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនិងជំនាញបច្ចេកវិទ្យាជាដើម ដោយទីតាំងមានទាំងនៅទីក្រុង និងទីជនបទ។[13]
- ➢ ទីផ្សារ ឬ Market

ចំណុចនេះដែរគឺសំដៅទៅលើបច្ចេកវិទ្យាទំនើបដែលកំពុងពេញនិយមនៅក្នុងយុទ្ធសាស្ត្រទីផ្សារចំពោះសង្គមសព្វថ្ងៃនេះដែលទាំងនេះមានដូចជា ៖

១ , ការទិញ និង លក់ទីផ្សារហ៊ុន

២ , ការដាក់បញ្ចូលទំនិញ ផលិតផល និងសេវាកម្មរបស់ខ្លួនទៅក្នុងកម្មវិធីប្រព័ន្ធអនឡាញ

ឧទាហរណ៍ : Food panda , Trip.com , Pass App … ។

៣ , ការទូទាត់ប្រាក់តាមបណ្តាធនាគារផ្សេងៗ

ឧទាហរណ៍ : ABA bank , Wing Bank , ACLEDA Bank … ។

៤ , ការផ្សព្វផ្សាយ ទំនិញ ផលិតផល និងសេវាកម្មរបស់ខ្លួនតាមរយៈបណ្តាញសង្គមនានា ។

---

[13] កម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជជីវៈ និងបច្ចេកទេស https://scholarship.tvet.gov.kh/home

### ៣.៣. ហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់បរិវត្តកម្មឌីជីថល

ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថលនៅកម្ពុជា មានភាពរីកចម្រើនខ្លាំងក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ជាការឆ្លើយតបទៅនឹងកំណើននៃតម្រូវការរបស់ប្រជាពលរដ្ឋ ក្នុងការប្រើប្រាស់សេវាអ៊ីនធឺណិតជាមួយទូរស័ព្ទចល័ត និងឧបករណ៍ឌីជីថលជាច្រើនប្រភេទទៀត ដែលបច្ចុប្បន្នមានភាពពេញនិយមប្រើក្នុងកិច្ចការងារ ការសិក្សា និងធុរកិច្ចជាដើម។ ជាក់ស្ដែង កម្ពុជាមានវឌ្ឍនភាពផ្នែកហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ នៅលំដាប់មធ្យម នៅក្នុងកម្រិតតំបន់ និង សកល។ ទោះជាហេដ្ឋារចនាសម្ព័ន្ធបណ្ដាញអ៊ីនធឺណិតនៅកម្ពុជាមានភាពល្អប្រសើរ និងមានតម្លៃសមរម្យ ភាគច្រើននៅតាមទីក្រុង និងទីប្រជុំជនធំៗក៏ដោយ តែគុណភាពរួមនៅមានកម្រិតនៅឡើយ ហើយហេដ្ឋារចនាសម្ព័ន្ធមានស្រាប់នៅមិនទាន់គ្រប់គ្រាន់ក្នុងការជំរុញការធ្វើបរិវត្តកម្មឌីជីថល និងការចាប់យកកាលានុវត្តភាពថ្មីៗបានឆាប់រហ័សនោះទេ ដែលតម្រូវឱ្យមានការអភិវឌ្ឍ និងពង្រឹងបន្ថែម។ ដូច្នេះ សម្រាប់ជាមូលដ្ឋានក្នុងការធ្វើបរិវត្តកម្មឌីជីថល ដែលនឹងជ្រាបចូលក្នុងសង្គម និងគ្រប់ទិដ្ឋភាពនៃជីវភាពរបស់ប្រជាជន, រាជរដ្ឋាភិបាលនឹងផ្ដោតលើការកសាងហេដ្ឋារចនាសម្ព័ន្ធឌីជីថល លើទិដ្ឋភាព ៣ធំៗ រួមមាន៖[14]

- **ការតភ្ជាប់ឌីជីថល៖** បច្ចុប្បន្នជាមួយភាពជឿនលឿននៃបច្ចេកវិទ្យាឌីជីថល យើងសង្កេតឃើញសាលារៀន មន្ទីរពេទ្យ ប្រព័ន្ធដឹកជញ្ជូនសាធារណៈ ប្រព័ន្ធសន្តិសុខសង្គម និង រដ្ឋបាលសាធារណៈនានា បាននឹងកំពុងធ្វើការភ្ជាប់ជាមួយប្រព័ន្ធឌីជីថល ដើម្បីអាចឆ្លើយតបទៅនឹងកំណើនការប្រើប្រាស់បច្ចេកវិទ្យារបស់ប្រជាពលរដ្ឋ និងការផ្ដល់សេវាឌីជីថល ដោយធ្វើការតភ្ជាប់ឌីជីថលប្រកបដោយប្រសិទ្ធភាព។ ជារួមក្នុងទិដ្ឋភាពនៃហេដ្ឋារចនាសម្ព័ន្ធ គាំទ្រដល់បរិវត្តកម្មឌីជីថល បច្ចេកវិទ្យាអ៊ីនធឺណិត និង អគ្គិសនីដើរតួសំខាន់ ជាចរន្តនៃការតភ្ជាប់ឌីជីថល និងថាមពលដែលមិនអាចខ្វះបាន ដើម្បីធានានិរន្តរភាពដំណើរការនៃគ្រប់សកម្មភាពឌីជីថល ។
- **ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា និង ប្រព័ន្ធទូទាត់សងប្រាក់ឌីជីថលនៅក្នុងវិស័យហិរញ្ញវត្ថុ៖** បច្ចុប្បន្នបច្ចេកវិទ្យាឌីជីថលត្រូវបានបញ្ចូលនៅក្នុងវិស័យធនាគារ បានអនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចធ្វើប្រតិបត្តិការហិរញ្ញវត្ថុបានកាន់តែរហ័ស ចំណាយតិច និងមានសុវត្ថិភាពជាងមុន ។ ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងវិស័យធនាគារ អាចឱ្យអ្នកប្រប្រើប្រាស់ទទួលបានសេវាកម្មក្នុងទម្រង់ឌីជីថល ដូចជា ការទាញយករបាយការណ៍ធនាគារ, ការដកសាច់ប្រាក់, ការផ្ទេរប្រាក់, ការគ្រប់គ្រងគណនី, ការបើកគណនីប្រាក់បញ្ញើ, ការគ្រប់គ្រងប្រាក់កម្ចី, ការទូទាត់វិក្កយបត្រ, ការស្នើសុំកាតនិម្មិត និងការត្រួតពិនិត្យគណនីជាដើម ក៏ដូចជាផ្ដល់សារៈប្រយោជន៍ដល់អ្នកប្រើប្រាស់ មានដូចជាប្រព័ន្ធ Online Bankingនិង ប្រព័ន្ធបាគងផងដែរ ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ វត្តមាន និង ការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ ឬ FinTech បានធ្វើឱ្យវិស័យហិរញ្ញវត្ថុមានការផ្លាស់ប្ដូរជាច្រើន ។

[14] ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍, ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ , https://mptc.gov.kh/2021/05/%E1%9E%80%E1%9F%92%E1%9E%9A%E1%9E%94%E1%9E%81%E1%9E%8E%E1%9F%92%E1%9E%8C%E1%9E%82%E1%9F%84%E1%9E%9B%E1%9E%93%E1%9E%99%E1%9F%84%E1%9E%94%E1%9E%B6%E1%9E%99%E1%9E%9F%E1%9F%81%E1%9E%8A%E1%9F%92%E1%9E%8B/

បច្ចេកវិទ្យាហិរញ្ញវត្ថុ ជាការប្រើប្រាស់បច្ចេកវិទ្យា ក៏ដូចជាអ្នកនវានុវត្តនៅក្នុងវិស័យហិរញ្ញវត្ថុដែលរួមទាំងវិស័យហិរញ្ញវត្ថុធនាគារ និងហិរញ្ញវត្ថុមិនមែនធនាគារ។ គោលដៅរបស់បច្ចេកវិទ្យានៅក្នុងវិស័យហិរញ្ញវត្ថុនោះគឺ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់ ការផ្តល់ និងការទទួលយកសេវាហិរញ្ញវត្ថុដល់អ្នកប្រើប្រាស់ប្រកបដោយបរិយាបន្ន។

- **ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តដឹកជញ្ជូនគ្រប់មធ្យោបាយ និង ការរៀបចំនូវប្រព័ន្ធឡូហ្ស៊ីស្ទិកដ៏រស់រវើក** ៖ ហេដ្ឋារចនាសម្ព័ន្ធរូបវន្តបច្ចុប្បន្ន រួមមាន
  - **ផ្លូវថ្នល់** មានផ្លូវល្បឿនលឿន, ផ្លូវក្រវាត់ក្រុង ។
  - **ផ្លូវដែក** មានរថភ្លើងជំនាន់ថ្មីៗសម្រាប់ធ្វើដំណើរនិងអាជីវកម្មផ្សេងៗក្នុងប្រទេសកម្ពុជា ។
  - **ផ្លូវអាកាស** មានអាកាសយាន្តដ្ឋានថ្មី បានកសាងនៅតំបន់សេដ្ឋកិច្ចដូចជា រាជធានីភ្នំពេញ សៀមរាប , តាខ្មៅ ។
  - **ផ្លូវទឹក** មានកំពង់ផែរាជធានីភ្នំពេញស្វយ័ត, កំពង់ផែក្រុងព្រះសីហនុ ជាដើម ហើយថ្មីៗនេះ រដ្ឋាភិបាលបានដាក់គម្រោងថ្មី ដោយការបង្កើតនូវគម្រោងព្រែកជីកហ្វូណនដែលត្រូវសាងសង់ឆាប់ៗនេះ ។
  - **ICT របស់កម្ពុជា** នៅមានកម្រិតក្នុងវិស័យឡូហ្ស៊ីស្ទិក ។ ជារួម វិស័យឡូហ្ស៊ីស្ទិក និង ដឹកជញ្ជូនគោលដៅចុងក្រោយនេះ នាបច្ចុប្បន្ន យើងសង្កេតឃើញមានកំណើនការដឹកជញ្ជូនដែលភ្ជាប់ជាមួយបច្ចេកវិទ្យាឌីជីថលគួរឱ្យកត់សម្គាល់ តែនៅមួយចំនួនតូចមិនមានសមត្ថភាពគ្រប់គ្រាន់ មិនបានប្រើប្រាស់បច្ចេកវិទ្យានេះ ។

### ៣.៤. ទំនុកចិត្ត និង ភាពជឿជាក់លើប្រព័ន្ធឌីជីថល

ជាផ្នែកដ៏សំខាន់ក្នុងការគាំទ្រដល់បរិវត្តកម្មឌីជីថល ក្នុងការធានាដល់សុវត្ថិភាពនិងផ្តល់ការការពារដល់អ្នកប្រើប្រាស់ សំដៅលើកកម្ពស់ការចូលរួមរបស់តួអង្គពាក់ព័ន្ធក្នុងសកម្មភាព និងប្រតិបត្តិការនៅក្នុងវិស័យឌីជីថលឱ្យកាន់ទូលំទូលាយ ។ នៅក្នុងបរិការណ៍នៃការវិវឌ្ឍយ៉ាងឆាប់រហ័ស ការកសាងភាពជឿជាក់ និងទំនុកចិត្តលើប្រព័ន្ធឌីជីថលនឹងផ្តោតលើការកសាងប្រព័ន្ធច្បាប់ និងការលើកកម្ពស់ការយល់ដឹងអំពីសុវត្ថិភាពឌីជីថលដែលនឹងរួមចំណែកដល់ការបង្កើនភាពជឿជាក់ និងទំនុកចិត្តរបស់អ្នកពាក់ព័ន្ធ និងលើកទឹកចិត្តឱ្យមានការចូលរួមកាន់តែទូលំទូលាយនៅក្នុងដំណើរការអភិវឌ្ឍសេដ្ឋកិច្ចសង្គមឌីជីថល។

### ៣.៥. ពលរដ្ឋឌីជីថល

ការចាប់យកអត្ថប្រយោជន៍ជាអតិបរមាពីបរិវត្តកម្មសេដ្ឋកិច្ច និង សង្គមឌីជីថល និង បង្កើនភាពប្រកួតប្រជែងជាមួយនឹងប្រទេសក្នុងតំបន់ តាមរយៈការអភិវឌ្ឍធនធានមនុស្សឱ្យមានភាពជាអ្នកដឹកនាំឌីជីថល, ពង្រីកបណ្តុំធនធានមនុស្សដែលមានទេពកោសល្យឌីជីថល, និង ធ្វើយ៉ាងណា ប្រែក្លាយប្រជាពលរដ្ឋកម្ពុជា ឱ្យទៅជាពលរដ្ឋឌីជីថលទាំងក្នុងវិស័យសាធារណៈនិងវិស័យឯកជននិងជ្រៀតដល់កម្រិតសហគមន៍មូលដ្ឋាន។[15]

[15] ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍, ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ , https://mptc.gov.kh/2021/05/%E1%9E%80%E1%9F%92%E1%9E%9A%E1%9E%94%E1%9E%81%E1%9E%8E%E1%9F%92%E1%9E%8C%E1%9E%82%E1%9F%84%E1%9E%9B%E1%9E%93%E1%9E%99%E1%9F%84%E1%9E%94%E1%9E%B6%E1%9E%99%E1%9E%9F%E1%9F%81%E1%9E%8A%E1%9F%92%E1%9E%8B/

### ៣.៦. រដ្ឋាភិបាលឌីជីថល

ជំរុញរបៀបវារៈ នៃការកែទម្រង់របស់រាជរដ្ឋាភិបាល ដោយប្រើប្រាស់បច្ចេកវិទ្យា និង បង្កើតបរិយាកាសប្រកបដោយបរិយាបន្នកម្មមួយតាមរយៈ ការកំណត់ស្តង់ដានៃសេវាសាធារណៈតាមបច្ចេកវិទ្យាឌីជីថល ដោយរក្សាភាពជាម្ចាស់នៃក្រសួងស្ថាប័ន, ការកសាងថ្នាលបច្ចេកវិទ្យាមូលដ្ឋានរបស់រដ្ឋ, និងការរៀបចំនូវប្រព័ន្ធអភិបាលកិច្ចផ្អែកលើទិន្នន័យក្នុងបរិការណ៍រដ្ឋាភិបាលឌីជីថល ។ ការកសាងរដ្ឋាភិបាល និងសេវាធារណៈឌីជីថល ជាគន្លឹះជំរុញការអនុវត្តឌីជីថល, និងអភិបាលកិច្ចផ្អែកលើទិន្នន័យ។

### ៣.៧. ធុរកិច្ចឌីជីថល

ជំរុញការចាប់យកឌីជីថលរបស់សហគ្រាសគ្រប់កម្រិត និង គ្រប់វិស័យតាមរយៈការជំរុញបរិវត្តកម្មឌីជីថលសហគ្រាស ដោយការប្រើប្រាស់បច្ចេកវិទ្យាក្នុងសហគ្រាសនៅកម្ពុជា បានកំពុងកើនឡើងយ៉ាងឆាប់រហ័សផងដែរ, ការបង្កើតប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាព និង ធុរកិច្ចថ្មី, និង ការលើកកម្ពស់ខ្សែច្រវ៉ាក់តម្លៃឌីជីថល។

## ៤. ការបញ្ចៀស ការកាត់បន្ថយ និង ដំណោះស្រាយផលប៉ះពាល់ និង ការគ្រប់គ្រងហានិភ័យ ៖

តាមការចង្អុលបង្ហាញក្នុងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ ដើម្បីចូលរួមបញ្ចៀស កាត់បន្ថយ និងដោះស្រាយផលប៉ះពាល់ពាក់ព័ន្ធនឹងទិដ្ឋភាពសេដ្ឋកិច្ចសង្គម ដូចជា វប្បធម៌ និងប្រពៃណី ដែលអាចកើតមានពីការធ្វើបរិវត្តកម្មឌីជីថល គណៈកម្មាធិការរដ្ឋាភិបាលឌីជីថលត្រូវរៀបចំនិងធ្វើវិសោធនកម្មច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីគ្រប់គ្រងនិងត្រួតពិនិត្យលើការបង្ហោះនិងការបង្កើតមាតិកាផ្សេងៗ ក្នុងការការពារវប្បធម៌និងប្រពៃណី ព្រមទាំងលើកទឹកចិត្តដល់ការច្នៃប្រតិដ្ឋនិងនវានុវត្តន៍។ ទន្ទឹមនឹងនេះ គណៈកម្មាធិការ រដ្ឋាភិបាលឌីជីថលអនុវត្តគម្រោងនិង ឬកម្មវិធីជំរុញការយល់ដឹងអំពីវប្បធម៌ សិល្បៈ និងអរិយធម៌ តាមប្រព័ន្ធអេឡិចត្រូនិក រៀបចំការផ្សព្វផ្សាយសម្រាប់តម្រង់ឥរិយាបថនិងផ្នត់គំនិតវិជ្ជមាន និងពន្យល់អំពីការសម្រេចចិត្ត ព្រមទាំងបញ្ហាបទិសដៅអភិវឌ្ឍន៍ពាក់ព័ន្ធនឹងបច្ចេកវិទ្យាឌីជីថលក្នុងវិស័យសាធារណៈ ក៏ដូចជា ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ បន្ថែមលើនេះការរៀបចំនិងអនុវត្តក្របខណ្ឌកម្មវិធីផ្សព្វផ្សាយថ្នាក់ជាតិនឹងជំរុញការអភិវឌ្ឍចំណេះដឹងនិងជំនាញឌីជីថល និងការផ្តល់ប្រឹក្សាស្តីពីការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដែលមានសុវត្ថិភាពនិងការធានាដល់កុមារ យុវជន លោកគ្រូ អ្នកគ្រូ និងអាណាព្យាបាល។[16]

### ៤.១. ហានិភ័យពាក់ព័ន្ធនឹងមូលធនមនុស្ស និង ហិរញ្ញវត្ថុ ៖

- មូលធនមនុស្សនិងហិរញ្ញវត្ថុ គឺជាធនធានដ៏ចាំបាច់បំផុតសម្រាប់ការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលការអនុវត្តគោលនយោបាយ ដំណើរការស្ថាប័ន និងការអភិវឌ្ឍវិស័យផ្សេងៗទៀត។ ហានិភ័យពាក់ព័ន្ធនឹងមូលធនមនុស្ស មានដូចជា កង្វះធនធានមនុស្សជំនាញ កង្វះឆន្ទៈនិងសុចរិតភាពក្នុងការអនុវត្តការងារ និងអត្រានៃ

[16] និយ័តករទូរគមនាគមន៍កម្ពុជា, គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ https://trc.gov.kh/wp-content/uploads/policy/Digital-Government-Policy-2022-2035-1.pdf

ការចាកចេញឬការផ្លាស់ប្តូរពីការងារមានកម្រិតខ្ពស់ ដោយសារគម្លាតចំណូលរវាង វិស័យសាធារណៈនិង ឯកជន និងរវាងការងារក្នុង ប្រទេសនិងក្រៅប្រទេស។

- ចំណែកហានិភ័យពាក់ព័ន្ធផ្នែកហិរញ្ញវត្ថុវិញមានចំណុចធំៗពីរ គឺ
    1. កង្វះខាតធនធានហិរញ្ញវត្ថុសម្រាប់ការវិនិយោគនិងអនុវត្តការងារ
    2. ការប្រើប្រាស់ធនធានហិរញ្ញវត្ថុមិនមានប្រសិទ្ធភាពនិងប្រសិទ្ធផល ។

រាជរដ្ឋាភិបាលត្រូវផ្តោតការយកចិត្តទុកដាក់លើការគ្រប់គ្រងធនធានទាំងពីរនេះឱ្យមានប្រសិទ្ធភាពនិង ប្រសិទ្ធផល ហើយ ត្រូវកាត់បន្ថយឱ្យបានជាអតិបរមានូវហានិភ័យនានាដែលអាចកើតឡើងជាយថាហេតុ។ អភិបាលកិច្ចល្អ ការបើកចំហការគោរពច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា និងការលើកទឹកចិត្ត គឺជា កត្តាគន្លឹះសំខាន់បំផុតដែលនាំមកនូវ ភាពជោគជ័យ។

### ៤.២.ហានិភ័យពាក់ព័ន្ធនិងការអភិវឌ្ឍន៍ឆាប់រហ័សនៃបច្ចេកវិទ្យា៖

បច្ចេកវិទ្យាឌីជីថលមានការវិវឌ្ឍយ៉ាងឆាប់រហ័ស ទាមទារឱ្យរាជរដ្ឋាភិបាលមានផែនការច្បាស់លាស់ក្នុងការ ចាប់យកនិងប្រើប្រាស់បច្ចេកវិទ្យាទាំងនោះ ដើម្បីបញ្ចៀសការខាតបង់ពេលវេលានិងការវិនិយោគបន្ថែម ច្រើនលើការផ្លាស់ប្តូរប្រព័ន្ធសុសវែរ និងសម្ភារបរិក្ខារឌីជីថលថ្មី សំដៅបន្តអនុលោមភាពសន្តិសុខបច្ចេកវិទ្យា ព័ត៌មាន បង្កើនប្រសិទ្ធភាពប្រតិបត្តិការ និងឆ្លើយតបនឹងកំណើននៃសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់។ ក្នុងន័យ នេះ គណៈកម្មាធិការរដ្ឋាភិបាលឌីជីថលនិងក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវចូលរួមរៀបចំផែនការចាប់យកនិងប្រើ ប្រាស់បច្ចេកវិទ្យាឌីជីថល ដោយបញ្ជីគ្នាជាមួយផែនការអភិវឌ្ឍន៍ បច្ចេកវិទ្យាឌីជីថល ព្រមទាំងជំរុញការពង្រឹង សមត្ថភាពស្ថាប័នអប់រំនិងស្រាវជ្រាវ ដើម្បីធានាប្រសិទ្ធភាព សន្តិសុខ និរន្តភាព និងភាពជាម្ចាស់ លើទិន្នន័យ និងបច្ចេកវិទ្យាឌីជីថលស្នូលដែលយកមកប្រើប្រាស់ក្នុងប្រព័ន្ធរដ្ឋាភិបាលឌីជីថល។

# ជំពូកទី៣

# ការវិភាគទិន្នន័យ និង ការបកស្រាយទិន្នន័យ

# ជំពូកទី៣

# ការវិភាគទិន្នន័យ និង ការបកស្រាយទិន្នន័យ

## ៣.១. ការប្រមូលទិន្នន័យ

នៅក្នុងចំណុចនេះដែរយើងបានបង្កើតកម្រងសំណួរស្រាវជ្រាវដែលទាក់ទងជាមួយឌីជីថល និងការប្រើប្រាស់ឌីជីថលនៅក្នុង បណ្តាស្ថាប័នរដ្ឋ ស្ថាប័នឯកជន ព្រមទាំងការសិក្សាផងដែរ ហើយយើងបានសម្រេចចិត្តថាជ្រើសរើស ២១សំណួរសម្រាប់ធ្វើការស្ទង់មតិដែលក្នុង២១សំណួរនេះដែរមាន ១៩សំណួរជាសំណួរបិទ និងមាន ២សំណួរជាសំណួរបើក ។ ម៉្យាងវិញទៀតយើងបានបែងចែកសំណួរជាពីរប្រភេទ ដែលប្រភេទទីមួយយើងធ្វើការស្ទង់មតិទៅលើសិស្សានុសិស្សចាប់ពីរកម្រិត វិទ្យាល័យដល់ សាកលវិទ្យាល័យ និង ប្រភេទទីពីយើងធ្វើការស្ទង់មតិចំពោះ បុគ្គលិកបំពេញការងារ ទាំងស្ថាប័នរដ្ឋនិង ឯកជន ។

ចំពោះការឆ្លើយនូវសំណួរស្ទង់មតិនេះពួកយើងបានបញ្ចូលសំណួរទាំងអស់ចូលទៅក្នុងទម្រង់ Google Form សម្រាប់ស្ទង់មតិតាមរយៈអនឡាញ(Online) ដែលវាងាយស្រួលក្នុងការឆ្លើយនូវសំណួរ និង ការសរុបទិន្នន័យដូចគ្នាដែរ ។

បន្ទាប់ពីបានទិន្នន័យចម្លើយនៃការស្រង់មតិនេះរួចហើយពួកយើងបានប្រមូលទិន្នន័យចម្លើយទាំងអស់បញ្ចូលទៅក្នុកម្មវិធី Excel រួចយើងយកទិន្នន័យទាំងនោះបញ្ចូលទៅក្នុងកម្មវិធី IBM SPSS Statistic ដើម្បីធ្វើការ វិភាគទិន្នន័យក៏ដូចជាបកស្រាយទិន្នន័យទាំងមូល ។

## ៣.២. ការពិពណ៌នាទិន្នន័យ

ការស្រាវជ្រាវនេះ ធ្វើឡើងដោយការប្រមូលទិន្នន័យពីការស្ទង់មតិ ដើម្បីធ្វើការពិពណ៌នាអំពីលទ្ធផលចំនួនអ្នកចូលរួមស្ទង់មតិរាល់សំណួរគ្រប់ទម្រង់ដែលបានរៀបចំកន្លងមក។ ក្នុងនោះយើងបានបែងចែកកម្រងសំណួរជាពីរប្រភេទ គឺកម្រងសំណួរចំពោះស្ថាប័នរដ្ឋនិងស្ថាប័នឯកជន និងកម្រងសំណួរសម្រាប់យុវជន និងសិស្សានុសិស្ស ។

### ៣.២.១ កម្រងសំណួរចំពោះស្ថាប័នរដ្ឋ និងស្ថាប័នឯកជន

#### ៣.២.១.១. ភេទ

| | | ឯកតា (នាក់) | ចំនួនភាគរយ | ភាគរយបង្គរ |
|---|---|---|---|---|
| ចំនួន | ប្រុស | 11 | 46% | 45.8 |
| | ស្រី | 13 | 54% | 100.0 |
| | សរុប | 24 | 100% | |

តាមលទ្ធផលនៃការស្ទង់មតិមក យើងសង្កេតឃើញថាចំនួនអ្នកចូលរួមសរុបមាន ២៤នាក់ ដែលនៅក្នុងនោះមានមនុស្សស្រីចំនួន១៣នាក់ គិតជាភាគរយមាន ៥៤%។ ចំណែកឯអ្នកចូលរួមមនុស្សប្រុសចំនួន ១១នាក់ គិតជាភាគរយមាន ៤៦%។

ក្រាហ្វិកទី១៖ ភេទនៃអ្នកចូលរួមស្ទង់មតិ (គិតជាភាគរយ)




### ៣.២.១.២. អាស័យដ្ឋាន

| | | ឯកតា (នាក់) | ចំនួនភាគរយ | ភាគរយបង្គរ |
|---|---|---|---|---|
| ចំនួន | ទីក្រុង | 21 | 87% | 87.5 |
| | ទីជនបទ | 3 | 13% | 100.0 |
| | សរុប | 24 | 100% | |

លទ្ធផលទិន្នន័យទទួលបានពីការស្ទង់មតិបានឱ្យដឹងថា អ្នកចូលរួមឆ្លើយសំណួរមកពីទីក្រុងមានចំនួនច្រើនជាងអ្នកនៅទីជនបទ ។ ក្នុងនោះមានអ្នកនៅទីក្រុងមានចំនួន ២១នាក់ គិតជាភាគរយ ៨៧% ។ រីឯនៅទីជនបទមានចំនួន ៣នាក់ គិតជាភាគរយ ១៣% ។

ក្រាហ្វិកទី២ ៖ ទីតាំងនៃអ្នកចូលរួមស្ទង់មតិ (គិតជាភាគរយ)



### ៣.២.១.៣. ប្រភេទភារងារ

| | | ឯកតា (នាក់) | ចំនួនភាគរយ | ភាគរយបង្គរ |
|---|---|---|---|---|
| ចំនួន | ស្ថាប័នរដ្ឋ | 9 | 38% | 37.5 |
| | ស្ថាប័នឯកជន | 15 | 62% | 100.0 |
| | សរុប | 24 | 100% | |

តាមទិន្នន័យខាងលើ ដែលបានមកពីការស្ទង់មតិ បានបង្ហាញថាមន្ត្រី ឬបុគ្គលិកបានចូលរួមស្ទង់មតិសរុប ២៤នាក់ ដែលមកពីស្ថាប័នផ្សេងៗពីគ្នា។ ក្នុងនោះមានចំនួន ៩នាក់ មកពីស្ថាប័នរដ្ឋ គិតជាភាគរយមាន ៣៨% ។ ចំពោះបុគ្គលិកមកពីស្ថាប័នឯកជនមានចំនួន ១៥នាក់ និងមកពីស្ថាប័នឯកជន គិតជាភាគរយមាន ៦២% ។

ក្រាហ្វិកទី៣៖ ប្រភេទស្ថាប័ននៃអ្នកធ្វើការ (គិតជាភាគរយ)




### ៣.២.១.៤. ជំនាញឌីជីថល

| | | ឯកតា (នាក់) | ចំនួនភាគរយ | ភាគរយបង្គរ |
|---|---|---|---|---|
| ចំនួន | ស្គាល់ | 18 | 75% | 75.0 |
| | ធ្លាប់ឃើញ | 1 | 4% | 79.2 |
| | ស្គាល់និងធ្លាប់ឃើញ | 5 | 21% | 100.0 |
| | សរុប | 24 | 100% | |

តាមរយៈការស្ទង់មតិ ភាគច្រើនមន្ត្រីឬបុគ្គលិកមកពីស្ថាប័នផ្សេងៗពីគ្នា មានចំនួន១៨នាក់ ដែលស្គាល់ពីបច្ចេកវិទ្យាឌីជីថលនេះច្បាស់ គិតជាភាគរយមាន ៧៥% ។ ក្នុងទិន្នន័យមានមន្ត្រី ឬ បុគ្គលិកចំនួន ១នាក់

ដែលគាត់បានត្រឹមធ្លាប់ឃើញពីបច្ចេកវិទ្យាឌីជីថលតែប៉ុណ្ណោះ គិតជាភាគរយមាន ៤%។ រីឯមន្ត្រី ឬ បុគ្គលិក ចំនួន ៥នាក់ដែលបានស្គាល់ និងធ្លាប់ឃើញពាក់ព័ន្ធនឹងបច្ចេកវិទ្យាឌីជីថល គិតជាភាគរយមាន ២១% ។

ក្រាហ្វិកទី៤៖ ចំនួនមន្ត្រីឬបុគ្គលិកដែលស្គាល់ឬធ្លាប់ឃើញពាក់ព័ន្ធបច្ចេកវិទ្យាឌីជីថល (គិតជាភាគរយ)




### ៣.២.១.៥. ការទទួលការបណ្តុះបណ្តាល

| | | ឯកតា (នាក់) | ចំនួនភាគរយ | ភាគរយបង្គរ |
|---|---|---|---|---|
| ចំនួន | ធ្លាប់តាមរយៈសិក្ខាសាលាផ្ទាល់ | 6 | 25% | 25.0 |
| | ធ្លាប់តាមរយៈសិក្ខាសាលាអនឡាញ | 6 | 25% | 50.0 |
| | ធ្លាប់តាមរយៈការបណ្តុះបណ្តាលផ្ទាល់ | 4 | 17% | 66.7 |
| | ធ្លាប់តាមរយៈការបណ្តុះបណ្តាលអនឡាញ | 3 | 12% | 79.2 |
| | មិនដែលចូលរួម | 5 | 21% | 100.0 |
| | សរុប | 24 | 100% | |

យោងតាមទិន្នន័យនៃការស្ទង់មតិ យើងសង្កេតឃើញថានៅគ្រប់ស្ថាប័ន ទាំងស្ថាប័នរដ្ឋ និង ស្ថាប័នឯកជនមានការចូលរួមទទួលការបណ្តុះបណ្តាល និងសិក្ខាសាលាអំពីសេដ្ឋកិច្ចឌីជីថលបានច្រើនគួរសម ដែលពេលនេះផងដែរក៏មានមន្ត្រី ឬ បុគ្គលិកមួយចំនួនតូចមិនទាន់បានទទួលបានការបណ្តុះបណ្តាល ។ ក្នុងទិន្នន័យបានបង្ហាញថាមន្ត្រី ឬ បុគ្គលិកចំនួន ៦នាក់ ធ្លាប់បានចូលរួមតាមរយៈសិក្ខាសាលាដោយផ្ទាល់ គិតជាភាគរយមាន ២៥% រីឯចំនួន ៦នាក់ទៀត ធ្លាប់បានសិក្ខាសាលាតាមរយៈអនឡាញ គិតជាភាគរយមាន ២៥%។ ចំណែកឯមន្ត្រី ឬ បុគ្គលិកមានចំនួន ៤នាក់ ធ្លាប់បានទទួលការបណ្តុះបណ្តាលដោយផ្ទាល់ គិតជាភាគរយមាន ១៧% និង ចំនួន៣នាក់ទៀត បានទទួលការបណ្តុះបណ្តាលតាមរយៈអនឡាញ គិតជាភាគរយមាន ១២%។ ចុងក្រោយនៅមានមន្ត្រី ឬ បុគ្គលិកចំនួន ៥នាក់ នៅមិនទាន់ទទួលបានការបណ្តុះបណ្តាល ឬ សិក្ខាសាលានៅឡើយ ដែលគិតជាភាគរយមានចំនួន ២១%។

ក្រាហ្វិកទី៥៖ ការទទួលបានការបណ្តុះបណ្តាលនិងសិក្ខាសាលាអំពីសេដ្ឋកិច្ចឌីជីថល (គិតជាភាគរយ)




## ៣.២.១.៦. ការប្រើប្រាស់ឌីជីថល

| | | ឯកតា (នាក់) | ចំនួនភាគរយ | ភាគរយបង្គរ |
|---|---|---|---|---|
| ចំនួន | ប្រើ | 18 | 75% | 75.0 |
| | ប្រើខ្លះៗ | 6 | 25% | 100.0 |
| | សរុប | 24 | 100% | |

នៅគ្រប់ស្ថាប័នរដ្ឋ និង ស្ថាប័នឯកជនមានភាពពេញនិយមប្រើប្រាស់បច្ចេកវិទ្យាឌីជីថលគួរឱ្យកត់សម្គាល់ ដែលមន្ត្រី ឬ បុគ្គលិកបានចូលរួមឆ្លើយនូវកម្រងសំណួរនេះ យើងសង្កេតឃើញថា រាល់គ្រប់ស្ថាប័នមានចំនួន ១៨នាក់ មានការបំពាក់គ្រឿងអេឡិចត្រូនិចនិងប្រើប្រាស់បច្ចេកវិទ្យាឌីជីថល គិតជាភាគរយមានចំនួន ៧៥% ។ ចំណែកឯមន្ត្រី ឬ បុគ្គលិកចំនួន ៦នាក់ បានបង្ហាញថានៅស្ថាប័នរបស់ពួកគេនៅមានប្រើបច្ចេកវិទ្យាឌីជីថលខ្លះៗ នៅមិនទាន់ប្រើប្រាស់បច្ចេកវិទ្យាឌីជីថលទាំងស្រុងនៅឡើយ គិតជាភាគរយមាន ២៥%។

ក្រាហ្វិកទី៦៖ ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលសម្រាប់បំពេញការងារ (គិតជាភាគរយ)



### ៣.២.១.៧. បញ្ហាជួបប្រទះនៃការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលនៅក្នុងការបំពេញការងារ

| | | ឯកតា (នាក់) | ចំនួនភាគរយ | ភាគរយបង្គរ |
|---|---|---|---|---|
| ចំនួន | ពិបាកខ្លះៗ | 11 | 46% | 45.8 |
| | មិនពិបាកទេ | 6 | 25% | 70.8 |
| | ជួបបញ្ហា មិនចេះដោះស្រាយ | 1 | 4% | 75.0 |
| | ជួបបញ្ហា ចេះដោះស្រាយ | 6 | 25% | 100.0 |
| | សរុប | 24 | 100% | |

បន្ទាប់ពីធ្វើការស្ទង់មតិរួចមក ពិតណាស់រាល់ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលតែងតែមានការជួបបញ្ហាប៉ះពាល់ដល់ដំណើរការងារ គ្រាន់តែបញ្ហានោះធំឬតូច អាស្រ័យលើមនុស្សចេះដោះស្រាយឬមានវិធីសាស្ត្រយ៉ាងណា ។ ជាក់ស្តែងយោងតាមទិន្នន័យខាងលើបង្ហាញថា មន្ត្រី ឬ បុគ្គលិកចំនួន ១១នាក់ ជួបការលំបាកខ្លះៗកំឡុងពេលជួបបញ្ហា បើគិតជាភាគរយមាន ៤៦% ។ រីឯស្ថាប័នផ្សេងៗទៀត មន្ត្រី ឬ បុគ្គលិកមានចំនួន ៦នាក់ចំពោះការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលគឺមិនមានការលំបាកអ្វីនោះទេ គិតជាភាគរយមាន ២៥%។ បន្ទាប់មកមានមន្ត្រី ឬ បុគ្គលិកចំនួន ១នាក់ មកពីស្ថាប័នផ្សេងៗ ជួបបញ្ហាពេលប្រើប្រាស់បច្ចេកវិទ្យាឌីជីថលសម្រាប់បំពេញកិច្ចការងារ តែមិនចេះដោះស្រាយ គិតជាភាគរយមាន ៤%។ ចំណែកឯមន្ត្រី ឬ បុគ្គលិកចំនួន ៦នាក់ ចេះដោះស្រាយបញ្ហាដោយខ្លួនឯង នៅពេលជួបបញ្ហាកំឡុងពេលបំពេញការងារដោយប្រើបច្ចេកវិទ្យាឌីជីថល គិតជាភាគរយមាន ២៥% ។

ក្រាហ្វិកទី៧៖ ផលវិបាកនៃអ្នកប្រើប្រាស់បច្ចេកវិទ្យាឌីជីថល (គិតជាភាគរយ)



### ៣.២.១.៨. អ្នកជំនាញឌីជីថល

| | | ឯកតា (នាក់) | ចំនួនភាគរយ | ភាគរយបង្គរ |
|---|---|---|---|---|
| ចំនួន | មានច្រើន | 12 | 50% | 50.0 |
| | មិនសូវមាន | 12 | 50% | 100.0 |
| | សរុប | 24 | 100% | |

តាមរយៈទិន្នន័យដែលប្រមូលបាន ជំនាញឌីជីថលនៅគ្រប់ស្ថាប័ននៅមានកម្រិត យើងសង្កេតឃើញថា ស្ថាប័នទាំង២៤ខាងលើមានភាពស្មើគ្នា រវាងចំនួនអ្នកមានជំនាញឌីជីថលនិងអ្នកមិនសូវមានជំនាញឌីជីថល ។ ក្នុងនោះគ្រប់ស្ថាប័នចំនួន ១២ សម្បូរអ្នកជំនាញឌីជីថលច្រើន គិតជាភាគរយមាន ៥០%។ ចំណែកឯស្ថាប័នចំនួន ១២ ទៀត អ្នកជំនាញឌីជីថលមានខ្លះ តែមិនសូវសម្បូរទេ បើគិតជាភាគរយមាន ៥០% ។

ក្រាហ្វិកទី៨៖ ធនធានមនុស្សដែលមានជំនាញឌីជីថលនៅគ្រប់ស្ថាប័ន (គិតជាភាគរយ)




### ៣.២.១.៩. អត្ថប្រយោជន៍នៃបច្ចេកវិទ្យាឌីជីថល

| | | ឯកតា (នាក់) | ចំនួនភាគរយ | ភាគរយបង្គរ |
|---|---|---|---|---|
| ចំនួន | 50.00% | 8 | 33.3% | 33.3 |
| | 70.00% | 6 | 25.0% | 58.3 |
| | 80.00% | 3 | 12.5% | 70.8 |
| | 90.00% | 5 | 20.8% | 91.7 |
| | 95.00% | 2 | 8.3% | 100.0 |
| | Total | 24 | 100% | |

យោងតាមទិន្នន័យដែលបានស្ទង់មតិទៅលើសំណួរទាក់ទងនឹងចំណាប់អារម្មណ៍របស់មន្ត្រី ឬបុគ្គលិក ចំពោះអត្ថប្រយោជន៍នៃបច្ចេកវិទ្យាឌីជីថលរបស់ស្ថាប័ននីមួយៗ បង្ហាញដូចខាងក្រោម៖

- អត្ថប្រយោជន៍ទទួលបានពីបច្ចេកវិទ្យាឌីជីថលចាប់ពី (៥០% - ៧០%) មានចំនួន ១៤ស្ថាប័ន គិតជាភាគរយមាន ៥៨.៣%
- អត្ថប្រយោជន៍ទទួលបានពីបច្ចេកវិទ្យាឌីជីថលចាប់ពី (៨០% - ៩៥%) មានចំនួន ១០ស្ថាប័ន គិតជាភាគរយមាន ៤១.៦% ។

ក្រាហ្វិកទី៩៖ អត្ថប្រយោជន៍នៃបច្ចេកវិទ្យាឌីជីថលនៅគ្រប់ស្ថាប័ន (គិតជាភាគរយ)




## ៣.២.២. គម្រូវសំណួរសម្រាប់យុវជន និងសិស្សានុសិស្ស

### ៣.២.២.១ ភេទ

| | | ឯកតា (នាក់) | ចំនួនភាគរយ | ភាគរយបង្គរ |
|---|---|---|---|---|
| ចំនួន | ស្រី | 52 | 51% | 50.5 |
| | ប្រុស | 51 | 49% | 100 |
| សរុប | | 103 | 100% | |

តាមការវិភាគទិន្នន័យនេះបានបង្ហាញថា ចំនួននាក់ដែលចូលរួមស្ទង់មិតិទាំងអស់មានចំនួន ១០៣ នាក់ក្នុងនោះមាន ប្រុសចំនួន៥១នាក់ត្រូវនឹង៤៩% និង ស្រី ៥២នាក់ត្រូវនឹង៥១% ។

ក្រាហ្វិកទី១៖ បង្ហាញអំពីភាគរយភេទរបស់អ្នកចូលរួមស្ទង់មតិ (គិតជាភាគរយ)




### ៣.២.២.២. អាស័យដ្ឋាន

| | | ឯកតា (នាក់) | ចំនួនភាគរយ | ភាគរយបង្គរ |
|---|---|---|---|---|
| ចំនួន | ទីក្រុង | 77 | 75% | 74.8 |
| | ជនបទ | 26 | 25% | 100 |
| សរុប | | 103 | 100% | |

ចំពោះតារាងនេះគឺបង្ហាញអំពីលំនៅស្ថានបច្ចុប្បន្នរបស់អក្នចូលរួមស្ទង់មិតិដែលក្នុង១០៣នាក់មាន ៧៧នាក់ត្រូវនឹង៧៥%នៅទីក្រុង និង ២៦នាក់ត្រូវនិង២៥%នៅខាងជនបទ ។

ក្រាហ្វិកទី២៖ បង្ហាញអំពីចំនួនភាគរយនៃទីលំនៅស្ថានរបស់អ្នកចូលរួមស្ទង់មតិ (គិតជាភាគរយ)



### ៣.២.២.៣. កម្រិតនៃការសិក្សា

| | | ឯកតា (នាក់) | ចំនួនភាគរយ | ភាគរយបង្គរ |
|---|---|---|---|---|
| ចំនួន | សាកលវិទ្យាល័យ | 54 | 52% | 52.4 |
| | វិទ្យាល័យ | 49 | 48% | 100 |
| សរុប | | 103 | 100% | |

តារាងនេះបង្ហាញពីកម្រិតនៃការសិក្សារបស់អ្នកដែលចូលរួមការស្ទង់មិតិដែលមានចំនួនចំនួន១០៣នាក់ក្នុងនោះអ្នកដែលសិក្សាក្នុងសាកលវិទ្យាល័យមានចំនួន ៥៤នាក់ ត្រូវ៥២% ហើយនាក់ដែលសិក្សានៅវិទ្យាល័យមានចំនួន៤៩នាក់ ត្រូវនឹង៤៨% ។

ក្រាហ្វិកទី៣៖ បង្ហាញពីភាគរយនៃកម្រិតសិក្សារបស់អ្នកដែលចូលរួមការស្ទង់មតិ (គិតជាភាគរយ)




### ៣.២.២.៤. មុខរបរផ្ទាល់ខ្លួន

| | | ឯកតា (នាក់) | ចំនួនភាគរយ | ភាគរយបង្គរ |
|---|---|---|---|---|
| ចំនួន | មានអាជីវកម្ម | 18 | 17% | 17.5 |
| | មិនមានអាជីវកម្ម | 85 | 83% | 100 |
| សរុប | | 103 | 100% | |

តារាងនេះវិញបង្ហាញថាតើអ្នកដែលចូលរួមការស្ទង់មតិនេះមានមុខរបរផ្ទាល់ខ្លួនឬមួយក៏អត់ ដែលបានបង្ហាញថាក្នុង១០៣នាក់មាន១៨នាក់ត្រូវនឹង១៧%ពួកគាត់មានអាជីវកម្មផ្ទាល់ខ្លួន នឹង៨៥នាក់ត្រូវនឹង៨៣%ពួកគេមិនអាជីវកម្មផ្ទាល់ខ្លួន ។

ក្រាហ្វិកទី៤៖ បង្ហាញពីភាគរយរបស់អ្នកដែលចូលរួមការស្ទង់មតិដែលមានអាជីវកម្ម និង មិនទាន់មានអាជីវកម្ម (គិតជាភាគរយ)




### ៣.២.២.៥. ការយល់ដឹងពីឌីជីថល

| | | ឯកតា (នាក់) | ចំនួនភាគរយ | ភាគរយបង្គរ |
|---|---|---|---|---|
| ចំនួន | ស្គាល់ | 101 | 98% | 98.1 |
| | មិនដែលស្គាល់ | 2 | 2% | 100 |
| សរុប | | 103 | 100% | |

ចំពោះតារាងនេះដែរបានបង្ហាញយើងអំពីទិន្នន័យដែលយុវជនគាត់បានស្គាល់អំពីបច្ចេកវិទ្យាឌីជីថល ដែលក្នុង ១០៣នាក់មាន ១០១នាក់ ត្រូវ៩៨.១% គាត់បានស្គាល់ទាក់ទងនិងឌីជីថល និង ២នាក់ត្រូវនិង១.៩% គាត់មិនបានស្គាល់ទាក់ទងនិងឌីជីថល ។

ក្រាហ្វិកទី៥៖ ចំនួនភាគរយនៃការយល់ដឹងអំពីបច្ចេកវិទ្យាឌីជីថល



### ៣.២.២.៦. ការទទួលការបណ្តុះបណ្តាល

| | | ឯកតា (នាក់) | ចំនួនភាគរយ | ភាគរយបង្គរ |
|---|---|---|---|---|
| ចំនួន | សិក្សាដោយផ្ទាល់ | 63 | 61% | 61.2 |
| | សិក្សាតាមបណ្តាញសង្គម | 40 | 39% | 100 |
| សរុប | | 103 | 100% | |

ឯតារាងនេះបង្ហាញពីការទទួលការបណ្តុះបណ្តាលរបស់អ្នកដែលចូលរួមស្ទង់មតិ ដែលក្នុង១០៣នាក់ មាន៦៣នាក់ ដែលត្រូវ៦១%ពួកគាត់សិក្សាពីឌីជីថលដោយផ្ទាល់ និង ៤០នាក់ ត្រូវនិង៣៩%គឺសិក្សាតាមបណ្តាញសង្គម ។

ក្រាហ្វិកទី៦៖ បង្ហាញពីភាគរយរបស់អ្នកដែលចូលរួមការស្ទង់មតិដែលទទួលការបណ្តុះបណ្តាលឌីជីថល (គិតជាភាគរយ)




### ៣.២.២.៧. ការប្រើប្រាស់ឌីជីថល

| | | ឯកតា (នាក់) | ចំនួនភាគរយ | ភាគរយបង្គរ |
|---|---|---|---|---|
| ចំនួន | ប្រើប្រាស់ | 81 | 79% | 78.6 |
| | ប្រើប្រាស់ខ្លះៗ | 22 | 21% | 100 |
| សរុប | | 103 | 100% | |

តារាងនេះបង្ហាញអំពីការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលប្រចាំថ្ងៃរបស់អ្នកដែលចូលរួមស្ទង់មតិដែលសរុបចំនួន១០៣នាក់ ដែល៨១នាក់ត្រូវ៧៩% គាត់ប្រើប្រាស់ និង ២២នាក់ត្រូវនិង២១% ពួកគាត់ប្រើប្រាស់ខ្លះៗ ។

ក្រាហ្វិកទី៧៖ បង្ហាញពីភាគរយបស់អ្នកដែលចូលរួមការស្ទង់មតិដែលប្រើប្រាស់ឌីជីថល (គិតជាភាគរយ)




### ៣.២.២.៨. ផលចំណេញពីឌីជីថលចំពោះ ការសិក្សា និងមុខរបរ

| | | ឯកតា (នាក់) | ចំនួនភាគរយ | ភាគរយបង្គរ |
|---|---|---|---|---|
| ចំនួន | 10.00% | 2 | 1.9 | 1.9 |
| | 18.00% | 1 | 1 | 2.9 |
| | 40.00% | 1 | 1 | 3.9 |
| | 50.00% | 7 | 6.8 | 10.7 |
| | 60.00% | 4 | 3.9 | 14.6 |
| | 65.00% | 3 | 2.9 | 17.5 |
| | 70.00% | 21 | 20.4 | 37.9 |
| | 75.00% | 1 | 1 | 38.8 |
| | 80.00% | 21 | 20.4 | 59.2 |
| | 85.00% | 6 | 5.8 | 65 |
| | 86.00% | 1 | 1 | 66 |
| | 90.00% | 29 | 28.2 | 94.2 |
| | 95.00% | 4 | 3.9 | 98.1 |
| | 100.00% | 2 | 1.9 | 100 |
| សរុប | | 103 | 100 | |

តារាងនេះដែរគឺបង្ហាញពីការបញ្ចេញពីការចំណេញជាភាគរយរបស់អក្នដែលចូលរួមស្ទង់មតិដែលក្នុងនោះមានដូចជា ៖

. (១០% ៤០%) មានចំនួន ៤នាក់ ត្រូវនិង ៣.៩%

. (៥០% ៧០%) មានចំនួន៣៥នាក់ ត្រូវនិង៣៤% ។

. (៧៥% ១០០%) មានចំនួន៦៤នាក់ ត្រូវនិង៦២.១% ។

ក្រាហ្វិកទី៨៖ បង្ហាញពីភាគរយរបស់អ្នកដែលចូលរួមការស្ទង់មតិដែលការសិក្សា និង មុខរបពួកគាត់ទទួលផល ពីឌីជីថល (គិតជាភាគរយ)




### ៣.២.២.៩. ស្ថានភាពអាជីវកម្ម និង ការសិក្សាក្រោយពេលប្រើប្រាស់ឌីជីថល

| | | ឯកតា (នាក់) | ចំនួនភាគរយ | ភាគរយបង្គរ |
|---|---|---|---|---|
| ចំនួន | ធម្មតា | 60 | 58% | 58.3 |
| | យឺតយ៉ាវ | 43 | 42% | 100 |
| សរុប | | 103 | 100% | |

តារាងនេះបង្ហាញអំពីមតិរបស់អក្នដែលចូលរួមការស្ទង់មតិដែលបង្ហាញពីស្ថានភាពអាជីវកម្ម និង ការសិក្សារបស់ពួកគាត់មុនពេលស្គាល់បច្ចេកវិទ្យាឌីជីថលដែលក្នុង១០៣នាក់មាន ៦០នាក់ត្រូវ៥៨%ដែលគាត់យល់ថាធម្មតា និង ៤៣នាក់ត្រូវ៤២% យល់ថាមានភាពយឺតយ៉ាវ ។

ក្រាហ្វិកទី៩៖ បង្ហាញពីភាគរយរបស់អ្នកដែលចូលរួមការស្ទង់មតិដែលការសិក្សា និង មុខរបរបស់ពួកគាត់ប្រើប្រាស់ឌីជីថល (គិតជាភាគរយ)



### ៣.២.២.១០. មតិចំពោះឌីជីថល

| | | ឯកតា (នាក់) | ចំនួនភាគរយ | ភាគរយបង្គរ |
|---|---|---|---|---|
| ចំនួន | សំខាន់ណាស់ | 73 | 71% | 70.9 |
| | សំខាន់ | 29 | 28% | 99 |
| | មិនសំខាន់ | 1 | 1% | 100 |
| សរុប | | 103 | 100% | |

តារាងនេះបង្ហាញពីចំណាប់អារម្មណ៍របស់អ្នកដែលចូលរួមស្ទង់មតិចំពោះឌីជីថលសរុបមាន១០៣នាក់ ដែល៧៣នាក់ត្រូវនិង៧០.៩%គាត់យល់ថាមានសារសំខាន់ ហើយ២៩នាក់ត្រូវនិង ២៨.២% យល់ថាមិនសូវសំខាន់ និង ១នាក់ ត្រូវនិង ១% គាត់យល់ឃើញថាមិនសំខាន់ ។

ក្រាហ្វិកទី១០៖ បង្ហាញពីភាគរយរបស់អ្នកដែលចូលរួមការស្ទង់មតិមានមតិចំពោះឌីជីថល (គិតជាភាគរយ)




## ៣.៣. ការវិភាគទិន្នន័យ និងការបកស្រាយ

នៅក្នុងចំណុចនេះ យើងធ្វើការសិក្សាទៅលើការប្រមូលទិន្នន័យដែលមានការចូលរួមឆ្លើយនូវកម្រងសំណួរពីវិស័យការងារ ក្នុងនោះមានស្ថាប័នរដ្ឋ និង ស្ថាប័នឯកជន ព្រមទាំងយុវជន និងសិស្សានុសិស្ស ។ ចំនួនអ្នកឆ្លើយតបទាំងអស់សរុបមាន ១០៣ នាក់ ជាយុវជន និងសិស្សានុសិស្សមកពីទីជនបទ និងទីក្រុង។ ចំណែកឯនៅក្នុងវិស័យការងារ រួមមានស្ថាប័នរដ្ឋ និងស្ថាប័នឯកជន សរុបមាន ២៤ ស្ថាប័នបានចូលរួមឆ្លើយសំណួរ ដែលបច្ចុប្បន្នមកពីទីជនបទ និងទីក្រុងផងដែរ ។

ទិន្នន័យទាំងនេះផងដែរ ត្រូវបានវិភាគដោយការប្រើប្រាស់កម្មវិធីកុំព្យូទ័រមានដូចជា IBM SPSS និង Excel ដែលកម្មវិធីទាំងពីរនេះ បានផ្តល់ភាពងាយស្រួលបំផុតក្នុងការវិភាគទិន្នន័យនៃអត្ថបទនេះ ដោយហេតុថាអត្ថបទនេះជាការស្រាវជ្រាវបែបគុណវិស័យ ហើយរាល់ទិន្នន័យបឋមដែលប្រមូលបានទាំងអស់ជាទិន្នន័យ

ដែលបានពីការស្ទង់មតិតាមរយៈអនឡាញ យ៉ាងណាមិញកម្មវិធីទាំងពីរនេះ ពិតជាសមស្របជាមួយការវិភាគទិន្នន័យនៃអត្ថបទសិក្សាស្រាវជ្រាវនេះ។

### ៣.៣.១. ទិន្នន័យនៃការប្រៀបធៀបតម្លៃមធ្យមចំពោះការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងវិស័យការងារ

#### ៣.៣.១.១. ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងវិស័យការងារ

| ការប្រើប្រាស់ឌីជីថល | | N | Mean | Std. Deviation | F | Sig. |
|---|---|---|---|---|---|---|
| អត្ថប្រយោជន៍នៃឌីជីថល | ប្រើ | 18 | 73.33% | 17.41% | 0.172 | 0.683 |
| | ប្រើខ្លះៗ | 6 | 63.33% | 15.06% | | |

*:P<0.10, **P<0.5, ***P:<0.01

បើតាមការពិនិត្យទិន្នន័យខាងលើ យើងអាចសង្កេតឃើញថា កម្រិតនៃភាពជឿជាក់រវាងអត្ថប្រយោជន៍នៃការប្រើប្រាស់ឌីជីថលច្រើន និងប្រើខ្លះៗ វាមិនមានភាពខុសគ្នាទេ។

#### ៣.៣.១.២. អត្ថប្រយោជន៍នៃការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលរវាងស្ថាប័នរដ្ឋ និងស្ថាប័នឯកជន

| Interest | | N | Mean | Std. Deviation | F | Sig. |
|---|---|---|---|---|---|---|
| អត្ថប្រយោជន៍នៃបច្ចេកវិទ្យាឌីជីថល | ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលរបស់ស្ថាប័នរដ្ឋ | 6 | 75.00% | 19.75% | 0.537 | 0.474 |
| | ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលរបស់ស្ថាប័នឯកជន | 12 | 72.50% | 16.99% | | |

*:P<0.10, **P<0.5, ***P:<0.01

ចំពោះតារាងខាងលើ យើងបានដកស្រង់ទិន្នន័យពីតារាងនៃការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងវិស័យការងារ ដោយជ្រើសរើសតែស្ថាប័នមានការប្រើប្រាស់ប្រព័ន្ធឌីជីថលចំនួន ១៨ស្ថាប័នសុទ្ធតែម្តង។ យោងតាមទិន្នន័យខាងលើ បានបង្ហាញថា កម្រិតនៃភាពជឿជាក់របស់អត្ថប្រយោជន៍រវាងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលរបស់ស្ថាប័នរដ្ឋ និង ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលរបស់ស្ថាប័នឯកជន គឺមិនមានភាពខុសគ្នាទេ។

### ៣.៣.១.៣. ការទទួលបានការបណ្តុះបណ្តាលបច្ចេកវិទ្យាឌីជីថលក្នុងវិស័យការងារ

| | | | ការបណ្តុះបណ្តាលបច្ចេកវិទ្យាឌីជីថល | | | | | |
|---|---|---|---|---|---|---|---|---|
| | | | សិក្ខាសាលាផ្ទាល់ | សិក្ខាសាលាអនឡាញ | ការបណ្តុះបណ្តាលផ្ទាល់ | ការបណ្តុះបណ្តាលតាមអនឡាញ | មិនដែលចូលរួម | សរុប |
| វិស័យការងារ | ស្ថាប័នរដ្ឋ | ចំនួន | 3 | 3 | 1 | 1 | 3 | 9 |
| | | % | 22.2% | 22.2% | 11.1% | 11.1% | 33.3% | 100% |
| | ស្ថាប័នឯកជន | ចំនួន | 4 | 4 | 3 | 2 | 2 | 15 |
| | | % | 26.7% | 26.7% | 20.0% | 13.3% | 13.3% | 100% |
| សរុប | | ចំនួន | 6 | 6 | 4 | 3 | 5 | 24 |
| | | % | 25.0% | 25.0% | 16.7% | 12.5% | 20.8% | 100% |

យោងតាមទិន្នន័យខាងលើ យើងបានធ្វើការបែងចែកចំនួនស្ថាប័នតាមផ្នែក ដែលមន្ត្រី ឬ បុគ្គលិក តម្រូវឱ្យទទួលបានការបណ្តុះបណ្តាលបច្ចេកវិទ្យាឌីជីថល។ ចំពោះការបណ្តុះបណ្តាលបច្ចេកវិទ្យាឌីជីថល នៅក្នុងវិស័យការងារមានស្ថាប័នរដ្ឋចំនួន ៩ ដែលក្នុងនោះមាន ៣ស្ថាប័នបានចូលរួមសិក្ខាសាលាផ្ទាល់ គិតជាភាគរយ ២២.២% ដូចគ្នាទៅនឹងស្ថាប័ន ៣ទៀតបានចូលរួមសិក្ខាសាលាតាមរយៈអនឡាញគិតជាភាគរយ ២២.២%។ រីឯស្ថាប័នចំនួន ១ ទទួលបានការបណ្តុះបណ្តាលផ្ទាល់ គិតជាភាគរយ ១១.១% និងការបណ្តុះបណ្តាលតាមអនឡាញមាន ១ស្ថាប័ន គិតជាភាគរយ ១១.១% ។ ក្រៅពីនោះមាន ៣ស្ថាប័ននៅមិនទាន់បានចូលរួមបណ្តុះបណ្តាលបច្ចេកវិទ្យាឌីជីថល គិតជាភាគរយមាន ៣៣.៣% ។

ជាមួយគ្នានេះ ការបណ្តុះបណ្តាលបច្ចេកវិទ្យាឌីជីថលក្នុងស្ថាប័ឯកជនមាន ១៥ ដោយក្នុងនោះមាន ៤ស្ថាប័នបានសិក្ខាសាលាដោយផ្ទាល់ គិតជាភាគរយ ២៦.៧% និងការសិក្ខាសាលាតាមរយៈអនឡាញមានការចូលរួមចំនួន ៤ស្ថាប័ន គិតជាភាគរយ ២៦.៧% ។ ចំណែកឯការបណ្តុះបណ្តាលផ្ទាល់មាន ៣ស្ថាប័ន គិតជាភាគរយ ២០% និងការបណ្តុះបណ្តាលតាមអនឡាញមាន ២ស្ថាប័ន គិតជាភាគរយ ១៣.៣% ។ យ៉ាងណាមិញ នៅមាន ២ស្ថាប័នដែលមិនទទួលបានការបណ្តុះបណ្តាលពាក់ព័ន្ធនឹងបច្ចេកវិទ្យាឌីជីថល គិតជាភាគរយ ១៣.៣% ។

សរុបមក ផ្អែកលើការស្ទង់មតិទៅលើស្ថាប័នទាំង ២៤ និងយោងតាមការបកស្រាយទិន្នន័យខាងលើ យើងសង្កេតឃើញថា ស្ថាប័នឯកជនទទួលបានការបណ្តុះបណ្តាលបច្ចេកវិទ្យាឌីជីថលមានចំនួនច្រើនជាងស្ថាប័នរដ្ឋ ដែលការវិវត្តនៃការប្រើប្រាស់ប្រព័ន្ធឌីជីថលរបស់ស្ថាប័ន្ធឯកជនមានភាពជឿនលឿនជាង និងដំណើរការងារមានភាពឆាប់រហ័ស និងមានសក្តានុពល ផ្អែកលើបុគ្គលិកមានជំនាញឌីជីថលច្បាស់លាស់ ។

### ៣.៣.២. ទិន្នន័យនៃការប្រៀបធៀបតម្លៃមធ្យមចំពោះការបណ្តុះបណ្តាលពាក់ព័ន្ធនឹងបច្ចេកវិទ្យាឌីជីថលរបស់យុវជន និងសិស្សានុសិស្ស

#### ៣.៣.២.១. អត្ថប្រយោជន៍នៃការបណ្តុះបណ្តាលបច្ចេកវិទ្យាឌីជីថលក្នុងថ្នាក់ និងតាមរយៈអនឡាញ

**ប្រៀបធៀបអត្ថប្រយោជន៍របស់អ្នកបណ្តុះបណ្តាលឌីជីថលក្នុងថ្នាក់និងតាមអនឡាញ**

| បណ្តុះបណ្តាលតាមរយៈ | N | Mean | Std. Deviation | F | Sig. |
|---|---|---|---|---|---|
| សិក្សាក្នុងថ្នាក់ | 63 | 75.06% | 19.89% | | 0.003 |
| សិក្សាតាមអនឡាញ | 40 | 78.63% | 10.86% | 9.136 | |

*: p<0.10, **: p<0.05, ***p<0.01

តាមរយៈលទ្ធផលនៃការវិភាគនេះ និងតាមកម្រិតនៃភាពជឿជាក់យើងសង្កេតឃើញថា ចំនួនយុវជនឬសិស្សានុសិស្ស ដែលបានទទួលការបណ្តុះបណ្តាលអំពីឌីជីថលតាមរយៈអនឡាញ ទទួលបានផលប្រយោជន៍ច្រើនជាងតាមរយៈក្នុងថ្នាក់ ។

#### ៣.៣.២.២. ការបណ្តុះបណ្តាលបច្ចេកវិទ្យាឌីជីថលតាមទីក្រុង និងតាមបណ្តាខេត្ត

| | | | ការបណ្តុះបណ្តាលបច្ចេកវិទ្យាឌីជីថល | | |
|---|---|---|---|---|---|
| | | | សិក្សាក្នុងថ្នាក់ | សិក្សាតាមអនឡាញ | សរុប |
| អាស័យដ្ឋាន | ទីក្រុង | ចំនួន | 53 | 24 | 77 |
| | | % | 68.8% | 31.2% | 100.0% |
| | ខេត្ត | ចំនួន | 10 | 16 | 26 |
| | | % | 38.5% | 61.5% | 100.0% |
| សរុប | | ចំនួន | 63 | 40 | 103 |
| | | % | 61.2% | 38.8% | 100.0% |

ចំណែកឯទិន្នន័យនេះវិញបង្ហាញថា យុវជន និងសិស្សានុសិស្សទាំងអស់មិនថានៅទីក្រុង ឬជនបទទេគឺពួកគេសុទ្ធតែបានស្គាល់ពីឌីជីថលគ្រាន់តែការទទួលការបណ្តុះបណ្តាលរបស់ពួកគេផ្សេងៗគ្នា ( ក្នុងថ្នាក់ ឬតាមអនឡាញ ) នេះបានបញ្ជាក់ឱ្យឃើញថាយុវជន និងសិស្សានុសិស្ស ពួកគាត់បានយល់ដឹងថាឌីជីថលគឺមានផលប្រយោជន៍មិនថាទៅលើ ការសិក្សា ការបំពេញការងារប្រចាំថ្ងៃនោះទេ ។ យោងតាមទិន្នន័យបានពីការស្ទង់មតិខាងលើ យើងសង្កេតឃើញថា ចំនួនអ្នករស់នៅទីក្រុងសរុបមាន ៧៧នាក់ ដែលទទួលបានការបណ្តុះ

បណ្តាលពាក់ព័ន្ធបច្ចេកវិទ្យាឌីជីថល ក្នុងនោះអ្នកសិក្សាក្នុងថ្នាក់មាន ៥៣នាក់ គិតជាភាគរយមាន ៦៨.៨០% រីឯការសិក្សាតាមអនឡាញមានចំនួន ២៤នាក់ គិតជាភាគរយមាន ៣១.២០% ។ ចំពោះអ្នករស់នៅតាមបណ្តាខេត្តសរុបមាន ២៦នាក់ ធ្លាប់ទទួលបានការបណ្តុះបណ្តាលបច្ចេកវិទ្យាឌីជីថល ក្នុងនោះមានអ្នកសិក្សាក្នុងថ្នាក់មាន ១០នាក់ គិតជាភាគរយមាន ៣៨.៥០% និងការសិក្សាតាមរយៈអនឡាញមានចំនួន ១៦នាក់ គិតជាភាគរយមាន ៦១.៥០% ។

## ៣.៤. លទ្ធផលនៃការស្រាវជ្រាវ

តាមលទ្ធផលរបស់ការស្រាវជ្រាវនៃការស្ទង់មតិនេះបង្ហាញឱ្យឃើញថា ៖

- កំណើននៃសិស្សានុសិស្ស និង យុវជនមួយចំនួនដែលចង់ចេះ និងចង់ដឹងអំពីឌីជីថល គឺមានការកើនឡើង
- អ្នកដែលបំពេញការងារទាំងពីរស្ថាប័ន គឺមានការប្រើប្រាស់ឌីជីថលដើម្បីជំនួយដល់ការសម្រួលការងារ និង អាជីវកម្មរបស់ពួកគេ
- អត្ថប្រយោជន៍នៃឌីជីថលទៅលើ ស្ថាប័នរដ្ឋ និង ឯកជន គឺប្រហាក់ប្រហែលគ្នា
- ចំពោះការសិក្សាអំពីឌីជីថល តាមរយៈអនឡាញគឺទទួលបានផលជាងសិក្សាផ្ទាល់
- ការទទួលបានការបណ្តុះបណ្តាពីឌីជីថលរបស់ស្ថាប័នឯកជនច្រើនជាងស្ថាប័នរដ្ឋ ។

## ៣.៥. ការពិភាក្សា

ចំណុចពិភាក្សានេះ យើងធ្វើឡើងដើម្បីវិភាគផែកញែកពីឥទ្ធិពលនៃបច្ចេកវិទ្យាឌីជីថល ចំពោះមូលធនមនុស្សបច្ចុប្បន្ន ដែលនឹងបង្ហាញពីភាពខ្លាំង ភាពខ្សោយ ប្រសិទ្ធផល និងផលប៉ះពាល់នៃបច្ចេកវិទ្យាឌីជីថលក្នុងវិស័យនវានុវត្តឌីជីថលរបស់កម្ពុជា។ ជាក់ស្តែង យោងតាមលទ្ធផលនៃការស្រាវជ្រាវនេះ ដោយការវាស់ស្ទង់មតិពីពលរដ្ឋមួយចំនួនតាមសណ្ឋានដែលបានបែងចែកគន្លងមក បើគិតឱ្យស៊ីជម្រៅយើងសង្កេតឃើញថា រាល់ការយល់ដឹង និងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងកម្ពុជាមានភាពកាន់តែប្រសើរឡើង តែក៏នៅមានកម្រិតនៅឡើយ តម្រូវឱ្យមានសកម្មភាពផ្សេងៗពាក់ព័ន្ធនឹងការជម្រុញ បណ្តុះបណ្តាល ណែនាំបន្ថែមពីបច្ចេកវិទ្យាឌីជីថលនេះ។ បន្ថែមពីនេះត្រូវធ្វើយ៉ាងណាត្រូវមានកំណែទម្រង់ថ្មីក្នុងវិស័យអប់រំ ឱ្យមានភាពជឿនលឿន និងប្រសិទ្ធភាពចំពោះភាពជឿជាក់លើប្រព័ន្ធឌីជីថលរបស់មូលធនមនុស្សក្នុងប្រទេសកម្ពុជា។

### ៣.៥.១. ភាពខ្លាំងនៃការចាប់យកបច្ចេកវិទ្យាឌីជីថលលើមូលធនមនុស្ស

បន្ទាប់ពីបានធ្វើការស្រាវជ្រាវដោយការវាស់ស្ទង់មតិរួចមក ចំពោះការយល់ដឹងពីបច្ចេកវិទ្យាឌីជីថល និងអក្ខរកម្មឌីជីថលនៅក្នុងវិស័យការងារ គ្រប់ស្ថាប័នបច្ចុប្បន្នបានកំពុងពេញនិយមប្រើប្រាស់បច្ចេកវិទ្យាទាំងនេះដើម្បីជាជំនួយពិសេសក្នុងដំណើរនៃការបំពេញកិច្ចការងារនៃស្ថាប័ននីមួយៗឱ្យមានភាពរលូន និងមានសក្តានុពល ។ បន្ថែមពីនោះតាមស្ថាប័នក៏កំពុងធ្វើការបណ្តុះបណ្តាលមន្ត្រី និង បុគ្គលិកទាក់ទងនឹងជំនាញឌីជីថលតាមមធ្យោបាយផ្សេងៗដូចជាការសិក្ខាសាលា ការបង្កើតវគ្គបណ្តុះបណ្តាលខ្លីៗជាដើម ។ ចំណែកឯយុវជន និង

សិស្សានុសិស្សសុទ្ធសឹងតែទទួលបានការបណ្តុះបណ្តាលបច្ចេកវិទ្យាឌីជីថលស្ទើរគ្រប់តំបន់ យោងតាមទិន្នន័យនៃការស្ទង់មតិចំនួនអ្នកទទួលបានការបណ្តុះបណ្តាលបច្ចេកវិទ្យាឌីជីថលនៅទីក្រុងមានចំនួនច្រើនជាងអ្នកនៅតាមបណ្តាខេត្ត ។ បញ្ជាក់ឱ្យឃើញថា អ្នកនៅទីក្រុងមានអតិភាពច្រើនក្នុងការទទួលបានការអប់រំ សិក្សាផ្ទាល់ និងអនឡាញក្នុងវិស័យឌីជីថលនេះ ដោយហេតុថា អ្នកមានជំនាញឌីជីថលនៅទីក្រុងមានសមត្ថភាពក្នុងការដឹកនាំបណ្តុះបណ្តាលដល់យុវជន និងសិស្សានុសិស្សឱ្យទទួលបាននូវចំណេះដឹងក្នុងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលនេះក្នុងការបម្រើដល់ការសិក្សា ការងារ មុខរបរអាជីពជាដើម ពីព្រោះតម្រូវការអ្នកជំនាញឌីជីថល តម្រូវឱ្យចេះជំនាញឌីជីថលមានអត្រាខ្ពស់ក្នុងរាជធានីភ្នំពេញដែលបច្ចុប្បន្នប្រទេសកម្ពុជាកំពុងអភិវឌ្ឍ និងវិវត្តទៅរកសេដ្ឋកិច្ចឌីជីថល។ យ៉ាងណាមិញតាមបណ្តាលខេត្តត្បិតតែមានដំណើរយឺតនៃឌីជីថលជាងទីក្រុងក៏ពិតមែន តែក៏នៅតែមានយុវជន និងសិស្សានុសិស្សមួយចំនួនធំបានកំពុងទទួលបានការបណ្តុះបណ្តាលពីបច្ចេកវិទ្យាឌីជីថលនេះផងដែរ តាមរយៈសិក្សាក្នុងថ្នាក់ផ្ទាល់ និងតាមអនឡាញ។

### ៣.៥.២. ភាពខ្សោយនៃការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងការបណ្តុះបណ្តាល ៖

បច្ចេកវិទ្យាឌីជីថល បានដើរតួយ៉ាងសំខាន់ក្នុងការជម្រុញកំណើតសេដ្ឋកិច្ច ទន្ទឹមនឹងនេះ បញ្ហាមូលធនមនុស្សនៅមាន កង្វះធនធានមនុស្ស កង្វះចំណេះដឹង កង្វះជំនាញបច្ចេកទេស និងបទពិសោធន៍ ។ ផ្អែកតាមលទ្ធផលនៃការស្រាវជ្រាវ អត្ថប្រយោជន៍នៃការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលរបស់ស្ថាប័នរដ្ឋនិងស្ថាប័នឯកជនហាក់បីដូចជា មិនមានអ្វីប្រែប្រួល អត្ថប្រយោជន៍ទទួលបានពីការប្រើប្រាស់មានលក្ខណៈប្រហាក់ប្រហែលគ្នាមិនមានអ្វីខុសគ្នា ក៏ព្រោះតែកម្រិតមូលធនមនុស្សជំនាញឌីជីថល នៅក្នុងស្ថាប័ននីមួយៗមានចំណេះជំនាញប្រហាក់ប្រហែលគ្នា អាចនិយាយបានថាធនធានមនុស្សជំនាញឌីជីថលនៅមានកម្រិត មិនទាន់មានអ្នកចេះជំនាញឌីជីថលមួយនេះច្រើននៅឡើយ ។

ចំពោះការទទួលបានការបណ្តុះបណ្តាលពាក់ព័ន្ធនឹងបច្ចេកវិទ្យាឌីជីថលវិញ ការបណ្តុះបណ្តាលបុគ្គលិករបស់ស្ថាប័នឯកជនទទួលបានច្រើនជាងស្ថាប័នរដ្ឋ ដោយសារនៅស្ថាប័នរដ្ឋមួយចំនួននៅមិនទាន់រៀបចំ ផែនការអភិវឌ្ឍមូលធនមនុស្ស ទាក់ទងនឹងកម្មវិធីបណ្តុះបណ្តាលដល់មន្ត្រី គ្រប់ជ្រុងជ្រោយនៅឡើយទេ ។ ម៉្យាងវិញទៀត ចំណាប់អារម្មណ៍ចំពោះឌីជីថលនៅក្នុងស្ថាប័នរដ្ឋមិនសូវពេញនិយម ក្នុងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលនេះទាំងស្រុងនោះទេ តួយ៉ាងនៅក្នុងស្ថាប័ននៅកំពុងប្រើវិធីសាស្ត្របែបបុរាណ បូករួមជាមួយបច្ចេកវិទ្យាឌីជីថលនៅឡើយ ។

ចំណែកឯការសិក្សាអំពីបច្ចេកវិទ្យាឌីជីថលរបស់យុវជន និង សិស្សានុសិស្សតាមរយៈអនឡាញចេះជាងការសិក្សាផ្ទាល់ មូលហេតុនៃការសិក្សាផ្ទាល់ចេះតិចបណ្តាលមកពីកត្តាមួយចំនួន ដោយហេតុថាការសិក្សាដោយផ្ទាល់បានត្រឹមរៀនពីទ្រឹស្តីជាក់ស្តែង ក៏ប៉ុន្តែយុវជន និង សិស្សានុសិស្សនៅខ្វះខាតការស្រាវជ្រាវបន្ថែមតាមប្រព័ន្ធអ៊ីនធឺណិត និង មិនសូវមានការអនុវត្តផ្ទាល់ជាមួយការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ។

### ៣.៥.៣. ប្រសិទ្ធភាពនៃបច្ចេកវិទ្យាឌីជីថលលើមូលធនមនុស្ស ៖

មូលធនមនុស្សមួយចំនួនធំបានដឹងកំពុងប្រើប្រាស់ថ្នាលបច្ចេកវិទ្យាឌីជីថល ដើម្បីទទួលបានសេវាសង្គមទូលំទូលាយ ដោយយុវជនទូទៅនិង សិស្សនិស្សិត អាចទាញយកឯកសារស្រាវជ្រាវព័ត៌មានលើបណ្តាញសង្គមជាដើម ។ចំពោះរាល់ការប្រើប្រាស់ប្រព័ន្ធឌីជីថលរបស់បុគ្គលម្នាក់ៗបានផ្តលភាពងាយស្រួលឱ្យពួកគេអាចមានទំនាក់ទំនងគ្នាទៅវិញទៅមកបានលឿនសម្រាប់ការងារសិក្សា និងមុខរបរអាជីពបានដំណើរការឆាប់រហ័ស និងចំណេញពេលវេលា ។ ដោយឡែកបន្ទាប់ពីជម្ងឺរីករាលដាលនៃជម្ងឺកូវីដ១៩រួចមក សេវាឌីជីថលចាប់ផ្តើមមាន និង មានអ្នកប្រើប្រាស់គួរឱ្យកត់សម្គាល់ ក្នុងនោះមូលធនមនុស្សយើងចាប់ផ្តើមពេញនិយម ទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិច និង ការប្រប្រាស់ផ្សេងៗផ្អែកលើថ្នាលបច្ចេកវិទ្យាឌីជីថល ។ ជាពិសេសយើងឃើញមានការប្រើប្រាស់សេវាអ៊ីនធើណិត សម្រាប់ការសិក្សា និង កាងារ និង សម្រាប់កម្សាន្តនានាដូចជា៖ Facebook, Messenger, Telegram, Instagram, ជាដើម ដើម្បីជំនួយដល់ជីវភាពរស់នៅប្រចាំថ្ងៃក្នុងការទទួលបាននូវព័ត៌មានសង្គម និង ព័ត៌មានសេដ្ឋកិច្ចបានឆាប់រហ័សជាដើម ។

### ៣.៥.៤. ផលប៉ះពាល់នៃបច្ចេកវិទ្យាឌីជីថលលើមូលធនមនុស្ស ៖

នៅក្នុងសង្គមកម្ពុជាការកសាងសបង្គមឌីជីថល និង ការកសាងប្រទេសជាតិឱ្យមានការរីកចម្រើនសេដ្ឋកិច្ចឌីជីថល បង្កឱ្យមានផលប៉ះពាល់មួយចំនួនផងដែរជាក់ស្តែង ផលប៉ះពាល់ទៅលើសង្គមការប្រើប្រាស់ ប្រព័ន្ធឌីជីថល ឬហៅបានប្រព័ន្ធអ៊ីនធឺណិតអាចបាត់បង់ឯកជនភាពនៃទិន្នន័យផ្ទាល់ខ្លួនដែលត្រូវក្រុមហ៊ុនគ្រប់គ្រងប្រព័ន្ធ និង បច្ចេកវិទ្យាទាំងនោះអាចតាមដានរាល់ទិន្នន័យឯកជនភាពរបស់អ្នកប្រើប្រាស់ និង ទំនាក់ទំនងផ្សេងៗដែលកើតមានឡើង ។ ជាមួយគ្នានេះក៏មានជនខិលខូចបានបង្កើត ព័ត៌មានមិនពិត និង ព័ត៌មានក្លែងក្លាយធ្វើឱ្យអ្នកប្រើប្រាស់មានការភាន់ច្រឡំ ជាមួយការគំរាមកំហែងតាមព័ន្ធអនឡាញ ដោយអ្នកប្រើប្រាស់ឧបករណ៍ដូចជា ទូរស័ព្ទ កុំព្យូទ័រ ភ្ជាប់ជាមួយប្រព័ន្ធអ៊ីនធើណិតអាចកើតមានឧក្រិដ្ឋកម្មតាមរយៈការហេកទិន្នន័យឯកជនភាពជាដើម ។ ឧក្រិដ្ឋកម្មទាំងនេះអាចមានផលប៉ះពាល់ដល់សុវត្ថភាពរបស់អ្នកប្រើប្រាស់ប្រព័ន្ធឌីជីថល ផ្នែកហិរញ្ញវត្ថុ និង ឯកជនភាពដែលអាចធ្វើឱ្យសំណាកអ្នកប្រើប្រាស់បាត់បង់ភាពជឿជាក់លើប្រព័ន្ធឌីជីថើ ។ ចំណែក ឯផលប៉ះពាល់ទៅលើសេដ្ឋកិច្ចបច្ចុប្បន្នការងារ មុខរបរបែបប្រពៃណី អាចប្រឈមនិងបាត់បង់ដោយសារខណៈប្រទេសកម្ពុជាកំពុង អភិវឌ្ឍជាមួយវិស័យបច្ចេកវិទ្យាឌីជីថល ដែលទាមទារមូលធនមនុស្សមានចំណេះជំនាញបច្ចេកទេសពាក់ព័ន្ធនិងបច្ចេកវិទ្យាឌីជីថលយ៉ាងខ្លាំង ជាហេតុធ្វើឱ្យពួកគេពិបាកប្រកមមុខរបរស្វែងរកការងារធ្វើឱ្យតាមទីផ្សារ ដែលមានតម្រូវការចាំបាច់ ។

# សេចក្តីសន្និដ្ឋាន និង អនុសាសន៍

# សេចក្តីសន្និដ្ឋាន និង អនុសាសន៍

## ➤ សេចក្តីសន្និដ្ឋាន

ជារួមមកតាមរយៈការបកស្រាយខាងលើ យើងអាចសន្និដ្ឋានបានថាសេដ្ឋកិច្ចឌីជីថលពិតជាមានសក្តានុពល យ៉ាងខ្លាំងសម្រាប់ប្រទេសកម្ពុជា ដោយសារតែសេដ្ឋកិច្ចឌីជីថលបានជំរុញការពង្រីកទីផ្សាររបស់សហគ្រាសធុន តូច និងមធ្យម (SME) ជំរុញសកម្មភាពពាណិជ្ជកម្ម និងធុរកិច្ច ក៏ដូចជាពង្រីកការតភ្ជាប់នឹងខ្សែច្រវាក់ផលិតកម្ម និងខ្សែច្រវាក់តម្លៃតំបន់និងសកល។ លើសពីនេះទៅទៀត សេដ្ឋកិច្ចឌីជីថលថែមទាំងបានបង្កើតការងារថ្មីៗ ជំនាញថ្មីៗ ជំរុញការវិនិយោគក្នុងវិស័យ ITC និងបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈថែមទៀតផង។ លើសពីនេះទៅទៀត ឌីជីថលូបនីយកម្មបានបង្កើតឱ្យមានប្រក្រតីភាពថ្មី ដែលជួយសម្រួលដល់ការធ្វើការពីចម្ងាយ ការសិក្សាពីចម្ងាយ ការទទួលព័ត៌មាន ការប្រាស្រ័យទាក់ទង និងរបៀបរបបរស់នៅប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជា។ តែទោះជាយ៉ាងណាក្តី ក៏បរិវត្តកម្មឌីជីថលនៅតែបង្កជាឧបសគ្គមួយចំនួនដល់កម្ពុជា។

គួរយ៉ាង ការបំផ្លាញទម្លាប់ចាស់ តាមរយៈការជ្រាបចូលនៃវត្តមានរបស់បច្ចេកវិទ្យា ឌីជីថលមកក្នុងសេដ្ឋកិច្ចកម្ពុជានេះ នឹងនាំមកនូវការផ្លាស់ប្តូររចនាសម្ព័ន្ធកម្លាំងពលកម្មនិងការងារ ការប្រែប្រួល មូលដ្ឋាននៃការប្រមូលពន្ធ ការបង្វែរអាទិភាពនៃចំណាយវិនិយោគសាធារណៈ កង្វះនៃការចាប់យកការប្រើ ប្រាស់ឌីជីថល គម្លាតឌីជីថល និងបញ្ហាពាក់ពន្ធនឹងសន្តិសុខសាយប័រ។ ការណ៍នេះតម្រូវឱ្យមានការចូលរួម យ៉ាងសកម្មពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាការព្យាយាមសម្របទៅនឹងប្រក្រតីភាពថ្មី ការពង្រឹងជំនាញ ឌីជីថល និងការចាប់យកឌីជីថលរបស់ប្រជាជនកម្ពុជា។ ថ្វីត្បិតតែការផ្លាស់ប្តូរទៅសេដ្ឋកិច្ចឌីជីថលនេះនាំមក នូវឧបសគ្គមួយចំនួនក៏ពិតមែន តែរាជរដ្ឋាភិបាលកម្ពុជាបានព្យាយាមយ៉ាងខ្នះខ្នែងនៅក្នុងការបង្កើតគោល នយោបាយដែលជំរុញដល់បរិវត្តកម្មនេះ ក៏ដូចជាការបង្កើតឲ្យមានច្បាប់ការពារផ្សេងៗ ដើម្បីពង្រឹងសុខសន្តិភាព និងការទុកចិត្តទៅលើសេវាកម្មឌីជីថល។

បើយោងតាមទិន្នន័យពីការស្ទង់មតិខាងលើ យើងអាចសន្និដ្ឋានបានថាសព្វថ្ងៃយុវជនកម្ពុជាអាច សម្របខ្លួនទៅនឹងឌីជីថូបនីយកម្មបានជាច្រើន។ ការបកស្រាយខាងលើបានបង្ហាញថា អ្នកចូលរួមទាំងអស់ សុទ្ធតែមានឧបករណ៍ឌីជីថលសម្រាប់ប្រើប្រាស់ ដោយពុំមាននរណាម្នាក់បានរាយការណ៍ថា ពួកគេគ្មាន ឧបករណ៍ឌីជីថលសម្រាប់ប្រើប្រាស់នោះទេ យ៉ាងហោចក៏ពួកគេមានឧបករណ៍មួយសម្រាប់ប្រាស្រ័យទាក់ទង ដែរ។ ហើយម្យ៉ាងវិញទៀតពួកគេសុទ្ធតែបានធ្លាប់ដឹងនិងសិក្សាអំពីឌីជីថល ព្រមទាំងបានប្រើប្រាស់វាសម្រាប់សម្រួលដល់ជីវភាពប្រចាំថ្ងៃផងដែរមិនថានៅទីក្រុង ឬក៏ជនបទនោះទេ ។ មួយវិញទៀតការសម្ភាន់នៃការស្ទង់មតិនេះគឺផ្តោតសំខាន់ទៅលើធនធានដែលគាត់ស្គាល់និង មានជំនាញឌីជីថល ដែលទិន្នន័យបានបង្ហាញយើងឃើញថាវាពិតជាមានកំណើននាក់ដែលគាត់បានដឹង និង បានស្គាល់ពីអត្ថប្រយោជន៍របស់ឌីជីថលពិតមែន ហើយ ចំពោះយុវជននិង សិស្សានិសិស្ស ដែលគាត់កំពុងតែសិក្សារៀនសូត្រ ពួកគេក៏បានបង្ហាញឱ្យយើងដឹងថាទោះពួកគេរវល់ និងសិក្សាក៏ពួកគេបានចំណាយពេលបន្តិចបន្តួចសិក្សាអំពីឌីជីថលផងដែរ ព្រោះពួកគេបានយល់ដឹងថាបច្ចុប្បន្ន និង ទៅអនាគតឌីជីថលដើរតួរយ៉ាងសំខាន់ក្នុង សកម្មភាព និងជីវភាពប្រចាំថ្ងៃរបស់ពួកគេ ។

សរុបមកការអភិវឌ្ឍពលរដ្ឋឌីជីថលពិតជាមានសារៈសំខាន់នៅក្នុងការធ្វើឱ្យកម្ពុជាឈានទៅរកសេដ្ឋកិច្ចឌីជីថលដែលពេញលេញមួយ ហេតុនេះហើយនៅក្នុងការវាស់ស្ទង់មតិមួយនេះក៏បានធ្វើការសួរទៅកាន់យុវជន និងសិស្សានុសិស្សដែល ចំនួនទិន្នន័យ ១០៣នាក់បានស្គាល់អំពីឌីជីថលក្នុងនោះ (៦១%)បានសិក្សាពីឌីជីថលតាមរយៈការសិក្សារដោយផ្ទាល់ និង (៣៩%) បានសិក្សាតាមបណ្ដាញសង្គម ដែលសរុបទិន្នន័យទាំងនេះអ្នកដែលបានយកចំណេះដឹងដែលបានសិក្សាមកប្រើប្រាស់មាន(៧៩%)ពួកគាត់ប្រប្រាស់ច្រើន និង (២១%) គាត់បានយកចំណេះដឹងទាំងនោះយកមកប្រើខ្លះៗ ដែលទិន្នន័យទាំងនោះក៏បង្ហាញដែរថាពួកគាត់ទទួលបានអត្ថប្រយោជន៍ស្ទើរតែស្មើគ្នាពីឌីជីថលដែលបានជំនួយដល់ សកម្មភាពប្រចាំថ្ងៃនិង ការសិក្សារ ស្រាវជ្រាវរបស់ពួកគេឱ្យកាត់តែជឿនលឿនមួយកម្រិតទៀត ។ មិនតែប៉ុណ្ណោះសូម្បីតែបុគ្គលដែលបំពេញការងារក្នុងស្ថាប័នទាំងពីរក៏បានបញ្ចេញមតិដែរ ថាក្នុងស្ថាប័នទាំងពីរមានគឺសុទ្ធតែប្រើប្រាស់ឌីជីថលគ្រាន់ តែ(៧៥%)គឺពួកគាត់បានចំណាយពេលនិង ប្រើប្រាស់ឌីជីថលច្រើននិង (២៥%) ពួកគេប្រើខ្លះៗសម្រាប់បំពេញការងាររបស់គាត់ ។ ទាំងនេះសបញ្ជាក់អោយយើងដឹងថា ទោះបីជាក្នុងលក្ខណ្ឌណាក៏បច្ចុប្បន្ននេះប្រជាពលរដ្ឋគាត់បានប្រើប្រាស់ឌីជីថលសម្រាប់សំរាលដល់កិច្ចការប្រចាំថ្ងៃពួកគេដែរគ្រាត់តែការយល់ដឹងអំពីឌីជីថលពួកគាត់នៅមានកម្រិត ព្រោះថា(៥០%) នៃពួកគេមានជំនាញជាមួយឌីជីថល និង (៥០%)ទៀតគាត់អាចប្រើប្រាស់បានតែគ្រាន់តែមិនទាន់សូវមានជំនាញទៅលើវានៅឡើយ ។

- **អនុសាសន៍**

នៅក្នុងយុគសម័យឌីជីថល ប្រទេសកម្ពុជាកំពុងវិវត្តទៅរកសេដ្ឋកិច្ចឌីជីថលមួយ ផ្អែកតាម **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១** របស់រាជរដ្ឋាភិបាលអាណត្តិថ្មី ដែលកំណត់យក **អាទិភាពគន្លឹះ ៥** គឺ មនុស្ស, ផ្លូវ, ទឹក, ភ្លើង និងបច្ចេកវិទ្យា ជាពិសេស គឺ **បច្ចេកវិទ្យាឌីជីថល** ដើម្បីឆ្លើយតបទៅនឹងបដិវត្តឧស្សាហកម្មទី៤ និងបរិវត្តកម្មឌីជីថលនៃសេដ្ឋកិច្ច និងសង្គមកម្ពុជា ។ នៅក្នុងបញ្ចកោណទី១ ៖ ការអភិវឌ្ឍមូលធនមនុស្ស គឺជាលក្ខខណ្ឌចាំបាច់មិនអាចខ្វះបានសម្រាប់ជំរុញពិពិធកម្ម និងកំណើនសេដ្ឋកិច្ច ប្រកបដោយបរិយាបន្ន និងភាពធន់ ។ មូលធនមនុស្ស មានគុណភាពខ្ពស់ និង សុខភាពល្អ គឺជាទ្រព្យសកម្មជាតិដ៏រឹងមាំ សម្រាប់បង្កើនតម្លៃសេដ្ឋកិច្ច លើកកម្ពស់តម្លៃវប្បធម៌ និងបង្កើតគំនិតថ្មីៗ សំដៅធានាចីរភាពកំណើនរយៈពេលវែង និង ការអភិវឌ្ឍមូលធនមនុស្ស មានសារៈសំខាន់ ដើម្បីឆ្លើយតបទៅនឹងកើនឡើងនៃតម្រូវការការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ក្នុងន័យនេះ រាជរដ្ឋាភិបាលផ្តោតលើអាទិភាព ៥ ៖[17]

- **ការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា** ៖ គោលដៅជាយុទ្ធសាស្ត្រ គឺការបង្កើតបរិយាកាសល្អ សម្រាប់ការអប់រំ និងការបណ្តុះបណ្តាល ប្រកបដោយគុណភាព និង ជំនាញខ្ពស់ ដោយផ្តោតលើ ការពង្រឹងអភិបាលកិច្ចនៃការគ្រប់គ្រងនៅតាមគ្រឹះស្ថានសិក្សា ការពង្រឹងគុណភាពនៃការបណ្តុះ

[17] យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ https://www.ocm.gov.kh/pentagonal-strategy/

បណ្តាលគ្រប់គម្រិត ការបង្កើនគុណភាព និង ការចូលរៀនមុខវិជ្ជា វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈ និង គណិតវិទ្យា(STEAM) និង ការពង្រឹងការអប់រំកាយ និង កីឡា ។

➢ **ការបណ្តុះបណ្តាលជំនាញបច្ចេកទេស** ៖ គោលដៅជាយុទ្ធសាស្ត្រ គឺការធ្វើបរិវត្តកម្មការបណ្តុះបណ្តាលជំនាញបច្ចេកទេស និង វិជ្ជាជីវៈ ការបង្កើនការចុះឈ្មោះចូលរៀន ការរៀបចំជំនាញឡើងវិញ និង ការបង្កើនជំនាញ (Reskilling and Upskilling) ការពង្រឹងប្រព័ន្ធអេកូឡូស៊ីអភិវឌ្ឍជំនាញ ការដោះស្រាយបញ្ហានៃភាពមិនស៊ីចង្វាក់គ្នា រវាងការបណ្តុះបណ្តាល និង តម្រូវការ ទាំងប្រភេទ និង គុណភាពជំនាញ និងការពង្រឹង ការតាមដាន ការត្រួតពិនិត្យ និង ការវាយតម្លៃ ការអនុវត្តគោលនយោបាយ និង យុទ្ធសាស្ត្រដែលបានដាក់ចេញ ។

➢ **ការលើកកម្ពស់សុខភាព និង សុខុមាលភាពប្រជាជន** ៖ គោលដៅជាយុទ្ធសាស្ត្រ គឺការកាត់បន្ថយអត្រាឈឺ និង ស្លាប់ បណ្តាលពីជំងឺមិនឆ្លងចម្បងៗ ការលើកកម្ពស់សុខភាពបន្តពូជ សុខភាពទារក កុមារ និង មាតា ការពង្រឹងសមត្ថភាពស្ថាប័ន ក្នុងការដឹកនាំបរិវត្តកម្ម និង អភិបាលកិច្ច ក្នុងវិស័យសុខាភិបាល ការបន្តបង្កើនគុណភាព និង សមត្ថភាពរោគវិនិច្ឆ័យ ក្នុងការព្យាបាល និងការថែទាំ ការបន្តពង្រឹងគុណភាពនៃការបណ្តុះបណ្តាលវិជ្ជាជីវៈសុខាភិបាល ការលើកម្ពស់សមត្ថភាពជំនាញ ការលើកកម្ពស់កិច្ចសហការរវាងក្រសួងពាក់ព័ន្ធ និង ការចូលរួមរបស់ប្រជាជនតាមសហគមន៍ ។

➢ **ការពង្រឹងប្រព័ន្ធគាំពារសង្គម និង ប្រព័ន្ធស្បៀង**៖ គោលដៅជាយុទ្ធសាស្ត្រ គឺការកសាងនិងការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម ឱ្យមានលក្ខណៈប្រមូលផ្តុំ និង សន្តិភាព ទាំងក្នុងប្រព័ន្ធជំនួយសង្គម និង ប្រព័ន្ធសន្តិសុខសង្គម និង ការពង្រឹងប្រព័ន្ធស្បៀងដែលផ្តល់សន្តិសុខស្បៀង និង អាហារូបត្ថម្ភ សម្រាប់ប្រជាជនគ្រប់រូប ។

➢ **ការពង្រឹងភាពជាពលរដ្ឋក្នុងសង្គម ដែលមានអារ្យធម៌ខ្ពស់ប្រកបដោយសីលធម៌ សមធម៌ និង បរិយាបន្ន** ៖ គោលដៅជាយុទ្ធសាស្ត្រ គឺការធ្វើពលភាវូបនីយកម្មពលរដ្ឋ (People Revitalization) ឱ្យមានសមត្ថភាព ផលិតភាព សីលធម៌ គុណធម៌ ចរិយាធម៌ ភាពអំណត់ សុចរិតភាព វិន័យ និង ការទទួលខុសត្រូវខ្ពស់ និង ការលើកកម្ពស់ស្មារតី និង មនសិកាស្នេហាជាតិ ការពារជាតិ ឯកភាពជាតិ ការចេះយកអាសាគ្នា ការចែករំលែក ការចូលរួម គុណតម្លៃសង្គម និង ស្មារតី គោរពច្បាប់ ស្រឡាញ់សន្តិភាព វប្បធម៌ ប្រពៃណីទំនៀមទម្លាប់ អំពើល្អ និង យុត្តិធម៌ សំដៅធានាបាននូវសិនិទ្ធភាពសង្គម ( Social Cohesion) និង សុខដុមរមនាសង្គម ។

ការឈានទៅរកសេដ្ឋកិច្ចឌីជីថលពិតណាស់តម្រូវឱ្យមានមូលធនមនុស្សមានចំណេះដឹង ជំនាញឌីជីថលចូលរួមក្នុងសកម្មភាព ជាកត្តាជំរុញដល់បរិវត្តកម្មឌីជីថលកម្ពុជា ។ ជាមួយគ្នានេះ យើងបានធ្វើការស្ទង់មតិទាក់ទងនឹងចំណេះដឹងបច្ចេកវិទ្យាឌីជីថល ដោយមានការចូលរួមពីមូលធនមនុស្សក្នុងវិស័យការងារ និង យុវជនសិស្សានុសិស្ស ដើម្បីជាថ្នាលមួយក្នុងការកែលំអបន្ថែមនូវចំណុចខ្វះខាតនៃចំណេះ ជំនាញបច្ចេកវិទ្យាឌីជីថលនេះ ។ ខាងក្រោមនេះ ជាអនុសាសន៍មួយចំនួនដែលស្ថាប័នពាក់ព័ន្ធ និង យុវជន អាចធ្វើការផ្តោតសំខាន់ដើម្បីជាស្ពានអាចឈានទៅរកសេដ្ឋកិច្ចឌីជីថលរួមគ្នាប្រកបដោយចីរភាព៖

➢ **វិស័យការងារ៖**

នៅក្នុងស្ថាប័នរដ្ឋ និងស្ថាប័ឯកជន យើងឃើញមានមន្ត្រី ឬ បុគ្គលិកចេះជំនាញឌីជីថលបានច្រើនគួរសម តែ ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និង ការទទួលបានការបណ្តុះបណ្តាលជំនាញឌីជីថលនៅមានកម្រិត ។ ដូច្នេះ

ស្ថាប័នពាក់ព័ន្ធគួរតែធ្វើយ៉ាងណាមានកំណែទម្រង់ថ្មី ដោយជំរុញ និងលើកទឹកចិត្តឱ្យមន្ត្រី ឬ បុគ្គលិកចូលរួមសិក្ខាសាលា និង ទទួលបានការបណ្តុះបណ្តាលពាក់ព័ន្ធនឹងបច្ចេកវិទ្យាឌីជីថលបន្ថែមឱ្យបានច្រើន និង គ្រប់គ្នា ។ ម្យ៉ាងទៀត មន្ត្រី និង បុគ្គលិក គួរណាតែព្យាយាម ខិតខំបង្កើនសមត្ថភាពបន្ថែម និង ខំបង្កើនជំនាញបន្ថែមដោយការចាប់យកជំនាញឌីជីថលជាចម្បង ដើម្បីឱ្យការងារក្នុងស្ថាប័ននីមួយៗមានភាពរីកចម្រើន និងមានភាពជឿនលឿនផ្នែកវិស័យឌីជីថលកាន់តែប្រសើរ សមស្របនឹងគោលដៅយុទ្ធសាស្ត្ររបស់ រដ្ឋាភិបាល។

- **យុវជន និង សិស្សានុសិស្ស៖**

យុវជន និង សិស្សមួយចំនួន ភាគច្រើនចំពោះការយល់ដឹងអំពីសេដ្ឋកិច្ចឌីជីថលនៅមានកម្រិត ។ បច្ចុប្បន្នការសិក្សាស្រាវជ្រាវរកគំនិតថ្មីៗក្នុងការសិក្សារៀនសូត្រ និងសិក្សាពីអ្វីដែលថ្មីៗដោយការប្រើប្រាស់ជាមួយបច្ចេកវិទ្យាឌីជីថល គឺមានភាពទូលំទូលាយនឹងសម្បូរបែបណាស់។ អាស្រ័យហេតុនេះ យុវជន និង សិស្សានុសិស្ស គួរតែធ្វើការស្រាវជ្រាវបន្ថែមជាមួយកម្មវិធីផ្សេងៗ និង ចូលរួមទទួលយកការបណ្តុះបណ្តាលឱ្យបានច្រើន និង ជ្រើសជំនាញសិក្សាឱ្យបានត្រឹមត្រូវ ដែលជាតម្រូវការទីផ្សារនាពេលបច្ចុប្បន្ន និង នាពេលអនាគត នោះជាជំនាញឌីជីថល ដែលជាថ្នាលមូលធនមនុស្សជំនាញឌីជីថលក្នុងការវិវឌ្ឍទៅរកសេដ្ឋកិច្ចឌីជីថល ។

# ឯកសារយោង

# ឯកសារយោង

## ឯកសារយោងជាភាសាខ្មែរ


គោលនយោបាយរដ្ឋាភិបាលឌីជីថល ២០២២-២០៣៥

https://mptc.gov.kh/2022/02/%E1%9E%82%E1%9F%84%E1%9E%9B%E1%9E%93%E1%9E%99%E1%9F%84%E1%9E%94%E1%9E%B6%E1%9E%99%E1%9E%9A%E1%9E%8A%E1%9F%92%E1%9E%8B%E1%9E%B6%E1%9E%97%E1%9E%B7%E1%9E%94%E1%9E%B6%E1%9E%9B%E1%9E%8C%E1%9E%B8%E1%9E%87/

ក្របខណ្ឌគោលនយោបាយ សេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥

https://mptc.gov.kh/2021/05/%E1%9E%80%E1%9F%92%E1%9E%9A%E1%9E%94%E1%9E%81%E1%9E%8E%E1%9F%92%E1%9E%8C%E1%9E%82%E1%9F%84%E1%9E%9B%E1%9E%93%E1%9E%99%E1%9F%84%E1%9E%94%E1%9E%B6%E1%9E%99%E1%9E%9F%E1%9F%81%E1%9E%8A%E1%9F%92%E1%9E%8B/

ផែនទីបង្ហាញផ្លូវអភិវឌ្ឍន៍ជំនាញឌីជីថលនៅកម្ពុជា ២០២៤-២០៣៥

https://www.information.gov.kh/articles/127391

ក្រសួងសេដ្ឋកិច្ចសេដ្ឋកិច្ច និងហិរញ្ញវត្ថុ https://mef.gov.kh/

គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល https://digitaleconomy.gov.kh/index

មជ្ឈមណ្ឌលកម្ពុជា ៤.0 https://cambodia4point0.org/kh

យុទ្ធសាស្ត្របញ្ចកោណ (ដំណាក់កាលទី១)

https://asset.cambodia.gov.kh/mptc/2023/08/KH-PENTAGONAL-STRATEGY-PHASE-I.pdf

បដិវត្តន៍ឧស្សាហកម្មទី៤ ( ឧស្សាហកម្ម ៤.0)

https://cd-center.org/wp-content/uploads/2019/06/P127_20190604_V1IS3_KH.pdf

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១៖ កម្រងសំណួរ

ជម្រាបសួរអ្នកទាំងអស់គ្នា យើងខ្ញុំជានិសិត្សឆ្នាំទី៤ នៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ផ្នែកសេដ្ឋកិច្ចអភិវឌ្ឍន៍ ដែលបច្ចុប្បន្ននេះពួកខ្ញុំបានជ្រើសរើសយកការសរសេរសារណាសម្រាប់បញ្ចប់ឆ្នាំក្រោមប្រធានបទស្តីអំពី **ការកសាងធនធានមនុស្សក្នុងវិស័យនវានុវត្តឌីជីថល** ។ ដែលការសរសេរសារណានេះដែរគឺមានកម្រងសំណួរមួយចំនួនហើយទាំងនោះវាពិតជាមានសារសំខាន់ណាស់ចំពោះយើងខ្ញុំ មួយវិញទៀតក៏អាចដឹងអំពីស្ថានភាពនៅក្នុងស្ថាប័នមួយចំនួនថាតើមានប្រើប្រាស់ឌីជីថល ឬ ក៏សម្បូរធនធានដែលមានជំនាញឌីជីថលដែរឬទេនិងផ្សេងៗទៀត ។

ដែលសំណួរទាំងនោះយើងបានជ្រើសរើសមានដូចជា ៖

- **ចំពោះស្ថាប័នរដ្ឋ និង ឯកជន**

**១, បំពេញឈ្មោះ**( **នាម និង គោត្តនាម** )

..........................................................................................................................................

**២, ភេទ**

☐ ស្រី
☐ ប្រុស
☐ សូមមិនចែករំលែក

**៣, ទីលំនៅបច្ចុប្បន្ន**

☐ ទីក្រុង
☐ ទីជនបទ

**៤, តើបច្ចុប្បន្នអ្នកកំពុងធ្វើការនៅស្ថាប័នរដ្ឋឬស្ថាប័នឯកជន ?**

☐ ស្ថាប័នរដ្ឋ

☐ ស្ថាប័នឯកជន

**៥, តើអ្នកស្គាល់ជំនាញឌីជីថលនិងធ្លាប់ឃើញបច្ចេកវិទ្យាឌីជីថលពីមុនមកទេ ?**

ជំនាញឌីជីថល សំដៅដល់សមត្ថភាពក្នុងការប្រើប្រាស់ឧបករណ៍ទំនាក់ទំនង កម្មវិធីទំនាក់ទំនង និងបណ្តាញសង្គមជាដើម ដើម្បីអាចចូលទៅប្រើប្រាស់ទិន្នន័យ និងគ្រប់គ្រងព័ត៌មាន។ ឧទាហរណ៍៖ ការប្រើប្រាស់អ៊ីនធឺណិតសម្រាប់ការទំនាក់ទំនងដូចជា Telegram, Messenger, Facebook, Instagram, Line និង Twitter ជាដើម។

បច្ចេកវិទ្យាឌីជីថល មានដូចជា វិទ្យាសាស្ត្រកុំព្យូទ័រ (Computer Science) ទូរគមនាគមន៍និងបណ្ដាញ (Telecoms and Networking) បច្ចេកវិទ្យាក្លោដ (Cloud Computing) ការអភិវឌ្ឍសុសវែរ (Software Development) វិទ្យាសាស្ត្រទិន្នន័យ (Data Science) សន្តិសុខសាយប័រ (Cybersecurity) បច្ចេកវិទ្យាប្លុកឆេន (Block Chain) បច្ចេកវិទ្យាហិរញ្ញវត្ថុ (Fintech) បច្ចេកវិទ្យាបញ្ញាសប្បនិមិត្ត (AI) និងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (E-Commerce) ជាដើម។

- ☐ ស្គាល់
- ☐ ធ្លាប់ឃើញ
- ☐ បានស្គាល់និងធ្លាប់ឃើញ
- ☐ មិនស្គាល់ទាល់តែសោះ ។

**៦, តើអ្នកធ្លាប់បានចូលរួមសិក្ខាសាលានិងទទួលបានការបណ្ដុះបណ្ដាលស្ដីអំពីសេដ្ឋកិច្ចឌីជីថលដែរឬទេ និងតាមរយៈមធ្យោបាយណា?**

- ☐ ធ្លាប់ តាមរយៈសិក្ខាសាលាផ្ទាល់
- ☐ ធ្លាប់ តាមរយៈសិក្ខាសាលាអនឡាញ
- ☐ ធ្លាប់ តាមរយៈការបណ្ដុះបណ្ដាលផ្ទាល់
- ☐ ធ្លាប់ តាមរយៈការបណ្ដុះបណ្ដាលអនឡាញ
- ☐ មិនដែលចូលរួម ។

**៧, តើនៅកន្លែងការងារដែលអ្នកបំពេញការងារសព្វថ្ងៃមានប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដែរឬទេ?**

- ☐ ប្រើ
- ☐ ប្រើខ្លះៗ
- ☐ មិនប្រើទេ ។

**៨, នៅក្នុងការបំពេញការងាររបស់អ្នក តើអ្នកមានជួបបញ្ហានិងការលំបាកនៅពេលកន្លែងការងាររបស់អ្នកបានបញ្ចូលឱ្យមានការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដែរឬទេ?**

- ☐ ពិបាកខ្លាំង
- ☐ ពិបាកខ្លះៗ
- ☐ មិនពិបាកទេ
- ☐ ជួបបញ្ហា មិនចេះដោះស្រាយ
- ☐ ជួបបញ្ហា អាចដោះស្រាយបាន ។

**៩, តើនៅក្នុងកន្លែងការងាររបស់អ្នកសម្បូរទៅដោយអ្នកជំនាញឌីជីថលដែរឬទេ?**

- ☐ មានច្រើន

☐ មិនសូវមាន ។

**១០, ចំពោះបច្ចេកវិទ្យាទាំងនោះ តើអ្នកគិតថាវាជួយសម្រួលដល់កិច្ចការងាររបស់ស្ថាប័នឬក្រុមហ៊ុនរបស់អ្នកបានប៉ុន្មានភាគរយ?**

.....................................................................................................................................................

- ចំពោះ យុវជន សិស្សានុសិស្ស៖

**១. បំពេញឈ្មោះខ្មែរ (គោត្តនាម-នាម)**

..................................................

**២. ភេទ**

☐ ស្រី

☐ ប្រុស

☐ សូមមិនចែករំលែក

**៣. ទីលំនៅបច្ចុប្បន្ន**

☐ ទីក្រុង

☐ ទីជនបទ

**៤. តើអ្នកកំពុងសិក្សានៅកម្រិតសកលវិទ្យាល័យឬវិទ្យាល័យ?**

☐ សកលវិទ្យាល័យ

☐ វិទ្យាល័យ

☐ ផ្សេងៗ

**៥. តើបច្ចុប្បន្នអ្នកមានប្រកបមុខរបរអាជីវកម្មផ្ទាល់ខ្លួនដែរឬទេ?**

☐ មាន

☐ មិនមាន

**៦. តើអ្នកស្គាល់បច្ចេកវិទ្យាឌីជីថលនិងជំនាញឌីជីថលដែរឬទេ?**

ជំនាញឌីជីថល សំដៅដល់សមត្ថភាពក្នុងការប្រើប្រាស់ឧបករណ៍ទំនាក់ទំនង កម្មវិធីទំនាក់ទំនង និងបណ្ដាញសង្គមជាដើម ដើម្បីអាចចូលទៅប្រើប្រាស់ទិន្នន័យ និងគ្រប់គ្រងព័ត៌មាន។ ឧទាហរណ៍៖ ការប្រើប្រាស់អ៊ីនធឺណិតសម្រាប់ការទំនាក់ទំនងដូចជា Telegram, Messenger, Facebook, Instagram, Line និង Twitter ជាដើម។

បច្ចេកវិទ្យាឌីជីថល មានដូចជា វិទ្យាសាស្ត្រកុំព្យូទ័រ (Computer Science) ទូរគមនាគមន៍និងបណ្ដាញ (Telecoms and Networking) បច្ចេកវិទ្យាក្លោដ (Cloud Computing) ការអភិវឌ្ឍសុសវែរ (Software Development) វិទ្យាសាស្ត្រទិន្នន័យ (Data Science) សន្តិសុខសាយប័រ (Cybersecurity) បច្ចេកវិទ្យាប្លុកឆេន (Block Chain) បច្ចេកវិទ្យាហិរញ្ញវត្ថុ (Fintech) បច្ចេកវិទ្យាបញ្ញាសប្បនិមិត្ត (AI) និងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (E-Commerce) ជាដើម។

☐ ស្គាល់

☐ មិនស្គាល់

៧. តើអ្នកធ្លាប់បានទទួលការបណ្តុះបណ្តាលពាក់ព័ន្ធនឹងបច្ចេកវិទ្យាឌីជីថលនិងជំនាញឌីជីថលពីមុនមកទេ និងតាមរយៈណា?

☐ ធ្លាប់ តាមរយៈសិក្សាដោយផ្ទាល់

☐ ធ្លាប់ តាមរយៈអនឡាញ

☐ មិនដែរសោះ

៨. នាពេលបច្ចុប្បន្ន តើអ្នកបានប្រើប្រាស់នូវបច្ចេកវិទ្យាឌីជីថលសម្រាប់ការសិក្សា ឬនៅក្នុងមុខរបរអាជីវកម្មរបស់អ្នកដែរឬទេ?

☐ ប្រើប្រាស់

☐ មិនសូវប្រើប្រាស់

☐ មិនប្រើប្រាស់ទេ

៩. តើអ្នកទទួលបានផលប្រយោជន៍ពីការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលនេះ បានប៉ុន្មានភាគរយ?

..........................................................................................................................................

១០. តើអ្នកយល់យ៉ាងណាដែរ ចំពោះស្ថានភាពនៃការសិក្សា ឬអាជីវកម្មរបស់អ្នក មុនពេលដែលអ្នកមិនទាន់បានប្រើប្រាស់បច្ចេកវិទ្យាឌីជីថលនេះ?

☐ ធម្មតា

☐ មានភាពយឺតយ៉ាវ

១១. ក្រោយពីបានឆ្លើយសំណួរខាងលើហើយ តើអ្នកគិតថា បច្ចេកវិទ្យាឌីជីថល និងការមានជំនាញឌីជីថលផ្ទាល់ខ្លួន មានសារៈសំខាន់សម្រាប់ខ្លួនឯងនិងជួយក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ចឌីជីថលនាពេលបច្ចុប្បន្នទៅអនាគតដែរទេ?

☐ សំខាន់ណាស់

☐ សំខាន់

☐ មិនសូវសំខាន់ ។

# ឧបសម្ព័ន្ធទី២៖ ទិន្នន័យ

## ➢ ចំពោះស្ថាប័នរដ្ឋ និង ឯកជន

### Gender

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Male | 11 | 45.8 | 45.8 | 45.8 |
| | Female | 13 | 54.2 | 54.2 | 100.0 |
| | Total | 24 | 100.0 | 100.0 | |

### ADRESS

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | City | 21 | 87.5 | 87.5 | 87.5 |
| | Province | 3 | 12.5 | 12.5 | 100.0 |
| | Total | 24 | 100.0 | 100.0 | |

### JOB

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Public Sector | 9 | 37.5 | 37.5 | 37.5 |
| | Private Section | 15 | 62.5 | 62.5 | 100.0 |
| | Total | 24 | 100.0 | 100.0 | |

### DIGITAL SKILL

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Known | 18 | 75.0 | 75.0 | 75.0 |
| | Had been saw | 1 | 4.2 | 4.2 | 79.2 |
| | Known and saw | 5 | 20.8 | 20.8 | 100.0 |
| | Total | 24 | 100.0 | 100.0 | |

## DIGITAL_TRAINNING

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Study in class | 6 | 25.0 | 25.0 | 25.0 |
| | Study by online | 6 | 25.0 | 25.0 | 50.0 |
| | Training in class | 4 | 16.7 | 16.7 | 66.7 |
| | Training by online | 3 | 12.5 | 12.5 | 79.2 |
| | Never | 5 | 20.8 | 20.8 | 100.0 |
| | Total | 24 | 100.0 | 100.0 | |

## DIGITAL_USE

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Use | 18 | 75.0 | 75.0 | 75.0 |
| | Use a bit | 6 | 25.0 | 25.0 | 100.0 |
| | Total | 24 | 100.0 | 100.0 | |

## DIGITAL_PROBLEM

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Difficult a little bit | 11 | 45.8 | 45.8 | 45.8 |
| | Not difficult | 6 | 25.0 | 25.0 | 70.8 |
| | Can't solve problem | 1 | 4.2 | 4.2 | 75.0 |
| | Can solve problem | 6 | 25.0 | 25.0 | 100.0 |
| | Total | 24 | 100.0 | 100.0 | |

## DIGITAL_EXPERT

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | So many | 12 | 50.0 | 50.0 | 50.0 |
| | Less | 12 | 50.0 | 50.0 | 100.0 |
| | Total | 24 | 100.0 | 100.0 | |

**DIGITAL_ADVANCETAGE**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | 50.00% | 8 | 33.3 | 33.3 | 33.3 |
| | 70.00% | 6 | 25.0 | 25.0 | 58.3 |
| | 80.00% | 3 | 12.5 | 12.5 | 70.8 |
| | 90.00% | 5 | 20.8 | 20.8 | 91.7 |
| | 95.00% | 2 | 8.3 | 8.3 | 100.0 |
| | Total | 24 | 100.0 | 100.0 | |

**Interest**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Public use Digital | 6 | 25.0 | 33.3 | 33.3 |
| | Private use Digital | 12 | 50.0 | 66.7 | 100.0 |
| | Total | 18 | 75.0 | 100.0 | |
| Missing | System | 6 | 25.0 | | |
| Total | | 24 | 100.0 | | |

- **ចំពោះយុវជន និង សិស្សានុសិស្ស**

**Gender**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Male | 52 | 50.5 | 50.5 | 50.5 |
| | Female | 51 | 49.5 | 49.5 | 100.0 |
| | Total | 103 | 100.0 | 100.0 | |

**Address**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | City | 77 | 74.8 | 74.8 | 74.8 |
| | Province | 26 | 25.2 | 25.2 | 100.0 |
| | Total | 103 | 100.0 | 100.0 | |

## EDUCATION

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | University | 54 | 52.4 | 52.4 | 52.4 |
| | High school | 49 | 47.6 | 47.6 | 100.0 |
| | Total | 103 | 100.0 | 100.0 | |

## OWNBUSINESS

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Have business | 18 | 17.5 | 17.5 | 17.5 |
| | Haven't business | 85 | 82.5 | 82.5 | 100.0 |
| | Total | 103 | 100.0 | 100.0 | |

## DIGITAL_KNOWLAGE

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Known | 101 | 98.1 | 98.1 | 98.1 |
| | Unknown | 2 | 1.9 | 1.9 | 100.0 |
| | Total | 103 | 100.0 | 100.0 | |

## DIGITAL_TRAINNING

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Direct study in class | 63 | 61.2 | 61.2 | 61.2 |
| | Study online | 40 | 38.8 | 38.8 | 100.0 |
| | Total | 103 | 100.0 | 100.0 | |

## DIGITAL_USE

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Using digital | 81 | 78.6 | 78.6 | 78.6 |
| | Sometime using digital | 22 | 21.4 | 21.4 | 100.0 |
| | Total | 103 | 100.0 | 100.0 | |

## DIGITAL_ADVANCETAGE

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | 10.00% | 2 | 1.9 | 1.9 | 1.9 |
| | 18.00% | 1 | 1.0 | 1.0 | 2.9 |
| | 40.00% | 1 | 1.0 | 1.0 | 3.9 |
| | 50.00% | 7 | 6.8 | 6.8 | 10.7 |
| | 60.00% | 4 | 3.9 | 3.9 | 14.6 |
| | 65.00% | 3 | 2.9 | 2.9 | 17.5 |
| | 70.00% | 21 | 20.4 | 20.4 | 37.9 |
| | 75.00% | 1 | 1.0 | 1.0 | 38.8 |
| | 80.00% | 21 | 20.4 | 20.4 | 59.2 |
| | 85.00% | 6 | 5.8 | 5.8 | 65.0 |
| | 86.00% | 1 | 1.0 | 1.0 | 66.0 |
| | 90.00% | 29 | 28.2 | 28.2 | 94.2 |
| | 95.00% | 4 | 3.9 | 3.9 | 98.1 |
| | 100.00% | 2 | 1.9 | 1.9 | 100.0 |
| | Total | 103 | 100.0 | 100.0 | |

## BUSINESS_DIGITALL

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Normal | 60 | 58.3 | 58.3 | 58.3 |
| | Slowly | 43 | 41.7 | 41.7 | 100.0 |
| | Total | 103 | 100.0 | 100.0 | |

## DIGITALIMPORTANCE

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Very important | 73 | 70.9 | 70.9 | 70.9 |
| | important | 29 | 28.2 | 28.2 | 99.0 |
| | Not important | 1 | 1.0 | 1.0 | 100.0 |
| | Total | 103 | 100.0 | 100.0 | |

## Benefit Digital

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Business benefit digital | 102 | 99.0 | 99.0 | 99.0 |
| | useless | 1 | 1.0 | 1.0 | 100.0 |
| | Total | 103 | 100.0 | 100.0 | |

# ឧបសម្ព័ន្ធ៖ អត្ថបទ

(ឧបសម្ព័ន្ធទី១)

https://www.facebook.com/kh.mef.gdde?mibextid=LQQJ4d

(ឧបសម្ព័ន្ធទី២)

https://digitaleconomy.gov.kh/index

(ឧបសម្ព័ន្ធទី៣)

ក្នុងគេហទំព័រនេះ មានបង្កើតនូវកម្មវិធីអក្ខរកម្មឌីជីថល (E-LEARNING) និងមានវគ្គបណ្ដុះបណ្ដាលអក្ខរកម្មឌីជីថលតាមរយៈសិក្ខាកាមជាច្រើន សម្រាប់យុវជនគ្រប់រូបអាចចូលមើលបានដោយសេរី។

https://cambodia4point0.org/kh

(ឧបសម្ព័ន្ធទី៤)

https://www.facebook.com/itstepcambodia?mibextid=LQQJ4d

https://www.facebook.com/CADT.Academy?mibextid=LQQJ4d

https://www.facebook.com/istad.co?mibextid=LQQJ4d

https://www.facebook.com/seals.edu?mibextid=LQQJ4d

(ឧបសម្ព័ន្ធទី៥)

| | | |
|---|---|---|
| https://www.facebook.com/itstepcambodia?mibextid=LQQJ4d | https://www.facebook.com/rupp.edu.kh?mibextid=LQQJ4d | https://www.facebook.com/nortonuniversitycambodia?mibextid=LQQJ |

(ឧបសម្ព័ន្ធទី៦)

| | | | |
|---|---|---|---|
| https://www.facebook.com/ntti.edu.kh?mibextid=LQQJ4d | https://www.facebook.com/NationalInstituteofEntrepreneurshipandInnovation?mibextid=LQQJ4d | https://www.facebook.com/ntti.edu.kh?mibextid=LQQJ4d | https://www.facebook.com/NIBofficial?mibextid=LQQJ4d |

(ឧបសម្ព័ន្ធទី៧)

